វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា



# ផលប៉ះពាល់ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ

ស៊េរីឯកសារពិភាក្សា វិទ្យាស្ថាន CDRI លេខ 41



ការបោះពុម្ពផ្សាយរបស់
វិទ្យាស្ថាន CDRI
ខែតុលា 2009

# ផលប៉ះពាល់នៃ
# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
# អាស៊ាន-ចិន ចំពោះបរិស្ថាននៅតាម
# បណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ

ឯកសារពិភាក្សាវិទ្យាស្ថាន CDRI លេខ ៤១

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ ខែតុលា ឆ្នាំ២០០៩

**បេសកកម្ម វិបសអ**

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វិបសអ មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់អំពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។*

*វិបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និង បទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

**© រក្សាសិទ្ធិឆ្នាំ២០០៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN 978–99950–52-12-6

***សំរាប់គន្ថនិទ្ទេសៈ***
**វិទ្យាស្ថាន CDRI, ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន–ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ ឯកសារពិភាក្សាលេខ ៤១ (ភ្នំពេញ វិទ្យាស្ថាន CDRI)**
CDRI (2009), *The Environmental Impacts of the ASEAN-China Free Trade Agreement for Countries in the Greater Mekong Sub-region*, Working Paper No 41 (Phnom Penh: CDRI)

ខែសីហា ឆ្នាំ២០០៩

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)**
**ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)**
**ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣**
**ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤**
**អ៊ីមែល:** cdri@wicam.com.kh **website:** http://www.cdri.org.kh

រូបភាពក្របមុខៈ

១. ខេត្តព្រះសីហនុៈ ផ្លូវជាតិលេខ ៤ បានពង្រីក និងថែទាំបានល្អ ដើម្បីទ្រទ្រង់ដល់សកម្មភាពនានាដែលកំពុងតែកើនឡើងនៅកំពង់ផែសមុទ្រកម្ពុជា (ថតនៅខែតុលា ២០០៨ *ដោយ អ៊ុំ ចាន់ថា*)

២. តំបន់ឧស្សាហកម្មនៅខេត្តកំពង់ចាម (ថតនៅខែកក្កដា ២០០៨ *ដោយ ហេង ស៊ីនិត្យ*)

កែសម្រួល និងរចនាដោយៈ អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយៈ ខេង សេង និង អ៊ឹង សុជាតិ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ភ្នំពេញ

# មាតិកា


**បញ្ជីក្រាហ្វិក និងតារាង** .......... ៥

**បញ្ជីអក្សរកាត់** .......... ៧

**សេចក្តីថ្លែងអំណរគុណ** .......... ៩

**សេចក្តីសង្ខេប** .......... ១១

**ជំពូក ១ | សេចក្តីផ្តើម** .......... **១៥**

១.១. សាវតា .......... ១៥

១.២. គោលដៅនៃការស្រាវជ្រាវ .......... ១៦

១.៣. ទំហំនៃការសិក្សា .......... ១៧

១.៤. រចនាសម្ព័ន្ធ .......... ១៨

**ជំពូក ២ | ការពិនិត្យជាទូទៅជុំវិញការជជែកដេញដោលពីពាណិជ្ជកម្ម និងបរិស្ថាន** .......... **១៩**

២.១. បទបញ្ញត្តិបរិស្ថាន ការប្រកួតប្រជែង និងកាផ្លាស់ប្តូរទីតាំងឧស្សាហកម្ម .......... ១៩

២.១.១ តើបទបញ្ញត្តិបរិស្ថានតឹងរ៉ឹង ប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ? .......... ១៩

២.១.២. តើបទបញ្ញត្តិបរិស្ថាន ធ្វើឱ្យឧស្សាហកម្មកខ្វក់មួយចំនួន ផ្លាស់ប្តូរទីតាំងឬ? .......... ២១

២.២. កំណើនសេដ្ឋកិច្ច និងបរិស្ថាន .......... ២៥

២.៣. សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថាន .......... ២៦

២.៤. សង្ខេបសេចក្តី .......... ៣០

**ជំពូក ៣ | វិធីសាស្ត្រវាយតំលៃផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាន** .......... **៣៣**

៣.១. ការវាស់វែង និងព្យាករណ៍ពីផលវិបាកខាងបរិស្ថាននៃពាណិជ្ជកម្ម .......... ៣៣

៣.២. វិធីសាស្ត្រកែតំរូវសំរាប់វាយតំលៃផលវិបាកខាងបរិស្ថាន ចំពោះពាណិជ្ជកម្ម .......... ៣៤

៣.២.១. ម៉ាទ្រីសពាណិជ្ជកម្ម ប្រើជាឧបករណ៍សំរាប់វិភាគពីនិន្នាការពាណិជ្ជកម្ម .......... ៣៤

៣.២.២. ការធ្វើចំណាត់ថ្នាក់វិស័យនានា ទៅតាមកំរិតបំពុល .......... ៣៥

៣.២.៣ ការវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការបំពុល .......... ៣៧

**ជំពូក ៤ | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងផលប៉ះពាល់ទៅលើពាណិជ្ជកម្ម និងបរិស្ថាននៅមហាអនុតំបន់មេគង្គ** .......... **៣៩**

៤.១ ការបង្ហាញត្រួសៗពី ACFTA .......... ៣៩

៤.១.១ ប្រវត្តិ ACFTA ..... ៣៩

៤.១.២ សន្និទាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ..... ៤០

៤.១.៣ កម្មវិធីប្រមូលផលដើមដៃ ..... ៤១

៤.១.៤ កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ ..... ៤២

៤.២ ពាណិជ្ជកម្មនៅក្នុងមហាអនុតំបន់មេគង្គ និងផលប៉ះពាល់ទៅលើបរិស្ថាន ..... ៤៧

៤.២.១ ការពិនិត្យត្រួសៗពីពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិន ..... ៤៧

៤.២.២ ឥទ្ធិពលនៃពាណិជ្ជកម្មលើការបំពុល ..... ៥៣

**ជំពូក ៥ | ពាណិជ្ជកម្មរវាងកម្ពុជា-ចិន និងផលប៉ះពាល់ទៅលើបរិស្ថាន ..... ៥៧**

៥.១. ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងចិន ..... ៥៧

៥.២. ផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាននៅកម្ពុជា ..... ៦២

**ជំពូក ៦| សន្និដ្ឋាន និងការពិភាក្សាជាគោលនយោបាយ ..... ៦៧**

**ឯកសារយោង ..... ៧១**

**ឧបសម្ព័ន្ធស្ថិតិ ..... ៧៥**

**បញ្ជីឯកសារពិភាក្សារបស់ វិបសអ ..... ៨៥**

# បញ្ជីក្រាហ្វិក និងតារាង

ក្រាហ្វិក ១: ខ្សែកោងបរិស្ថាន Kuznets (EKC) ........ ២៥
ក្រាហ្វិក ២: ពាណិជ្ជកម្មរវាងប្រទេសចិន និងប្រទេស GMS5 ........ ៤៧
ក្រាហ្វិក ៣: និន្នាការនៃការនាំចូលរបស់ប្រទេសចិននូវផលិតផលមកពីប្រទេស GMS5 ........ ៤៩
ក្រាហ្វិក ៤: និន្នាការនៃការនាំចូលពីប្រទេសចិនមកប្រទេស GMS5 ........ ៥២
ក្រាហ្វិក ៥: ពាណិជ្ជកម្មរវាងកម្ពុជា និងចិន ........ ៥៧
ក្រាហ្វិក ៦: និន្នាការនៃការនាំចូលពីកម្ពុជារបស់ចិន ........ ៦០
ក្រាហ្វិក ៧: និន្នាការនៃការនាំចូលផលិតផលពីចិនមកកម្ពុជា ........ ៦២

តារាង ១: សង្ខេបពីការធ្វើចំណាត់ថ្នាក់កំរិតបំពុល គិតតាមវិស័យ ........ ៣៦
តារាង ២: អាស៊ាន ៦ និងចិន ........ ៤២
តារាង ៣: វៀតណាម ........ ៤៣
តារាង ៤: កម្ពុជា ឡាវ និងភូមា ........ ៤៣
តារាង ៥: តារាងពេលនៃការកាត់បន្ថយពន្ធគយសំរាប់ផលិតផលក្នុងក្រុមងាយប៉ះពាល់: អាស៊ាន ៦ និងចិន ........ ៤៤
តារាង ៦: តារាងពេលនៃការកាត់បន្ថយពន្ធគយសំរាប់ផលិតផលក្នុងបញ្ជីងាយប៉ះពាល់ ........ ៤៤
តារាង ៧: ផលិតផលនាំចេញពីប្រទេស GMS5 ទៅប្រទេសចិន ........ ៤៨
តារាង ៨: ការនាំចូលនៃប្រទេស GMS5 ពីប្រទេសចិន ........ ៥១
តារាង ៩: ម៉ាទ្រីសពាណិជ្ជកម្ម-បរិស្ថានសំរាប់ពាណិជ្ជកម្មសរុបរវាងប្រទេស GMS5 និងចិន ........ ៥៤
តារាង ១០: មុខទំនិញនាំចេញរបស់កម្ពុជាទៅចិន ........ ៥៩
តារាង ១១: រចនាសម្ព័ន្ធនៃការនាំចូលពីចិនរបស់កម្ពុជា ........ ៦១
តារាង ១២: ម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្មសំរាប់ការនាំចេញពីកម្ពុជាទៅចិន ........ ៦៣
តារាង ១៣: ផលចំណេញប៉ាន់ស្មានលើការបំពុល ដែលកម្ពុជាទទួលបានពីការនាំចូលទំនិញពីចិន ........ ៦៤

តារាង A.1: កំរិតនៃការបំពុលបែងចែកតាមមធ្យោបាយបំពុល គិតតាមតម្លៃសរុបនៃធាតុចេញ ........ ៧៥
តារាង A.2: ពាណិជ្ជកម្មថៃជាមួយចិន ........ ៧៦
តារាង A.3: ពាណិជ្ជកម្មវៀតណាមជាមួយចិន ........ ៧៧
តារាង A.4: ពាណិជ្ជកម្មឡាវជាមួយចិន ........ ៧៨
តារាង A.5: ពាណិជ្ជកម្មមីយ៉ាន់ម៉ាជាមួយចិន ........ ៧៩
តារាង A.6: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់ប្រទេស GMS5 នៅក្នុងទីផ្សារចិន ........ ៨០

តារាង A.7: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់ថៃនៅក្នុងទីផ្សារចិន ........................ ៨០
តារាង A.8: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់វៀតណាមនៅក្នុងទីផ្សារចិន ............. ៨១
តារាង A.9: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់ឡាវនៅក្នុងទីផ្សារចិន...................... ៨១
តារាង A.10: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់មីយ៉ាន់ម៉ានៅក្នុងទីផ្សារចិន............. ៨២
តារាង A.11: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់កម្ពុជានៅក្នុងទីផ្សារចិន ................. ៨២
តារាង A.12: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់ចិននៅក្នុងទីផ្សារប្រទេស GMS5..... ៨៣
តារាង A.13: សន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) របស់ចិននៅក្នុងទីផ្សារកម្ពុជា ................. ៨៣

# បញ្ជីអក្សរកាត់

| | |
|---|---|
| ស.រ.អា | សហរដ្ឋអាមេរិក |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (Association of South East Asian Nations) |
| ACFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN-China Free Trade Area) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Resource Institute) |
| EHP | កម្មវិធីប្រមូលផលដើមដៃ (Early Harvest Programme) |
| EKC | ខ្សែកោង Kuznets ស្តីពីបរិស្ថាន (Environmental Kuznets Curve) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign direct investment) |
| FTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (Free trade agreement) |
| GMS | មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) |
| HS | ប្រព័ន្ធសុខដុមនីយកម្ម (Harmonised System) |
| IISD | វិទ្យាស្ថានអន្តរជាតិសំរាប់ការអភិវឌ្ឍន៍មានចីរភាព<br>(International Institute for Sustainable Development) |
| ISIC | ចំណាត់ថ្នាក់ឧស្សាហកម្មតាមស្តង់ដារអន្តរជាតិ<br>(International Standard Industrial Classification) |
| MFN | លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (Most favoured nation) |
| RCA | ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (Revealed comparative advantage) |
| SAM | ម៉ាទ្រីសគណនេយ្យសង្គម (Social accounting matrix) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

## សេចក្តីថ្លែងអំណរគុណ[១]

ក្រុមអ្នកស្រាវជ្រាវនៃ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) រួមមាន លោក ហ៊ីង វុត្ថា ជាអ្នកស្រាវជ្រាវ និង បណ្ឌិត Hossein Jalilian ជានាយកផ្នែកស្រាវជ្រាវរបស់វិទ្យាស្ថាន ។ វិទ្យាស្ថានអន្តរជាតិសំរាប់ការអភិវឌ្ឍន៍មានចីរភាព (IISD) បានផ្តល់ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដល់ការសិក្សានេះ តាមរយៈបណ្តាញចំណេះដឹងខាងពាណិជ្ជកម្ម ។ ក្រុមអ្នកនិពន្ធ និងវិទ្យាស្ថាន CDRI សូមអរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថាន IISD ចំពោះជំនួយគាំទ្រដ៏សប្បុរសដល់គំរោងនេះ ។

អ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណផងដែរដល់សមាជិកវិទ្យាស្ថាន IISD មានជាអាទិ៍ Aaron Cosbey, Heike Baumüller និង Oli Brown ដែលបានជួយផ្តល់យោបល់ស្ថាបនាលើក្របខ័ណ្ឌនៃការវិភាគ និងរបាយការណ៍ព្រាងនេះ ។ អ្នកនិពន្ធ ក៏សូមអរគុណចំពោះការផ្តល់ជាគំនិត និងយោបល់ដ៏មានតំលៃពីសំណាក់ភ្ញៀវកិត្តិយសជាច្រើន ដែលបានមកចូលរួមនៅក្នុងសិក្ខាសាលាការផ្សព្វផ្សាយពីរបកគំហើញជាដំបូង១នាពេលកន្លងទៅ ។

---

[១] ការសិក្សានេះ បានធ្វើឡើងក្នុងក្របខ័ណ្ឌនៃបណ្តាញចំណេះដឹងខាងពាណិជ្ជកម្ម ដែលជាគំរោងមួយរបស់វិទ្យាស្ថានអន្តរជាតិសំរាប់ការអភិវឌ្ឍន៍មានចីរភាព (www.tradeknowledgenetwork.net) ។

## សេចក្ដីសង្ខេប

ជាងពីរទសវត្សរ៍កន្លងមកនេះ មហាអនុតំបន់មេគង្គ (GMS) ដែលមានប្រទេសកម្ពុជា ឡាវ ភូមា ថៃ វៀតណាម និងខេត្តយូណាននៃប្រទេសចិន បានឆ្លងកាត់បម្លាស់ប្ដូរខាងសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងលឿន ជាពិសេសនៅក្នុងសេរីភាវូបនីយកម្មពាណិជ្ជកម្ម តាមរយៈកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដ៏ជិតស្និទ្ធ ។ នៅឆ្នាំ២០០៤ ក្នុងលក្ខណៈជាសមាជិកអាស៊ាន បណ្ដាប្រទេសក្នុង GMS5 (ប្រទេសទាំងអស់ក្នុង GMS លើកលែងខេត្តយូណានចេញ) និងប្រទេសចិន បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ។ ACFTA តំរូវឱ្យប្រទេសនីមួយៗកាត់បន្ថយពន្ធគយជាបណ្ដើរៗ លើទំនិញដែលនាំចេញមកពីប្រទេសជាដៃគូនៅក្នុងកិច្ចព្រមព្រៀងនេះ ។

ជាលទ្ធផលនៃការប្ដេជ្ញាចិត្តធ្វើឡើងនៅក្នុង ACFTA អត្រាពន្ធគយលើទំនិញនាំចេញពីចិន មកកាន់ប្រទេស GMS5 ក៏ដូចជាពីប្រទេស GMS5 ទៅចិន បានត្រូវកាត់បន្ថយ ។ ការវិភាគពីលំហូរពាណិជ្ជកម្មនៅមុន និងក្រោយ ACFTA បង្ហាញថា ពាណិជ្ជកម្មរវាងចិន និងប្រទេស GMS5 បានកើនឡើងយ៉ាងច្រើនបន្ទាប់ពីការចុះកិច្ចព្រមព្រៀងនេះ ជាពិសេសចំពោះមុខទំនិញដែលគេបានកាត់បន្ថយពន្ធគយ ។ និន្នាការស្រដៀងគ្នា ក៏បានសង្កេតឃើញនៅកម្ពុជាដែរ ទោះបីជាផលិតផលនាំចេញមួយចំនួនដែលទទួលបានការកាត់បន្ថយពន្ធ វាមានកំណើនយឺតក្ដី ដោយសារអ្នកនាំចេញជួបការលំបាកក្នុងការបំពេញតាមស្ដង់ដារនាំចូលរបស់ចិន សំរាប់ផលិតផលកសិកម្ម ដូចជា ដំឡូងឈើ សត្វចិញ្ចឹម និងត្រី ជាដើម ។ ការរកឃើញទាំងនេះ បង្ហាញថា ACFTA ជាកត្តាជំរុញយ៉ាងសំខាន់ដល់ការរីកដុះដាលយ៉ាងលឿននៃពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិន ជាពិសេសបណ្ដាផលិតផល ដែលមិនចាំបាច់តំរូវតាមស្ដង់ដារដ៏ច្រើន ដូចជា ផ្នែកសុខភាព និងសុវត្ថិភាពចំណីអាហារជាដើម ។

ពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិន គឺប្រមូលផ្ដុំលើក្រុមផលិតផលមួយចំនួនតូច ដូចជា គ្រឿងចក្រ និងគ្រឿងបរិក្ខាអគ្គិសនី លោហៈសំខាន់ៗ ផលិតផលរ៉ែ វត្ថុធាតុគីមី វាយនភ័ណ្ឌ សំលៀកបំពាក់ កៅស៊ូ និងផលិតផលបន្លែជាដើម ។ ពីរភាគបីនៃបរិមាណទំនិញធ្វើពាណិជ្ជកម្ម គឺជាផលិតផលស្ថិតក្នុងក្រុមមានការបំពុលតិចបំផុត (គឺប្រភេទដែលបញ្ចេញសារជាតិពុលតិចជាង ៥០០តោន/លានដុល្លារអាមេរិកនៃផលិតកម្ម) រីឯមួយភាគបី គឺជាផលិតផលស្ថិតក្នុងក្រុមដែលមានការបំពុលខ្ពស់បំផុត (គឺមានសារធាតុបំពុលច្រើនជាង ១៥០០តោន/លានដុល្លារអាមេរិកនៃផលិតកម្ម) ។ ការបំពុលកើតចេញពីក្រុមទីពីរនេះ មានច្រើនគួរឱ្យកត់សំគាល់ ហើយកំណើនពាណិជ្ជកម្មដែលគេអាចប៉ាន់ប្រមាណនេះ ទំនងជានឹងបង្កការបំពុលកាន់តែច្រើនទៀតនៅក្នុងរយៈពេលខ្លី ។

នៅក្នុងរចនាសម្ព័ន្ធពាណិជ្ជកម្ម GMS ប្រទេសចិនជាផលិតករចំបងគេខាងមុខទំនិញស្ថិតក្នុងក្រុមមានសារធាតុបំពុលខ្ពស់ គឺបានន័យថា សកម្មភាពបំពុលភាគច្រើននៅក្នុងតំបន់ GMS វាមានប្រភពមកពីប្រទេសចិន ។ នៅកម្ពុជា កំណើនការនាំចូលទំនិញ ក្នុងក្រុមមានសារធាតុបំពុលខ្ពស់មកពីប្រទេសចិន បានធ្វើឱ្យប្រទេសយើងទទួលផលចំណេញយ៉ាងច្រើនពីពាណិជ្ជកម្មទាក់ទងនឹងបរិស្ថាន ប៉ុន្តែផលចំណេញនេះ បានមកពីការបំផ្លាញបរិស្ថាននៅក្នុងប្រទេសចិន ។

គេឃើញមានពាណិជ្ជកម្មខាងធនធានធម្មជាតិយ៉ាងច្រើននៅក្នុង GMS ដូចជា រ៉ែ ទំនិញកសិកម្ម និងឈើព្រមទាំងផលិតផលដែលផលិតចេញពីធនធានទាំងនេះ ។ ពាណិជ្ជកម្មទំនិញផ្អែកលើធនធានធម្មជាតិ បង្កការព្រួយបារម្ភជាច្រើនដល់បរិស្ថាន ទាក់ទិននឹងការរេចរឹលធនធាន ។ តំរូវការឈើ និងផលិតផលធ្វើពីឈើយ៉ាងច្រើននៅចិនបាននាំឱ្យមានកំណើន ការនាំចេញផលិតផលទាំងនេះ ពីប្រទេស GMS5 ។ ពាណិជ្ជកម្មឈើ និងផលិតផលធ្វើពីឈើដោយមិនមានច្បាប់គ្រប់គ្រងត្រឹមត្រូវ អាចធ្វើឱ្យថយចុះព្រៃឈើ និងនាំឱ្យមានបញ្ហាបរិស្ថានផ្សេងៗទៀត ដូចជា ការបាត់បង់ជីវៈចំរុះ សំណឹកដី ទឹកជំនន់ ការបាក់ដី និងបម្លាស់ប្តូរអាកាសធាតុ ។ ការពង្រីកវិស័យកសិកម្ម និងរុករករ៉ែ អាចដាក់សម្ពាធបន្ថែមទៀតទៅលើព្រៃធម្មជាតិ ។ ដោយសារពុំមានប្រព័ន្ធគ្រប់គ្រងវិស័យនេសាទ កំណើនពាណិជ្ជកម្មផលិតផលត្រី ទំនងជំរុញឱ្យមានការនេសាទហួសកំរិត ដែលមានផលប៉ះពាល់អាក្រក់ទៅលើស្តុកត្រី និងជីវភាពប្រជាជនមូលដ្ឋាន ជាពិសេសប្រជាពលរដ្ឋរស់នៅពឹងផ្អែកដោយផ្ទាល់លើការនេសាទ ។

ការរេចរឹលធនធានធម្មជាតិ ជាចំណុចព្រួយបារម្ភដ៏ធំមួយសំរាប់កម្ពុជា ដែលជាប្រទេសនាំចេញផលិតផលជាច្រើនផ្អែកលើធនធានធម្មជាតិ ។ កម្ពុជាកំពុងជួបប្រទះបញ្ហាប្រឈមខាងបរិស្ថានយ៉ាងច្រើន រួមមាន ការបាត់បង់គំរបព្រៃឈើ ការរេចរឹលធនធានត្រីទឹកសាប ការរេចរឹលធនធាននៅតំបន់ឆ្នេរ ការបាត់បង់ជីវៈចំរុះ និងច្បាប់បរិស្ថានដ៏ទន់ខ្សោយ ។ កំណើនពាណិជ្ជកម្មផលិតផលផ្អែកលើធនធានធម្មជាតិនៅក្នុងបរិបទនេះ ទំនងជាបង្កការខូចខាតច្រើនថែមទៀតដល់គុណភាពបរិស្ថាន ។

បញ្ហាបរិស្ថាន បានទទួលការយកចិត្តទុកដាក់មួយកំរិតពីថ្នាក់ដឹកនាំ GMS ដោយមានការព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំកំពូល GMS ដើម្បីកែលំអកិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហារួមខាងបរិស្ថាននៅក្នុងតំបន់ ។ ទោះយ៉ាងនេះក្តី នៅមានកង្វះយន្តការខាងស្ថាប័នមួយចំនួន សំរាប់សម្របសម្រួលការអនុវត្តគោលនយោបាយការពារបរិស្ថាន ឬផែនការសកម្មភាពផ្សេងៗ ។ អវត្តមានបទបញ្ញត្តិស្តីពីកិច្ចសហប្រតិបត្តិការផ្នែកបរិស្ថាននៅក្នុង ACFTA ក៏បង្ហាញពីកង្វះខាតគួរកត់សំគាល់នូវការបង្កើតគោលនយោបាយសេដ្ឋកិច្ចក្នុងតំបន់ផងដែរ ។ ជាការពិតណាស់ ការដាក់បញ្ចូលបញ្ហាព្រួយបារម្ភពីបរិស្ថាន ទៅក្នុងរបៀបវារៈពាណិជ្ជកម្ម GMS មិនមែនងាយស្រួលទេ យោងតាមកំរិតអភិវឌ្ឍន៍ទាបនៅក្នុងតំបន់នាពេលបច្ចុប្បន្ន ដែលទាមទារឱ្យមានអត្រាកំណើនសេដ្ឋកិច្ចកំរិតខ្ពស់ និងមានចីរភាព ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចដែលសំរេចបានដោយមានការបំផ្លិចបំផ្លាញបរិស្ថាន នឹងមិននាំឱ្យមានវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមកិច្ចឋិតថេរឡើយ ។ ការស្វែងរកតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងចីរភាពបរិស្ថាន គឺជាបញ្ហាអាទិភាពមួយដើម្បីសំរេចបានការអភិវឌ្ឍមានចីរភាពនៅក្នុង GMS ។ ដូចនេះ ជាការសំខាន់ដែលប្រទេស GMS ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈគោលនយោបាយ និងស្ថាប័នផ្សេងៗ ដើម្បីឆ្លើយតបឱ្យបានសក្តិសិទ្ធិ ចំពោះបញ្ហាបរិស្ថាននានាដែលផុសឡើង ។

នៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងផែនការផ្សេងៗក្នុងគោលដៅគ្រប់គ្រង អភិរក្ស និងការពារបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេលវែង ។ ប៉ុន្តែការអនុវត្តក្របខ័ណ្ឌទាំងនេះ បានជួបឧបសគ្គដោយសារកង្វះបុគ្គលិកមានជំនាញ ការបែងចែកថវិកាមិនបានគ្រប់គ្រាន់ ស្ថាប័នជាច្រើនមានមុខងារ

និងការទទួលខុសត្រូវត្រួតគ្នា និងភាពខ្សត់ខ្សោយនូវធនធានរូបវន្ត ។ រដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងសហគមន៍សង្គមស៊ីវិល គួរប្រឹងប្រែងដោះស្រាយបញ្ហាជាអាទិភាពទាំងនេះ ។

ការសិក្សានេះបានបង្ហាញច្បាស់ពីបញ្ហាបរិស្ថានជាច្រើន ដែលអាចផុសចេញពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលជាក្បាលម៉ាស៊ីនដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច ។ ជាការសំខាន់មែនដែលប្រទេសនៅ GMS ត្រូវបន្តពង្រីកពង្រឹងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ច ប៉ុន្តែក៏ត្រូវតែគិតគូរផងដែរពីបញ្ហាបរិស្ថាន និងដាក់បញ្ចូលវាទៅក្នុងការចរចា និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្សេងៗដែលពាណិជ្ជកម្មអាចបង្កដល់បរិស្ថាន ។ ធ្វើបែបនេះ ទើបពាណិជ្ជកម្មអាចជួយជំរុញកំណើនសេដ្ឋកិច្ច និងរួមចំណែកដល់ការអភិវឌ្ឍមានចីរភាព ។

## ជំពូក ១

# សេចក្ដីផ្ដើម

## ១.១. សាវតា

មហាអនុតំបន់មេគង្គ (GMS) រួមមានប្រទេសកម្ពុជា ឡាវ ភូមា ថៃ វៀតណាម និងខេត្តយូណានក្នុងប្រទេសចិនភាគនិរតី ។[២] តំបន់នេះគ្របដណ្ដប់លើផ្ទៃដីជិត ២,៣លានគ.ម[២] និងមានប្រជាជន ២៦៦លាននាក់ ។ ក្នុងអំឡុងពីរទសវត្សរ៍កន្លងទៅ GMS មានបម្លាស់ប្ដូរសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងលឿន ហើយគោលនយោបាយសេរីភាវូបនីយកម្មសេដ្ឋកិច្ច បានជួយផ្លាស់ប្ដូរប្រទេសមួយចំនួនក្នុង GMS ឱ្យទៅជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោក ។ ប្រទេសមានរបបសេដ្ឋកិច្ចតាមផែនការប្រមូលផ្ដុំពីមុនចំនួន ៤ គឺ ចិន វៀតណាម ឡាវ និងកម្ពុជា បានចាប់អនុវត្តកម្មវិធីកំណែទំរង់សេដ្ឋកិច្ចយ៉ាងសកម្មចាប់តាំងពីចុងឆ្នាំ១៩៧០ (ចិន) ចុងឆ្នាំ១៩៨០ (វៀតណាម) និងដើមឆ្នាំ១៩៩០ (ឡាវ និងកម្ពុជា) ដោយទទួលបានជោគជ័យគួរឱ្យកត់សំគាល់ ។ នាពេលបច្ចុប្បន្ន ប្រទេសទាំងនេះមានភាពសេរី និងបើកចំហច្រើនជាងកាលពី ១៥ឆ្នាំមុន ទោះបីជាកំរិតសេរីភាវូបនីយកម្មទីផ្សារប្រែប្រួលខុសគ្នាច្រើនក្នុងចំណោមប្រទេសទាំងនេះក្ដី[៣] ហើយពាណិជ្ជកម្ម និងវិនិយោគបានដើរតួយ៉ាងសំខាន់ក្នុងការសំរេចបានកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ ។

ប្រទេសទាំងអស់ក្នុង GMS សុទ្ធតែចូលរួមក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗនៅក្នុងតំបន់ ។ ប្រទេស GMS ទាំងអស់សុទ្ធតែជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) លើកលែងតែប្រទេសឡាវមួយចេញដែលកំពុងដាក់ពាក្យសុំចូលជាសមាជិកអង្គការនេះ ។ បណ្ដាប្រទេស GMS5 សុទ្ធតែជាសមាជិកសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) ដែលបង្កើតបានជាប្លុកពាណិជ្ជកម្មមួយសំរាប់ចរចាធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ជាមួយប្រទេសផ្សេងៗដូចជា ចិន អូស្ត្រាលី ញូវហ្ស៊ីលែន កូរ៉េខាងត្បូង

[២] ឯកសារនេះ ប្រើប្រាស់អក្សរកាត់ GMS សំរាប់ GMS ទាំងមូល ដែលរួមបញ្ចូលទាំងខេត្តយូណាននៃប្រទេសចិន និងប្រើ GMS5 សំរាប់តំបន់ GMS ដោយដកខេត្តយូណានចេញ ។

[៣] សន្ទស្សន៍បើកចំហពាណិជ្ជកម្មនៃបណ្ដាប្រទេសក្នុង GMS មានកំរិតខ្ពស់នៅឆ្នាំ២០០៥ គឺ ១៥៤សំរាប់ថៃ ១៤៧សំរាប់វៀតណាម ១២៥សំរាប់កម្ពុជា ៧៦សំរាប់ឡាវ និង ៧០សំរាប់ចិន ធៀបនឹង ៨២, ៦៤, ៣០, ៣៧ និង ២៧ សំរាប់ប្រទេសទាំងនេះនៅឆ្នាំ១៩៩០ ។

ជប៉ុន ឥណ្ឌា សហគមន៍អឺរ៉ុប និង ស.រ.អា ។ ប្រទេសចិន បានចុះកិច្ចព្រមព្រៀង FTAs ក៏រិតតំបន់ចំនួន ២[៤] និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីចំនួន ៥[៥] ហើយបានចរចាធ្វើ FTAs ជាមួយកូរ៉េខាងត្បូង និងអូស្ត្រាលី ។[៦]

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីស្ទើរតែទាំងអស់ ដែលបានអនុវត្ត រឺចរចា ដោយបណ្តាប្រទេស GMS គឺភាគច្រើនស្តីពីទិដ្ឋភាពសេដ្ឋកិច្ចនៃពាណិជ្ជកម្ម ដោយផ្តោតលើការកាត់បន្ថយ និងការលុបបំបាត់របាំងពន្ធគយ និងមិនមែនពន្ធគយ ពាណិជ្ជកម្មសេវាកម្ម សេរីភាវូបនីយកម្មការធ្វើវិនិយោគ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងការសំរបសំរួលពាណិជ្ជកម្ម ។ នៅក្នុងការចរចា គេបានយកចិត្តទុកដាក់តិចតួចណាស់ ទៅលើបញ្ហាបរិស្ថាន ។ ដោយហេតុថា ចីរភាពបរិស្ថាន ជាសមាសភាគមួយក្នុងចំណោមសមាសភាគទាំងបី (ពីរទៀតគឺ ការអភិវឌ្ឍខាងសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច) នៃការអភិវឌ្ឍប្រកបដោយចីរភាព ហើយ GMS ត្រូវតែដោះស្រាយបញ្ហាបរិស្ថាននានាដែលជាការព្រួយបារម្ភ ឬរឿងសំខាន់ក្នុងតំបន់ ជាពិសេសបញ្ហាពាក់ព័ន្ធនឹងទន្លេមេគង្គ និងធនធានរួមគ្នាផ្សេងទៀត ដូច្នេះកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់ប្រទេស GMS គួរតែមានបទបញ្ញត្តិផ្សេងៗស្តីពីបញ្ហាបរិស្ថាន ។

មកដល់ពេលនេះ មានការស្រាវជ្រាវតិចតួចណាស់ដែលធ្វើឡើងស្តីពីផលប៉ះពាល់ខាងបរិស្ថាននៃ FTAs នៅក្នុង GMS ។ ការសិក្សានេះព្យាយាមបំពេញកង្វះខាតចំណេះដឹងនេះ តាមរយៈការពិនិត្យពីផលប៉ះពាល់ផ្នែកពាណិជ្ជកម្មទៅលើបរិស្ថាន ដែលអាចកើតមាន ដោយឈរលើទស្សនៈរបស់ប្រទេស GMS5 និងរបស់ប្រទេសកម្ពុជា ។ យើងជ្រើសយកតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ធ្វើជាករណីសិក្សា ដើម្បីបង្ហាញពីទំនាក់ទំនងរវាង FTAs និងពាណិជ្ជកម្ម ព្រមទាំងផលប៉ះពាល់ជាយថាហេតុទៅលើបរិស្ថាននៃបម្លាស់ប្តូរលំហូរពាណិជ្ជកម្មដែលផុសចេញពី FTAs ។ ការសិក្សានេះ ពិនិត្យពីលក្ខណៈសំខាន់ៗ និងបទបញ្ញត្តិនៃ ACFTA ព្រមទាំងនិន្នាការទៅអនាគតនៃ ពាណិជ្ជកម្មនៅក្នុងអនុតំបន់នេះ ។ យើងបានបង្កើតម៉ាទ្រីសពាណិជ្ជកម្ម-បរិស្ថានមួយ សំរាប់ប្រើជាឧបករណ៍វាស់វែងប៉ាន់ស្មានពីផលប៉ះពាល់ខាងបរិស្ថាននៃបម្លាស់ប្តូរលំហូរពាណិជ្ជកម្ម (សំរាប់ព័តិមានលំអិត សូមមើលផ្នែកវិធីសាស្ត្រ) ។

## ១.២. គោលដៅនៃការស្រាវជ្រាវ

ការសិក្សានេះ មានគោលដៅចំបងបង្កើនការយល់ដឹងពីផលប៉ះពាល់ខាងបរិស្ថាននៃ FTAs នៅក្នុង GMS ព្រមទាំងជួយបញ្ជ្រាបគំនិតគិតគូរពីការអភិវឌ្ឍប្រកបដោយចីរភាព ទៅក្នុងការចរចា និងការអនុវត្ត FTAs ។ គោលដៅជាក់លាក់រួមមាន: (១) បង្ហាញត្រួសៗពីទំនាក់ទំនងរវាង FTAs ពាណិជ្ជកម្ម និងបរិស្ថាន (២) ពិនិត្យ

---

[៤] កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ី-ប៉ាស៊ីហ្វិក (APTA) ពីមុនហៅថា កិច្ចព្រមព្រៀងក្រុងបាងកក ។

[៥] ចិន-ឈីលី FTA, ចិន-ហុងកុង FTA, ចិន-ម៉ាវ៉ុក FTA, ចិន-ប៉ាគីស្ថាន FTA និង ញូហ្សឺលែន-ចិន FTA ។

[៦] ដកស្រង់ពីមូលដ្ឋានទិន្នន័យកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសំរាប់អាស៊ី នៃមជ្ឈមណ្ឌលសមាហរណកម្មតំបន់អាស៊ី (ARIC): http://www.aric.adb.org ។

ឡើងវិញពីលក្ខណៈសំខាន់ៗនៃ ACFTA ដែលផ្តោតទៅលើតារាងពេលកាត់បន្ថយពន្ធគយ និងមុខព្រួញនៃកិច្ចសហប្រតិបត្តិការ (៣) ពិនិត្យពីការវិវត្តនៃពាណិជ្ជកម្មចិន-GMS5 នៅក្រោម ACFTA និងវាយតំលៃពីផលប៉ះពាល់ខាងបរិស្ថាននៃការវិវត្តនេះ នៅក្នុង GMS ជាពិសេសប្រទេសកម្ពុជា (៤) ស្វែងយល់ពីតំរូវការសំខាន់ៗ និងអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា និងរកមើលថាតើ ACFTA អាចប៉ះពាល់យ៉ាងណាដល់អាទិភាពទាំងនេះ (៥) ផ្តល់ព័ត៌មានដល់អ្នកកសាងគោលនយោបាយ (ជាពិសេសនៅតាមក្រសួងខាងពាណិជ្ជកម្ម និងបរិស្ថាន) អំពីផលប៉ះពាល់ខាងបរិស្ថានជាសក្តានុពលនៃ FTAs ដើម្បីជួយឱ្យពាណិជ្ជកម្ម និងគោលនយោបាយខាងបរិស្ថាន កាន់តែរលូនគ្នាឡើងនៅក្នុងការចរចា FTAs នាពេលអនាគត ។

## ១.៣. ទំហំនៃការសិក្សា

ការសិក្សានេះព្យាយាមបំភ្លឺពីអន្តរកម្មរវាង FTAs ពាណិជ្ជកម្ម និងបរិស្ថាន តាមរយៈករណីសិក្សាមួយលើ ACFTA ។ អន្តរកម្មនេះមានភាពស្មុគស្មាញ ហើយការសិក្សាមានលទ្ធភាពតែមួយកំរិត ក្នុងការពិនិត្យពីបញ្ហាបរិស្ថានទាំងឡាយ ដែលអាចកើតមានឡើងដោយសារពាណិជ្ជកម្ម ជាពិសេសដោយសារ ACFTA បានចុះហត្ថលេខាស្រេចបាច់មិនទាន់យូរពេលប៉ុន្មានទេ ។

ម្យ៉ាងទៀតដោយសារកង្វះទិន្នន័យ ការសិក្សានេះមិនបានវិភាគលំអិតទៅលើទំនាក់ទំនងរវាង FTAs និងបម្លាស់ប្តូរនៅក្នុងលំហូរពាណិជ្ជកម្មទេ ។ ប៉ុន្តែការសិក្សាបានព្យាយាមបង្ហាញពីនិន្នាការដំបូងៗ នៅក្នុងលំហូរពាណិជ្ជកម្ម នៅមុន និងក្រោយពេលមាន ACFTA និងបានតភ្ជាប់លំហូរពាណិជ្ជកម្មយ៉ាងធូររលុង ទៅនឹងការកាត់បន្ថយពន្ធគយ ដើម្បីពន្យល់ពីភាពយឺតនៃពាណិជ្ជកម្មនានា ពាក់ព័ន្ធនឹងបម្លាស់ប្តូរពន្ធគយដែលជាលទ្ធផលនៃ FTA ។ ការសិក្សានេះ ពិនិត្យតែលើពាណិជ្ជកម្មទំនិញប៉ុណ្ណោះ ដោយមិនមើលពីផ្នែកសេវាកម្មទេ ។

ដោយពុំមានទិន្នន័យគ្រប់ជ្រុងជ្រោយទាក់ទងនឹងបរិស្ថាននោះ ការវិភាគពីផលប៉ះពាល់ខាងបរិស្ថានដែលបណ្តាលមកពីពាណិជ្ជកម្ម ត្រូវពឹងផ្អែកជាចំបងលើភាពខ្លាំងក្លានៃការបំពុលដែលបណ្តាលមកពីសកម្មភាពផលិតកម្មដោយផ្តោតជាពិសេសលើផលិតផលសំរេច ។ ការវាយតំលៃបែបគុណភាពដ៏ទូលំទូលាយមួយពីផលប៉ះពាល់ផ្សេងៗទៀតខាងបរិស្ថាន មានរៀបរាប់នៅក្នុងផ្នែកស្តីពីប្រទេសកម្ពុជា ។ ការសិក្សានេះមិនពិនិត្យលើផលប៉ះពាល់ខាងសង្គមកិច្ចដែលកើតចេញពីពាណិជ្ជកម្មទេ ទោះបីជាអ្នកនិពន្ធមើលឃើញថា វាកើតមានពិតមែនក្តី ពីព្រោះរឿងនេះគួរវាយតំលៃតាមការស្រាវជ្រាវមួយថែមទៀត ។

ការសិក្សានេះ មិនមានផ្តល់ជាការសន្និដ្ឋាន ឬអនុសាសន៍ខាងគោលនយោបាយជាក់លាក់ខ្លាំងនោះទេ ហើយដោយសារតែកំហិតនានាដូចបានបញ្ជាក់ខាងលើ លទ្ធផលនៃការសិក្សានេះគួរប្រើការដោយប្រយ័ត្នប្រយែង ។ អ្នកនិពន្ធសង្ឃឹមថា ការសិក្សានេះនឹងជំរុញឱ្យមានការស្រាវជ្រាវថ្មីៗទៀត ដើម្បីវាយតំលៃពីអន្តរកម្មដ៏ស្មុគស្មាញរវាង FTAs ពាណិជ្ជកម្ម និងបរិស្ថាន នៅក្នុង GMS ។

## ១.៤. រចនាសម្ព័ន្ធ

ជំពូក ២ រៀបរាប់ដោយសង្ខេបពីការជជែកវែកញែកស្តីពីពាណិជ្ជកម្ម និងបរិស្ថាន ដោយផ្តោតជាពិសេសលើទិដ្ឋភាព ៣ គឺ ១) បទបញ្ញត្តិច្បាប់ខាងបរិស្ថាន ការប្រកួតប្រជែង និងការផ្លាស់ប្តូរទីតាំងនៃឧស្សាហកម្ម ២) កំណើនសេដ្ឋកិច្ច និងបរិស្ថាន ៣) សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថាន ។ ជំពូក ៣ ពណ៌នាពីវិធីសាស្ត្រប្រើប្រាស់សំរាប់វាស់វែងផលប៉ះពាល់នៃពាណិជ្ជកម្មអន្តរជាតិទៅលើបរិស្ថាន (ជាពិសេសកំរិតខ្លាំងនៃការបំពុល) នៅក្នុង GMS (ទូទៅ) និងនៅក្នុងប្រទេសកម្ពុជា ។ ជំពូក ៤ ពិនិត្យពីលក្ខណៈផ្សេងៗនៃ ACFTA និងផលប៉ះពាល់ដែលអាចកើតមានទៅលើពាណិជ្ជកម្ម និងបរិស្ថាននៅក្នុង GMS ។ ផ្នែកនេះចែកជាពីរចំណែកគឺ ១-ការពិនិត្យជាទូទៅ ពី ACFTA ដោយមានការពិភាក្សាពីការវិវត្តនៅក្នុងប្រវត្តិសាស្ត្រ ហេតុផល និងលក្ខណៈសំខាន់ៗរបស់វា និង ២-ការពិភាក្សាពីពាណិជ្ជកម្មរវាងប្រទេសចិន និង GMS5 ព្រមទាំងផលប៉ះពាល់ទៅលើការបំពុលបរិស្ថាន ។ ជំពូក ៥ ពិនិត្យពីប្រទេសកម្ពុជា ដោយសិក្សាស្រាវជ្រាវពីផលប៉ះពាល់ខាងបរិស្ថានដែលកើតពីពាណិជ្ជកម្មរវាងកម្ពុជា និងចិន នៅក្រោម ACFTA និងពិនិត្យពីតំរូវការ និងអាទិភាពផ្សេងៗរបស់កម្ពុជា ក្នុងការរក្សាចីរភាពធនធានធម្មជាតិ និងបរិស្ថាន ។ ជំពូក ៦ ផ្តល់ការសន្និដ្ឋាន និងការពិភាក្សាពីគោលនយោបាយយ៉ាងសង្ខេប ។

## ជំពូក ២

# ការពិនិត្យជាទូទៅជុំវិញការជជែកដេញដោលពីពាណិជ្ជកម្ម និងបរិស្ថាន

ការសិក្សាអំពីពាណិជ្ជកម្ម និងផលប៉ះពាល់ទៅលើបរិស្ថាន បានលេចឡើងក្នុងលក្ខណៈប្រៀបធៀបនាពេលថ្មីៗនេះ ។ ចាប់តាំងពីអំឡុងឆ្នាំ១៩៧០ ការព្រួយបារម្ភកាន់តែខ្លាំងចំពោះការធ្លាក់ចុះនៃបរិស្ថាន ដែលបណ្តាលមកពីការរីកលូតលាស់ឆាប់រហ័សនៃវិស័យឧស្សាហកម្ម កំណើនសេដ្ឋកិច្ច និងសាកលភាវូបនីយកម្ម បានជំរុញឱ្យអ្នកវិភាគផ្តល់ជាអនុសាសន៍ដើម្បីបញ្ច្រាបការយល់ដឹកពីបញ្ហាបរិស្ថាន ទៅក្នុង កិច្ចការពាណិជ្ជកម្មផ្សេងៗ ។ ទោះយ៉ាងនេះក្តី បញ្ហាទាំងនេះ មិនត្រូវបានបញ្ច្រាបដោយប្រសិទ្ធភាពឡើយ ហើយបញ្ហានេះនាំឱ្យមានការជជែកដេញដោលពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថានកាន់តែច្រើន-ចាប់តាំងពីផលប៉ះពាល់នៃបទបញ្ញត្តិបរិស្ថាន ទៅលើពាណិជ្ជកម្ម រហូតដល់ឥទ្ធិពលនៃកំណើន និងសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើបរិស្ថាន ។ ផ្នែកនេះពិនិត្យឡើងវិញលើការជជែកដេញដោលពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថាន ដោយផ្តោតលើតថភាពសំខាន់បីយ៉ាងក្នុងការជជែកដេញដោលជាទូទៅគឺៈ ១) បទបញ្ញត្តិបរិស្ថាន ការប្រកួតប្រជែង និងការផ្លាស់ប្តូរទីតាំងឧស្សាហកម្ម ឬ "សម្មតិកម្មពីជំរកនៃការបំពុល" (pollution haven hypothesis) ។ ២) កំណើនសេដ្ឋកិច្ច និងបរិស្ថាន ។ ៣) សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថាន ។ ការពិនិត្យឡើងវិញនេះ នឹងមិនពិភាក្សាពីវិធីសាស្ត្រសិក្សាផ្សេងៗទេ ប៉ុន្តែព្យាយាមពន្យល់ពីរបកគំហើញសំខាន់ៗ ទាំងផ្នែកគាំទ្រ និងផ្នែកប្រឆាំងនឹងសម្មតិកម្ម ស្តីពីពាណិជ្ជកម្ម និងបរិស្ថាន ។

## ២.១. បទបញ្ញត្តិបរិស្ថាន ការប្រកួតប្រជែង និងការផ្លាស់ប្តូរទីតាំងឧស្សាហកម្ម

### ២.១.១ តើបទបញ្ញត្តិបរិស្ថានតឹងរ៉ឹង ប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ?

គោលនយោបាយបរិស្ថាន អាចប៉ះពាល់ដល់ចំណាយផលិតកម្ម និងការប្រកួតប្រជែងផងដែរ ។ ការងារជាទ្រឹស្តីនេះ ដាក់បញ្ចូលការចំណាយខាងបរិស្ថាន ទៅក្នុងមុខងារផលិតកម្ម[៧] និងប៉ាន់ស្មានពីផលប៉ះពាល់នៃការចំណាយខាងបរិស្ថាននេះទៅលើការប្រកួតប្រជែង ។ ការងារផ្នែកលើការពិសោធមួយចំនួនដែលធ្វើឡើង ដើម្បីសាកល្បងសម្មតិកម្មនេះ បានបង្ហាញលទ្ធផលចំរុះផ្សេងៗគ្នា ។ លទ្ធផលខ្លះ គាំទ្រដល់ការរិះគន់ថា គោលនយោបាយបរិស្ថាន បានបង្កើនចំណាយផលិតកម្មយ៉ាងច្រើន ដូចនេះ វាកាត់បន្ថយការប្រកួតប្រជែង ។ លទ្ធផលខ្លះទៀត អះអាងថា ការចំណាយខាងបរិស្ថាន ដើរតួនាទីតូចតាចបើធៀបនឹងកត្តាដទៃទៀត ក្នុងការកំណត់ពីឧត្តមភាពប្រៀបធៀប និងការប្រកួតប្រជែង ។

[៧] ការចំណាយផលិតកម្ម ជាប់ទាក់ទងនឹងការចំណាយលើធាតុចូលជាច្រើនរួមមានទាំងពលកម្ម មូលធន និងបច្ចេកវិទ្យា ។ ក្នុង ករណីនេះ ការចំណាយប្រតិបត្តិតាមស្តង់ដារបរិស្ថាន បានត្រូវបញ្ចូលទៅក្នុងការចំណាយផលិតកម្ម ។

ការសិក្សាថ្មីៗ ដែលអង្កេតលើផលប៉ះពាល់នៃបទបញ្ញត្តិបរិស្ថានទៅលើការប្រកួតប្រជែង មាននៅក្នុងស្នាដៃរបស់ Siebert (1974), Pethig (1976) និង McGuire (1982) ។ លទ្ធផលផ្អែកលើការពិសោធរបស់ពួកគេ បានបង្ហាញពីការសន្និដ្ឋានជាទូទៅថា ស្តង់ដារបរិស្ថានតឹងរ៉ឹង ធ្វើឱ្យស្ថានភាពប្រកួតប្រជែងរបស់ប្រទេសចុះទន់ខ្សោយក្នុងវិស័យឧស្សាហកម្មអតិផលដែលមានការបំពុល និងកាត់បន្ថយការនាំចេញរបស់ឧស្សាហកម្មទាំងនេះ ។ អ្នកនិពន្ធ Lucas, Wheeler និង Hettige (1992) បានព្យាយាមសិក្សាសាកល្បងជំនួសកន្លែងសម្មតិកម្មពីមុន ដោយប្រើការវាយតំលៃពីមួយឆ្នាំទៅមួយឆ្នាំនៃកំរិតបំពុលដោយផលិតកម្ម នៅអំឡុងឆ្នាំ១៩៦០-៨៨ លើគំរូតាងដ៏ធំមួយនៃប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ។ អ្នកនិពន្ធទាំងបីខាងលើរកឃើញថា កំរិតបំពុលនៅក្នុងប្រទេសដែលមានចំណូលទាប (ដែលមានស្តង់ដារបរិស្ថានទាប) មានកំរិតខ្ពស់ជាង បើធៀបនឹងប្រទេសដទៃ ដោយសារប្រទេសទាំងនេះ មានជំនាញខាងធ្វើសកម្មភាពបំពុលខ្លាំងក្លា ។ អ្នកនិពន្ធ Low និង Yeats (1992) ដោយផ្អែកលើកំរិតបំពុលដោយពាណិជ្ជកម្មរវាងប៉ែកខាងជើង និងខាងត្បូង បានរកឃើញដែរថា ប៉ែកខាងត្បូងនាំចេញផលិតផលកខ្វក់ច្រើនជាង បើធៀបនឹងផលិតផលរបស់ពួកប៉ែកខាងជើង ។

ទោះយ៉ាងនេះក្តី ការសិក្សាផ្អែកលើការពិសោធផ្សេងទៀត មិនបានរកឃើញភស្តុតាងច្បាស់លាស់ណាមួយដែលថា បទបញ្ញត្តិបរិស្ថាន មានផលប៉ះពាល់លើការប្រកួតប្រជែងទេ (OECD 1993; Tobey 1990; Walter 1973) ។ ការសិក្សាទាំងនេះ បានប៉ាន់ស្មានថា ការកាត់បន្ថយចំណាយនៅក្នុងប្រទេសអភិវឌ្ឍន៍ មានក្នុងកំរិត ១-៣% នៃចំណាយសរុប បង្ហាញថាឥទ្ធិពលលើតំលៃ ចំពោះបទបញ្ញត្តិបរិស្ថាន មិនសូវសំខាន់នោះទេ ។ មតិជំទាស់មួយចំនួនទៀតលើកឡើងថា បទបញ្ញត្តិបរិស្ថានតឹងរ៉ឹង ធ្វើឱ្យក្រុមហ៊ុនមួយចំនួនប្រើប្រាស់បច្ចេកវិទ្យាកាន់តែទំនើបក្នុងផលិតកម្ម ហើយជំរុញឱ្យមានការកែប្រែការស្រាវជ្រាវ និងការអភិវឌ្ឍ ឆ្ពោះទៅរកភាពសមស្របល្អខាងបរិស្ថាន ការបង្កើនផលិតភាពសរុប និងការពង្រីកការអនុវត្ត ។ មតិនេះ ត្រូវបានគេដឹងលឺជាទូទៅថា ជាសម្មតិកម្មរបស់ Porter ។ Porter និង van der Linde (1995) បានវែកញែកថា អ្នកធ្វើគោលនយោបាយថ្នាក់ដឹកនាំអាជីវកម្ម និងបរិស្ថានវិទូ បានផ្តោតលើឥទ្ធិពលនៃការចំណាយដែលមិនមានការប្រែប្រួលនៃបទបញ្ញត្តិបរិស្ថាន ហើយពួកគេទាំងនោះ មិនបានអើពើពីការប៉ះប៉ូវសំខាន់ៗខាងផលិតភាព ដែលបានពីការកែប្រែកើតឡើងពីបទបញ្ញត្តិទាំងនោះទេ ។ អ្នកនិពន្ធទាំងពីរនេះ បានលើកឡើងថា បទបញ្ញត្តិបរិស្ថានដែលបង្កើតស្តង់ដារបរិស្ថានត្រឹមត្រូវមួយចំនួនអាចនាំទៅរកវិធីសាស្ត្រថ្មីដែលអាចបន្ថយតំលៃផលិតផល និងធ្វើឱ្យមានភាពស៊ីគ្នានៃគុណភាពផលិតផលល្អប្រសើរឡើង និងបង្កើនទ្រព្យផលិតភាពធនធាន ។ ជាចុងបញ្ចប់ ការលើកស្ទួយទាំងនេះ ធ្វើឱ្យក្រុមហ៊ុននានាកាន់តែមានលក្ខណៈប្រកួត ប្រជែងខ្លាំងឡើង មិនមែនបន្ថយកំលាំងប្រកួតប្រជែងនោះទេ ។

ក្នុងន័យគាំទ្រសម្មតិកម្មរបស់ Porter នោះ Berman និង Bui (1998) បានពិនិត្យពីឥទ្ធិពលនៃបទបញ្ញត្តិដើម្បីរក្សាគុណភាពខ្យល់របស់ ស.រ.អា ទៅលើផលិតភាពរបស់រោងចក្រស្លប្រេងកាតមួយចំនួនពីឆ្នាំ១៩៧៧-១៩៩៣ ហើយបានរកឃើញថា រោងចក្រស្លប្រេងកាត ដែលស្ថិតនៅក្នុងតំបន់មានបទបញ្ញត្តិតឹងរ៉ឹង ដូចជាកាលីហ្វ័រញ៉ាខាងត្បូងជាដើម មានកំណើនផលិតភាពលឿនជាង រោងចក្រស្លប្រេងកាត ដែលដំណើរការក្រោមបទបញ្ញត្តិមិនសូវតឹងរ៉ឹង ។ បញ្ហានេះ ប្រហែលមកពីរោងចក្រដែលនៅក្រោមបទបញ្ញត្តិតឹងរ៉ឹង ត្រូវបង្ខំឱ្យស្វែងរក

បច្ចេកវិទ្យាថ្មីទំនើបសំរាប់ផែនការវិនិយោគរបស់ពួកគេ ។ Cohen និង Fenn (1997) បានធ្វើការពិនិត្យមើលថា តើការអនុវត្តខាងបរិស្ថានបានល្អ ធ្វើឱ្យខូចខាត ឬជួយដល់កំរិតចំណេញខាតរបស់ក្រុមហ៊ុន ។ ការសិក្សារបស់ពួកគេ ផ្អែកលើទិន្នន័យហិរញ្ញវត្ថុ និងបរិស្ថានរបស់ក្រុមហ៊ុនចំនួន ៥០០ ដែលបានបញ្ចូលក្នុងសន្ទស្សន៍ស្តង់ដារ និងសន្ទស្សន៍អន់ខ្សោយនៃឧស្សាហកម្មចំនួន៨៥ ។ អ្នកនិពន្ធទាំងពីរ បានប្រៀបធៀបពីលទ្ធផលនៃមូលប័ត្រវិនិយោគ ២សំណុំ: សំណុំមូលប័ត្រ "បៃតង" មួយ ដែលបញ្ចូលនូវឧស្សាហកម្មនាំមុខគេខាងបរិស្ថាន (ឧស្សាហកម្មទាំងឡាយដែលមានការអនុវត្តខាងបរិស្ថានល្អជាងឧស្សាហកម្មកំរិតកណ្តាល) និងសំណុំមូលប័ត្រ "ពណ៌ត្នោត" មួយ ដែលដាក់ចូលនូវឧស្សាហកម្មមានការអនុវត្តខាងបរិស្ថាននៅពីក្រោយគេ ។ ពួកគាត់បានរកឃើញថា ក្នុង ៨០% នៃការប្រៀបធៀប មូលប័ត្រ "ពណ៌បៃតង" មានជោគជ័យខាងហិរញ្ញវត្ថុជាងមូលប័ត្រ "ពណ៌ត្នោត" ។ អ្នកនិពន្ធទាំងពីរ ក៏បានសន្និដ្ឋានថា មិនមានភស្តុតាងជាប្រព័ន្ធណាដែលបង្ហាញថា ការអនុវត្តខាងបរិស្ថានបានល្អ នាំទៅរកការថយចុះនៃផលចំណេញឡើយ ។

សរុបមក បញ្ហាព្រួយបារម្ភពីការប្រកួតប្រជែង ដែលបណ្តាលមកពីគោលនយោបាយបរិស្ថាន ហាក់ដូចជាត្រូវបានបំផ្លើសពីការពិត ដោយមិនមានភស្តុតាងផ្អែកលើការពិសោធច្បាស់លាស់ណាមួយ សំរាប់យកមកគាំទ្រដល់ការប្រមើលមើលជាលក្ខណៈទ្រឹស្តីទាំងនេះឡើយ ។ ការប្រកួតប្រជែង ត្រូវបានកំណត់ដោយកត្តាផ្សេងៗរួមមាន ធនធានមនុស្ស បច្ចេកវិទ្យា បរិយាកាសអាជីវកម្ម គុណភាពនៃស្ថាប័នរបស់ប្រទេស ។ល។ ការត្រួតពិនិត្យខាងបរិស្ថាន ទំនងជានឹងជួយបង្កើនចំណាយលើផលិតកម្ម ប៉ុន្តែ បើមើលពីការចំណាយក្នុងផលិតកម្មសរុបនោះ ការចំណាយផ្នែកបរិស្ថាននេះ ហាក់ដូចជាមិនមែនជាបញ្ហាសំខាន់ឡើយ ហើយវាមានផលប៉ះពាល់តិចតួចប៉ុណ្ណោះទៅលើថ្លៃ និងការប្រកួតប្រជែងខាងផលិតកម្ម បើធៀបនឹងកត្តាផ្សេងៗទៀត ។

### ២.១.២. តើបទបញ្ញត្តិបរិស្ថាន ធ្វើឱ្យឧស្សាហកម្មកខ្វក់មួយចំនួន ផ្លាស់ប្តូរទីតាំងឬ?

សំណួរមួយផ្សេងទៀត ដែលបានពិភាក្សាផងដែរគឺ តើបទបញ្ញត្តិបរិស្ថាន ជំរុញឱ្យឧស្សាហកម្មដែលមានកំរិតបំពុលលើសលុបផ្លាស់ទី ទៅកាន់ប្រទេសដែលកំរិតស្តង់ដារបរិស្ថានទាបជាងឬយ៉ាងណា? គេស្គាល់បាតុភូតនេះជាទូទៅថា ជា "សម្មតិកម្មពីជំរកនៃការបំពុល" ។ កត្តានេះពង្រីកនូវកត្តាក្លាសិក២ នៃគំរូពាណិជ្ជកម្ម (មូលធន និងពលកម្ម) ដោយចាត់ទុកការបំពុល ជាកត្តាផលិតកម្មមួយ ។ ការបំពុលលើសលុប ឬមិនសូវមានការបំពុល គឺកំណត់ដោយគោលនយោបាយបរិស្ថាន ដែលឆ្លុះបញ្ចាំងទាំងតំលៃដែលសង្គមផ្តល់ចំពោះបរិស្ថាន និងទាំងលទ្ធភាព និងសមត្ថភាពក្នុងការស្រូបយកការបំពុល ។ គេគិតថា ប្រទេសមួយមានការបំពុលបរិស្ថានលើសលប់ នៅពេលដែលវាមានសមត្ថភាពស្រូបយកការបំពុលក្នុងបរិមាណច្រើន ដែលអាចធ្វើឱ្យប្រទេសនោះប្រឈមមុខនឹងការបំពុលបាន ហើយក៏ទទួលបានឧត្តមភាពប្រៀបធៀបច្រើនពីសកម្មភាពបំពុលលើសលុប ។ សម្មតិកម្មនេះ ប៉ាន់ប្រមាណថា ប្រទេសដែលមិនសូវមានភាពតឹងរ៉ឹងខាងស្តង់ដារបរិស្ថាន នឹងទទួលបានឧត្តមភាពប្រៀបធៀបក្នុងឧស្សាហកម្មដែលមានការបំពុលខ្លាំងក្លា ឬឧស្សាហកម្មកខ្វក់ ហេតុដូច្នេះហើយប្រទេសទាំងនោះ នឹងទាក់ទាញនូវការវិនិយោគក្នុងវិស័យនេះកាន់តែច្រើនឡើង ។ ការសិក្សាជាច្រើន ព្យាយាមសាកល្បងសម្មតិកម្មនេះ ហើយលទ្ធផលផ្អែកលើ

ការពិសោធទាំងនោះ មានការប្រែប្រួល អាស្រ័យលើប្រទេសដែលបានសិក្សា ក្របខ័ណ្ឌពេលវេលានិងវិធីសាស្ត្រនៃការស្រាវជ្រាវ ។ ផ្នែកផ្សេងៗខាងក្រោមនេះ នឹងបង្ហាញពីលទ្ធផលផ្អែកលើការពិសោធ ដែលបានមកពីការសិក្សាគួរឱ្យចាប់អារម្មណ៍មួយចំនួនដែលគាំទ្រ និងមួយចំនួនទៀតប្រឆាំងនឹង "សម្មតិកម្មពីជំរកនៃការបំពុល" ។

## ការសិក្សាដែលគាំទ្រថាឥទ្ធិពលនៃបទបញ្ញត្តិបរិស្ថាន នាំឱ្យមានបម្លាស់ប្តូរទីតាំង

ការសិក្សាជាច្រើន ផ្តល់ភស្តុតាងគាំទ្រលើទស្សនៈថា ឧស្សាហកម្មកខ្វក់ ផ្លាស់ប្តូរទីតាំងដោយសារបទបញ្ញត្តិបរិស្ថានតឹងរ៉ឹង (Low & Yeats 1992; Henderson 1996; Kahn 1997; Gray 1997; Xing & Kolstad 2002; Brunnermeier & Levinson 2004) ។ តួយ៉ាងអ្នកនិពន្ធ Low និង Yeats (1992) បានប្រើរង្វាស់ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA)[៨] ដើម្បីកំណត់ពីទំហំនៃទីតាំងដែលទាក់ទាញឧស្សាហកម្មកខ្វក់ ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលទំនងជាមានស្តង់ដារបរិស្ថានករិតទាប ។ លទ្ធផលនៃការសិក្សាបង្ហាញថា ប្រទេសកំពុងអភិវឌ្ឍន៍ មាននិន្នាការខ្ពស់ជាងក្នុងការអភិវឌ្ឍន៍ជ្រៅនៅក្នុងឧស្សាហកម្មដែលមានការបំពុល ។

Henderson (1996) បានពិនិត្យពីឥទ្ធិពលនៃបទបញ្ញត្តិស្តីពីស្រទាប់អូសូននៅលើផ្ទៃផែនដី ស្តីពីសកម្មភាពសេដ្ឋកិច្ច ហើយលោកបានធ្វើការសាកល្បងថា តើបទបញ្ញត្តិនេះ មានឥទ្ធិពលលើការផ្លាស់ប្តូរទីតាំងរោងចក្រផ្សេងៗនៅក្នុងសហរដ្ឋអាមេរិកឬទេ ។ លោកបានរកឃើញថា មានការថយចុះរោងចក្រដែលមានការបំពុលគួរឱ្យកត់សំគាល់ នៅក្នុងតំបន់នានា ដែលបានប្តូរទំរង់ថាមានស្ថានភាពមិនទាន់សំរេចបានតាមស្តង់ដារ (non-attainment status) ដែលតំរូវឱ្យរោងចក្របំពាក់ឧបករណ៍ផលិតកម្មបៃតង ដើម្បីកាត់បន្ថយការបញ្ចេញសារធាតុពុល ។ ផ្ទុយមកវិញ រោងចក្រដែលមានការបំពុលបរិស្ថាន មានការកើនឡើងច្រើននៅក្នុងបណ្តាប្រទេសដែលមានស្ថានភាពសំរេច (attainment status) ។ ឧស្សាហកម្មបំពុលបរិស្ថាន មានការរីករាលដាលដោយរំកិលពីតំបន់ដែលមានស្ថានភាពមិនទាន់សំរេចបាន (ដែលមានការបំពុល) ទៅតំបន់ដែលមានស្ថានភាពសំរេចបាន (មានការបំពុលតិចតួចពីដំបូង) ។ ការរកឃើញនេះ ត្រូវបានគាំទ្រដោយអ្នកនិពន្ធ Kahn (1997) ដែលលោកបានលើកឡើងថា ការធ្វើឱ្យប្រសើរឡើង គុណភាពខ្យល់នៅតំបន់ដែលរងការបំពុល បានអនុវត្តសំរេចមួយផ្នែក តាមរយៈការផ្លាស់ប្តូរទីតាំងរបស់ឧស្សាហកម្មដែលបំពុលបរិស្ថាន ដោយសារករិតខុសគ្នានៃបទបញ្ញត្តិបរិស្ថាន ។

Gray (1997) ព្យាយាមធ្វើការសាកល្បងថា តើភាពខុសគ្នាតាមតំបន់ផ្សេងៗនៅ ស.រ.អា លើបទបញ្ញត្តិស្តីពីការបំពុល មានផលប៉ះពាល់ដល់ការផ្លាស់ប្តូរទីតាំងនៃសកម្មភាពផលិតកម្មឬទេ ។ គាត់បានរកឃើញចំណងទាក់ទងសំខាន់មួយរវាងករិតនៃភាពតឹងរ៉ឹងនៃបទបញ្ញត្តិបរិស្ថាន និងចំនួនរោងចក្របើកថ្មី -គឺរដ្ឋដែលមាន

---

[៨] ឧត្តមភាពប្រៀបធៀបដោយចំហ ជាការវាស់វែងពីការអនុវត្តការប្រកួតប្រជែងជាលក្ខណៈប្រៀបធៀបនៃការនាំចេញផលិតផល ឬប្រភេទទំនិញជាក់លាក់មួយរបស់ប្រទេសណាមួយ ។ គេគណនាវា ដោយយកចំណែកនៃប្រទេសនៅក្នុងការនាំចេញ ផលិតផលជាក់លាក់មួយរបស់ក្នុងពិភពលោក ទៅចែកនឹងចំណែកប្រទេសនោះនៅក្នុងពាណិជ្ជកម្មពិភពលោកសរុប ។ ផលិតផលដែលមានសមាភាគធំជាង ១ ត្រូវបានគិតថាជាសូចនាករនៃឧត្តមភាពប្រៀបធៀបរបស់ប្រទេសនោះធៀបនឹងផលិតផលដែលមានសមាភាគតូចជាង ១ ។

បទបញ្ញត្តិបរិស្ថានតឹងរ៉ឹងកាន់តែច្រើន នោះចំនួនរោងចក្រផលិតកម្មថ្មីនៅក្នុងរដ្ឋទាំងនោះ កាន់តែតិចទៅវិញ ។ Xing និង Kolstad (1998) បានបញ្ជាក់លើលទ្ធផលទាំងនេះ ដោយពួកគាត់បានពិនិត្យមើលលើវិនិយោគផ្ទាល់ពីបរទេស (FDI) នៃឧស្សាហកម្មមួយចំនួនរបស់ ស.រ.អា រួមមានទាំងឧស្សាហកម្មដែលចំណាយខ្ពស់ ទៅលើការត្រួតពិនិត្យការបំពុល (ផ្នែកធាតុគីមី និងលោហៈចំបង។) និងឧស្សាហកម្មដែលចំណាយទាបលើការត្រួតពិនិត្យការបំពុល (ផ្នែកគ្រឿងម៉ាស៊ីនប្រើ និងមិនប្រើថាមពលអគ្គិសនី សំភារៈដឹកជញ្ជូន និងផលិតផលអាហារ) ដើម្បីវាយតំលៃពីឥទ្ធិពលនៃគោលនយោបាយបរិស្ថានតឹងរ៉ឹង ទៅលើការបោះទីតាំងនៃឧស្សាហកម្មដែលមានការបំពុល ។ ការវិភាគជាលក្ខណៈស្ថិតិបង្ហាញថា ភាពធូររលុងនៃបទបញ្ញត្តិបរិស្ថាននៅក្នុងប្រទេសមួយ គឺជាកត្តាកំណត់សំខាន់មួយចំពោះ FDI ពី ស.រ.អា ក្នុងឧស្សាហកម្មដែលមានការបំពុលលើសលប់ ហើយវាមិនសំខាន់ឡើយ ចំពោះឧស្សាហកម្មដែលមានការបំពុលតិចតួចនោះ ។ លទ្ធផលនេះ ត្រូវបានអះអាងបញ្ជាក់ដោយអ្នកស្រាវជ្រាវដដែលនេះ (Xing & Kolstad, 2002) តាមរយៈការសិក្សាថ្មីៗជាច្រើនរបស់ពួកគាត់ ដែលពិនិត្យមើលពីផលប៉ះពាល់នៃបទបញ្ញត្តិបរិស្ថាន ទៅលើចលនាមូលធនក្នុងឧស្សាហកម្មដែលមានការបំពុលនៅសហរដ្ឋអាមេរិក ។

Brunnermeier និង Levinson (2004) បានសិក្សាទៅលើឯកសារមានស្រាប់នានាស្តីពីសម្មតិកម្មពីជំរកនៃការបំពុល រើកញែកពីការសិក្សាថ្មីនេះ ដែលគាំទ្រចំពោះឥទ្ធិពលនៃបទបញ្ញត្តិបរិស្ថានដែលនាំឱ្យមានការផ្លាស់ប្តូរទីតាំងឧស្សាហកម្ម ។ ការសិក្សាទាំងនោះ បានប្រើទិន្នន័យជាក្រុមដើម្បីត្រួតពិនិត្យពីភាពមិនស្មើសាច់ដែលមិនបានអង្កេត ឬបានប្រើប្រាស់ឧបករណ៍ដើម្បីត្រួតពិនិត្យពីភាពគ្មានមូលហេតុជាក់ស្តែង ហើយបានរកឃើញពីឥទ្ធិពលសំខាន់ៗយ៉ាងច្រើនលើជំរកនៃការបំពុល ។

## ការសិក្សាដែលមិនបានរកឃើញថា បទបញ្ញត្តិបរិស្ថាន ជះឥទ្ធិពលទៅលើបម្លាស់ប្តូរទីតាំង

ការសិក្សាមួយចំនួន មិនបានរកឃើញភស្តុតាងណាដែលគាំទ្រដល់ទ្រឹស្តីនៃការផ្លាស់ប្តូរទីតាំងឧស្សាហកម្មកខ្វក់បណ្តាលមកពីបទបញ្ញត្តិបរិស្ថានតឹងរ៉ឹងនោះទេ (Duerksen et al. 1980; Walter 1982; Beghin et al. 1997a; Eskeland et al. 1997) ។ ការសន្និដ្ឋានបែបនេះ ផ្អែកលើការរើកញែកថា បន្ទុកចំណាយលើការត្រួតពិនិត្យ បរិស្ថានមិនមានអ្វីធំដុំទេ ប៉ុន្តែមានកត្តាផ្សេងៗទៀតជាច្រើន (រួមមាន ធនធានធម្មជាតិ ទំហំទីផ្សារ ច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ ធនធានមនុស្ស និងការលើកទឹកចិត្តផ្នែកវិនិយោគ) ដែលមានផលប៉ះពាល់ខ្លាំងដល់ធ្វើការសំរេចចិត្តវិនិយោគ ។ ការសិក្សាមុនៗរបស់ Duerksen et al. (1980) បានប្រើប្រាស់ទិន្នន័យពាណិជ្ជកម្ម និងការវិនិយោគដើម្បីកំណត់ថាតើភាពខុសគ្នាក្នុងការចំណាយលើការត្រួតពិនិត្យបរិស្ថាន នាំឱ្យឧស្សាហកម្មមួយចំនួនចាកចេញពី ស.រ.អា ទៅកាន់បណ្តាប្រទេសលូតលាស់តិចជាងគេមែនឬទេ ហើយបានរកឃើញថា ប្រទេសដែលទទួលបានការវិនិយោគពីបរទេសច្រើនបំផុតលើផ្នែកដែលពោរពេញដោយការបំពុល ដូចជា ផ្នែកសារធាតុគីមី ក្រដាស លោហៈ និងស្ពាន់ឥន្ធនៈជាដើមគឺ ប្រទេសឧស្សាហកម្មដទៃផ្សេងទៀតដែលមិនមែនជាប្រទេសលូតលាស់តិចជាងគេឡើយ ។ គាត់រកឃើញទៀតថា ចំណែកនៃការវិនិយោគផ្ទាល់របស់សហរដ្ឋអាមេរិកនៅបរទេសលើផ្នែកឧស្សាហកម្ម ដែលពោរពេញដោយការបំពុលនៅក្នុងបណ្តាប្រទេសលូតលាស់តិចជាងគេ មិនមានការកើនឡើងច្រើនទេ បើធៀបនឹង

ប្រទេសអភិវឌ្ឍន៍ដទៃទៀត ។ ការសិក្សានេះសន្និដ្ឋានថា មិនមានភស្តុតាងអ្វីស្ដីពីការរីករាលដាលនៃបម្លាស់ប្ដូរទីតាំងឧស្សាហកម្មរបស់សហរដ្ឋអាមេរិក ទៅរកដែនជំរកនៃការបំពុលឡើយ ។

Walter (1982), Repetto (1995), Albrecht (1998) និង Eskeland et al. (1997) បានសិក្សាស្រដៀងគ្នាដោយផ្អែកលើការវិភាគទិន្នន័យវិនិយោគ ។ ឧទាហរណ៍ Walter (1982) បានពិនិត្យពីនិន្នាការក្នុងការវិនិយោគផ្ទាល់ពីបរទេស ទាំងទៅលើឧស្សាហកម្មធំរុះ និងគោលដៅរបស់ក្រុមហ៊ុនមកពីតំបន់អឺរ៉ុបខាងលិច ប្រទេសជប៉ុន និងសហរដ្ឋអាមេរិកនៅអំឡុងឆ្នាំ១៩៧០-៧៨ ។ គាត់បានរកឃើញថា ទោះបីជាផលិតកម្មពីបរទេសខាងឧស្សាហកម្មដែលពោរពេញដោយការបំពុល មានចំនួនច្រើនក៏ដោយ ក៏មានភស្តុតាងតិចតួចណាស់ដែលបង្ហាញថាការចំណាយលើការត្រួតពិនិត្យបរិស្ថាន មានផលប៉ះពាល់លើតួលេខនៃផលិតកម្មនេះ ។ ជាលទ្ធផល គាត់សន្និដ្ឋានថា មិនមានភស្តុតាងដែលគាំទ្រថា វិនិយោគផ្ទាល់ពីបរទេស (FDI) មាននិន្នាការងាកទៅរកប្រទេស ដែលមានកំរិតស្តង់ដារធូររលុងជាងនោះទេ ។

ប្រហាក់ប្រហែលនេះដែរ Repetto (1995) បានកត់សំគាល់ថា ទោះបីប្រទេសសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ និងប្រទេសសេដ្ឋកិច្ចអន្តរកាល ទទួលបាន FDI ពី ស.រ.អា ចំនួន ៤៥% ក៏ដោយ ក៏ចំណែកនៃឧស្សាហកម្មដែលងាយពាក់ព័ន្ធនឹងបរិស្ថានរបស់ពួកគេ (ឥន្ទនៈ និងឧស្ម័ន, ធាតុគីមី និងលោហៈធំបង៧ ឬលោហៈ កែច្នៃ) មានតិចតួចប៉ុណ្ណោះ ។ ចំពោះការវិនិយោគលើផ្នែកនេះ ប្រទេសទាំងពីរប្រភេទខាងលើទទួលបានតែ ៥% ប៉ុណ្ណោះ ធៀបនឹង ២៤% ដែលទទួលបានដោយប្រទេសអភិវឌ្ឍន៍ ។ លោកបានសន្និដ្ឋានថា "ការនាំចេញឧស្សាហកម្មកខ្វក់របស់ប្រទេសអភិវឌ្ឍន៍ ហាក់ដូចជាការដោះដូរក្នុងចំណោមពួកគេប៉ុណ្ណោះគឺ ពួកគេនាំឧស្សាហកម្មនោះពីប្រទេសអភិវឌ្ឍន៍មួយទៅកាន់ប្រទេសអភិវឌ្ឍន៍ផ្សេងទៀត ដោយមិនមែននាំទៅកាន់ប្រទេសសេដ្ឋកិច្ចលូតលាស់តិចតួចនោះឡើយ" (Repetto 1995, មានដកស្រង់មកប្រើនៅក្នុង OECD 1997: 10) ។

សេចក្តីសន្និដ្ឋាននេះ ទទួលបានការអះអាងបន្ថែមពី Albrecht (1998) ដែលបានវាយតំលៃថា តើលំហូរចេញនៃ FDI ពី ស.រ.អា ប្រមូលផ្តុំលើឧស្សាហកម្មកខ្វក់មែនឬទេ និងតើលំហូរចូលវិញ ប្រមូលផ្តុំលើឧស្សាហកម្មស្អាតល្អមែនឬទេ ។ ជាក់ស្តែង គាត់បានរកឃើញថា វាមានលក្ខណៈផ្ទុយមកវិញគឺ លំហូរចេញនៃ FDI មានការលូតលាស់លឿន ចំពោះឧស្សាកម្មស្អាតល្អ រីឯលំហូរចូល FDI លូតលាស់លឿនចំពោះឧស្សាហកម្មកខ្វក់ ។ យើងអាចនិយាយមួយបែបទៀតថា ស.រ.អា ហាក់ដូចកំពុងនាំចូលឧស្សាហកម្មកខ្វក់ ច្រើនជាងវានាំចេញទៅវិញ ។ Eskeland et at. (1997) បានធ្វើការសិក្សាមួយទៀត ដែលអង្កេតពីគំរូនៃ FDI ដើម្បីវាយតំលៃពីការប្រមូលផ្តុំនៃឧស្សាហកម្មកខ្វក់ ។ ការសិក្សានេះ ពិនិត្យលើការវិនិយោគពី ស.រ.អា ទៅក្នុងប្រទេសម៉ិកស៊ិច វេណេហ្ស៊ូអេឡា កូដឺវ័រ និងម៉ូរ៉ូកូ នៅអំឡុងឆ្នាំ១៩៨០ ហើយវាមិនបានរកឃើញភស្តុតាងណាដែលបង្ហាញថា ការវិនិយោគក្នុងប្រទេសទាំងនេះ មានទំនោរទៅរកផ្នែកមានការបំពុលឡើយ ។

សរុបមក បទបញ្ញត្តិបរិស្ថាន ហាក់ដូចជាមានឥទ្ធិពលក្នុងកំរិតតិចតួច ទៅលើការសំរេចចិត្តផ្លាស់ប្តូរទីតាំងនៃវិស័យភាគច្រើន ព្រោះការចំណាយប្រតិបត្តិតាមបទបញ្ញត្តិនេះ មានកំរិតតូចដែលមិនអាចចាត់ទុកជាកត្តាសំខាន់

ឡើយ ។ នេះក៏ព្រោះតែកត្តាផ្សេងៗ ដូចជា អំណោយផលខាងធនធាន ទំហំទីផ្សារ ច្រកចូលទៅកាន់ទីផ្សារ ធនធានមនុស្ស និងស្ថានភាពវិនិយោគសរុប មានឥទ្ធិពលខ្លាំងលើការសំរេចចិត្តផ្លាស់ប្តូរទីតាំងជាអន្តរជាតិ ។ FDI អាចស្ថិតក្រោមគោលបំណងស្វែងរកធនធាន ស្វែងរកទីផ្សារ ឬរកប្រសិទ្ធភាព ហើយផលប្រយោជន៍ផ្សេងទៀតរបស់ក្រុមហ៊ុន អាចកំណត់ពីកន្លែងដែលផលិតកម្មត្រូវតាំងនៅ ។ យ៉ាងណាក្តី នៅក្នុងផ្នែកមួយចំនួន ជាពិសេសផ្នែកដែលពាក់ព័ន្ធនឹងថាមពល ដូចជា ផលិតកម្មស៊ីម៉ង់ត៍ ដែក និងដែកថែប ជាដើម បទបញ្ញត្តិបរិស្ថានអាចដើរតួនាទីមួយក្នុងការជ្រើសរើសបោះទីតាំងផលិតកម្ម ប៉ុន្តែវាជាកត្តាតូចមួយ បើធៀបនឹងកត្តាផ្សេងទៀត ។

## ២.២. កំណើនសេដ្ឋកិច្ច និងបរិស្ថាន

បញ្ហាមួយទៀតដែលតែងត្រូវបានយកមកពិភាក្សានៅក្នុងទ្រឹស្តីធ្វើជំនួញ និងបរិស្ថាននោះ គឺ បញ្ហាផ្តោតលើផលវិបាកនៃកំណើនសេដ្ឋកិច្ច ទៅលើគុណភាពបរិស្ថាន ។ គេឃើញមានកំណើនក្នុងការស្រាវជ្រាវ និងរិះគន់ពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងបរិស្ថាន ដោយមានការកត់សំគាល់ថា បរិស្ថានមានការខូចខាតជាបណ្តើរៗស្របជាមួយនឹងកំណើនយ៉ាងលឿននៃសេដ្ឋកិច្ចពិភពលោក ។ ទស្សនាទានជាទ្រឹស្តីចំបងមួយដែលជះឥទ្ធិពលខ្លាំងលើការរិះគន់នេះ គឺខ្សែកោងខាងបរិស្ថាន ឈ្មោះខ្សែកោង Kuznets (EKC) (Grossman & Krueger 1991) ។

***ក្រាហ្វិក ១: ខ្សែកោងបរិស្ថាន Kuznets (EKC)***




EKC ពង្រីកនូវគោលគំនិតនៃខ្សែកោង Kuznets ដូចបានបង្ហាញក្នុងក្រាហ្វិក ១ ។ EKC ពណ៌នាពីទំនាក់ទំនងរវាងចំណូល និងវិសមភាពតាមខ្សែកោងការអភិវឌ្ឍ ដើម្បីវាស់វែងពីកំរិតគុណភាពបរិស្ថាន ស្របជាមួយនឹងកំណើនប្រាក់ចំណូល ។ ទំនាក់ទំនងរវាងគុណភាពបរិស្ថាន និងចំណូល នៅក្នុង EKC នាំឱ្យមានការទស្សទាយថា ការខូចខាតបរិស្ថាន នឹងកើនឡើងនៅកំរិតចំណូលទាប (ហៅថាការសឹករេចរឹលនៃបរិស្ថាន) រួចឡើងដល់កំរិតខ្ពស់បំផុត (ហៅថាចំណុចរបត់នៃចំណូល) ហើយក៏ធ្លាក់ចុះវិញបន្ទាប់ពីនោះ (ហៅថាភាពប្រសើរឡើងនៃបរិស្ថាន) ។ តក្កវិជ្ជានៃទំនាក់ទំនង EKC គឺនៅដំណាក់កាលដំបូងនៃឧស្សាហូបនីយកម្ម និងការអភិវឌ្ឍចលនាសេដ្ឋកិច្ច មានប្រើប្រាស់ធនធានធម្មជាតិយ៉ាងច្រើន និងបច្ចេកវិទ្យាកខ្វក់មួយចំនួន ក្នុងសកម្មភាពផលិតកម្ម ដែលបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាន ។ នៅពេលដែលគុណភាពនៃការរស់នៅមានការវិវត្តដែលបណ្តាលមកពីការអភិវឌ្ឍនោះ

មនុស្សនឹងមានកំណើនតំរូវការនូវសង្គមមួយ ដែលមានភាពស្អិទ្ធស្អាលនឹងបរិស្ថាន ហើយជាលទ្ធផល វានឹងដាក់សម្ពាធលើរដ្ឋាភិបាលឱ្យបង្កើតនូវគោលនយោបាយផ្សេងៗ ដើម្បីធ្វើឱ្យគុណភាពបរិស្ថានល្អប្រសើរឡើង ។

ការសិក្សាផ្អែកលើការពិសោធស្ដីពី EKC ភាគច្រើន ផ្ដោតលើសំណួរពីរគឺ តើមានទំនាក់ទំនងរវាងចំណូល និងការរេចរឹលបរិស្ថាន ដែលអាចបង្ហាញដោយការគ្រលប់ខ្សែកោងទៅជារាងអក្សរ U ឬទេ? ហើយបើមាននោះ តើនៅកំរិតចំណូលណាដែលការរេចរឹលបរិស្ថានចាប់ផ្ដើមថយចុះ? ជាឧទាហរណ៍ Grossman និង Krueger (1995) បានពិនិត្យទំនាក់ទំនងរវាងសូចនាករបរិស្ថានផ្សេងៗ និងកំរិតចំណូលក្នុងមនុស្សម្នាក់ ហើយបានរកឃើញថា កំណើនសេដ្ឋកិច្ចនាំឱ្យមានជំហានដំបូងមួយនៃការរេចរឹលបរិស្ថាន ហើយបន្ទាប់មកវានឹងមានជំហាននៃការវិវត្តមួយតាមពីក្រោយ ។ ចំណុចរបត់នៃការបំពុលផ្សេងៗ មានភាពប្រែប្រួលខុសគ្នា ប៉ុន្តែស្ទើរតែរាល់ករណីទាំងអស់ ពួកវាកើតមានឡើងមុនពេលដែលប្រទេសមួយឈានដល់កំរិតចំណូល ៨០០០ដុល្លារអាមេរិក ក្នុងមនុស្សម្នាក់ ។

បន្ទាប់ពីការសិក្សារបស់ Grossman និង Krueger អ្នកនិពន្ធ Shafik និង Bandopadhyay (1992) បានប៉ាន់ស្មានពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងសូចនាករគុណភាពបរិស្ថានសំខាន់ៗមួយចំនួន ហើយបានរកឃើញទំនាក់ទំនងមួយដែលស៊ីគ្នានឹងការសិក្សាពីមុន ស្ដីពីទំនាក់ទំនងរវាងចំណូល និងសូចនាករគុណភាពបរិស្ថានទាំងឡាយ ។ នៅពេលដែលចំណូលចាប់ផ្ដើមកើនឡើងនោះ ជាដំបូងការបំពុល ដូចជា ឧស្ម័នស៊ុលផួឌីអុកស៊ីត និងបញ្ហាធូលីក្នុងខ្យល់ មានការកើនឡើង បន្ទាប់មកវាថយចុះវិញនៅពេលដែលសេដ្ឋកិច្ចឡើងដល់កំរិតចំណូលជាក់លាក់មួយ ។

ជាទូទៅ គេរកឃើញ EKC កើតមានក្នុងតំបន់មួយចំនួនដែលរងការបំផ្លិចបំផ្លាញបរិស្ថានដោយសារផលប៉ះពាល់ភ្លាមៗ និងអាចដឹងបាន ដូចជា ការបំពុលខ្យល់ជាដើម ប៉ុន្តែខ្សែកោងនេះ មិនមានពណ៌នានៅក្នុងតំបន់ដែលរងផលប៉ះពាល់ក្នុងរយៈពេលវែង និងផលប៉ះពាល់ដែលមិនសូវមើលឃើញ ដូចជា កាកសំណល់រឹង ការបាត់បង់ជីវៈចំរុះ និងបម្លាស់ប្ដូរធាតុអាកាសជាដើម ។ លើសពីនេះ បើទោះជា EKC ត្រូវបានគេអង្កេតពីមុនមកក៏ដោយ ក៏វាហាក់ដូចជាឆាប់រហ័សពេកក្នុងការសន្និដ្ឋានថា បញ្ហានៃខ្សែកោងនេះ ត្រូវតែកើតមានឡើងដោយមិនអាចជៀសផុត ឬដោយស្វ័យប្រវត្តិ ។ គោលនយោបាយគាំទ្រដែលត្រឹមត្រូវ (ដែលអាចនាំមកនូវសារៈប្រយោជន៍ខាងសេដ្ឋកិច្ចក្នុងរយៈពេលវែង) អាចផ្លាស់ប្ដូរផលប៉ះពាល់មួយចំនួន ដូចគ្នាដែរនឹងការធ្វើឱ្យបរិស្ថានប្រសើរឡើង ជាមួយនឹងកំណើនប្រាក់ចំណូល ដែលមិនមែនកើតឡើងដោយស្វ័យប្រវត្តិទេ គឺវាផ្អែកលើគោលនយោបាយ និងស្ថាប័នមួយចំនួន ។ គោលនយោបាយ និងស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងមុខងារទីផ្សារ ដើរតួយ៉ាងសំខាន់ក្នុងការធានានូវលក្ខខណ្ឌគ្រប់គ្រាន់ និងស្តង់ដារ សំរាប់ការការពារបរិស្ថានដែលដើរស្របគ្នានឹងសកម្មភាពអភិវឌ្ឍន៍ ។

## ២.៣. សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថាន

សេរីភាវូបនីយកម្មពាណិជ្ជកម្ម អាចបង្កើនបរិមាណពាណិជ្ជកម្ម ពង្រីកសកម្មភាពសេដ្ឋកិច្ច ហើយក៏អាចជះឥទ្ធិពលលើគុណភាពបរិស្ថានផងដែរ ។ ផលប៉ះពាល់នៃសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើបរិស្ថានអាចបំបែកចេញជា ៣ សមាសភាគ ដែលមានអន្តរកម្មលើគ្នាចុះឡើង គឺមានឥទ្ធិពលខាងសមាសភាព ឥទ្ធិពលខាងទំហំ និងឥទ្ធិពលខាងបច្ចេកទេស (Grossman & Krueger 1991) ។

ឥទ្ធិពលខាងសមាសភាព កើតឡើងពីការផ្លាស់ប្តូរនៃឯកទេសនីយកម្ម នៅពេលដែលពាណិជ្ជកម្មមានភាពបើកចំហជាងមុន ។ ប្រទេសមួយនឹងទទួលជំនាញឯកទេសលើ ហើយនិងនាំចេញនូវផលិតផលដែលខ្លួនសំបូរធនធានក្នុងការផលិត ហើយនិងនាំចូលមកវិញនូវផលិតផលដែលមិនសូវមាននៅក្នុងប្រទេសនោះ ។ ទំហំនៃឥទ្ធិពលខាងសមាសភាព ផ្អែកលើកំរិតដែលឧត្តមភាពប្រៀបធៀបរបស់ប្រទេសនោះ វាស្ថិតនៅផ្នែកមានការបំពុលខ្លាំងក្លា ឬផ្នែកមិនសូវមានការបំពុល ។ ឥទ្ធិពលសុទ្ធទៅលើបរិស្ថានក្នុងតំបន់នឹងមានភាពវិជ្ជមាន បើសិនការពង្រីកវិស័យនាំចេញ មានការបំពុលជាមធ្យមតិចជាងវិស័យប្រកួតប្រជែងនឹងការនាំចូលដែលត្រូវរួមចុះ ។ ផ្ទុយមកវិញ ឥទ្ធិពលសុទ្ធនោះនឹងមានភាពអវិជ្ជមាន ប្រសិនបើការពង្រីកវិស័យនាំចេញ មានការបំពុលជាមធ្យមខ្ពស់ជាងវិស័យប្រកួតប្រជែងនឹងការនាំចូលដែលត្រូវរួមចុះ ។

ឥទ្ធិពលខាងទំហំកើតឡើងពីសកម្មភាពសេដ្ឋកិច្ច ដែលកើនឡើងដោយសារសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ សំរាប់មេគុណនៃការបំពុលជាក់លាក់ណាមួយ កំណើនផលិតកម្មតែងធ្វើឱ្យខូចខាតដល់បរិស្ថាន ដូច្នេះឥទ្ធិពលខាងទំហំ វាមានភាពអវិជ្ជមាន ពីព្រោះវាបង្កការបំពុល និងបញ្ចេញសារធាតុពុលបន្ថែមទៀត ។

ឥទ្ធិពលខាងបច្ចេកទេស កើតមាននៅពេលដែលផលិតករចាប់ប្រើបច្ចេកទេសផលិតកម្មមានលក្ខណៈស្អាតជាងមុន មានការបញ្ចេញសារធាតុពុលកំរិតទាបជាងមុន ដែលនាំឱ្យថយចុះការបំពុលគិតក្នុងផលិតផលសំរេចមួយឯកតា ។

បញ្ហាសំខាន់ចំពោះបរិស្ថាន មិនមែនសមាសភាគមួយៗដោយឡែកនោះទេ ប៉ុន្តែគឺលទ្ធផលសុទ្ធនៃឥទ្ធិពលខាងសមាសភាពទំហំ និងបច្ចេកទេស ។ សេរីភាវូបនីយកម្មពាណិជ្ជកម្ម មានផលប៉ះពាល់ជាវិជ្ជមានទៅលើបរិស្ថាន ប្រសិនបើឥទ្ធិពលខាងសមាសភាព និងខាងបច្ចេកទេស ធំលើសឥទ្ធិពលខាងទំហំ ហើយក្នុងករណីផ្ទុយពីនេះវិញនោះ វានឹងមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ។

## សេរីភាវូបនីយកម្មពាណិជ្ជកម្ម ហុចផលវិជ្ជមានលើបរិស្ថាន

ក្នុងចំណោមការសិក្សាផ្អែកលើការពិសោធសំខាន់ៗ ការសិក្សារបស់ Grossman និង Krueger (1991, 1993), Birdsall និង Wheeler (1992), Antweiler et al. (1998) និង Tsai (1999) បានវែកញែកថា សេរីភាវូបនីយកម្មអាចធ្វើឱ្យស្ថានភាព និងគុណភាពបរិស្ថាន ប្រសើរឡើង ។ នៅក្នុងការវាយតំលៃរបស់ពួកគេស្តីពីផលប៉ះពាល់ខាងបរិស្ថាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាមេរិកខាងជើង (NAFTA) Grossman និង Krueger (1993) បានលើកឡើងថា របបពាណិជ្ជកម្មសេរី និងច្រកចូលទូលាយទៅកាន់ទីផ្សារ ស.រ.អា ដ៏ធំ ទំនងជួយបង្កើតកំណើនប្រាក់ចំណូលនៅក្នុងប្រទេសម៉ិកស៊ិច ដែលនឹងនាំឱ្យមានកំណើនសម្ពាធខាងនយោបាយចំពោះការការពារបរិស្ថាន និងដែលជាការល្អចំពោះបរិស្ថាន ។ ពួកគេសន្និដ្ឋានដោយទស្សនៈវិជ្ជមានថា ការបំពុលនឹងថយចុះនៅម៉ិកស៊ិច ដោយសារប្រទេសនេះមានឯកទេសខាងកសិកម្ម និងឧស្សាហកម្មអតិពលកម្ម ដែលប្រើធាតុចូលតិចជាងថាមពល និងបង្កើតកាកសំណល់ពុលក្នុងផលិតផលសំរេចមួយឯកតា ទាបជាងផ្នែកដែលប្រើមូលធនមនុស្ស និងមូលធនទ្រព្យច្រើន ។ Tsai (1999) គាំទ្រដល់លទ្ធផលនេះ ដោយគាត់បានរកឃើញថា ការបញ្ចេញ

សារធាតុពុលក្រោយពេលធ្វើសេរីភាវូបនីយកម្ម វាមានកំរិតទាបជាងនៅមុនពេលធ្វើសេរីភាវូបនីយកម្ម ហើយរឿងនេះបានបញ្ជាក់គាំទ្រដល់ការវែកញែកដែលថា សេរីភាវូបនីយកម្មពាណិជ្ជកម្មនាំឱ្យគុណភាពបរិស្ថានល្អប្រសើរឡើង ។

Birdsall និង Wheeler (1992) បានធ្វើការសិក្សាមួយផ្សេងទៀត ដោយពិនិត្យពីឥទ្ធិពលគោលនយោបាយពាណិជ្ជកម្មទៅលើការបំពុល ។ ការសិក្សានេះបានឥវែកញែកថា សេរីភាវូបនីយកម្មនៃរបបពាណិជ្ជកម្ម និងកំណើនវិនិយោគបរទេសនៅតំបន់អាមេរិកឡាទីន មិនមានពាក់ព័ន្ធនឹងការវិវត្តឧស្សាហកម្មដែលមានកំរិតបំពុលលើសលប់នោះទេ ។ ដោយផ្អែកលើករណីសិក្សាមួយចំនួន និងភស្តុតាងខាងសេដ្ឋកិច្ចមាត្រសាស្ត្រនោះ អ្នកនិពន្ធទាំងពីរបានសន្និដ្ឋានថា ប្រទេសដែលមានរបបការពារសេដ្ឋកិច្ច ច្រើនតែអនុគ្រោះដល់ឧស្សាហកម្មមានកំរិតបំពុលលើសលប់ រីឯការបើកចំហសេដ្ឋកិច្ច តែងលើកទឹកចិត្តដល់ឧស្សាហកម្មដែលស្អាតល្អ ព្រោះតាមរយៈ FDI គឺមានការនាំចូលស្តង់ដារការបំពុលរបស់ប្រទេសអភិវឌ្ឍន៍ និងបច្ចេកវិទ្យាមានប្រសិទ្ធភាពល្អមួយចំនួនទៀត ។ Antweiler et al. (1998) បានបង្កើតគំរូទ្រឹស្តីមួយ ដែលបែងចែកផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការបំពុលជាឥទ្ធិពលខាង ទំហំ បច្ចេកទេស និងសមាសភាព ដើម្បីពិនិត្យមើលថា តើភាពបើកចំហដល់ទីផ្សារទំនិញអន្តរជាតិប៉ះពាល់ដូចម្តេចដល់ការប្រមូលផ្តុំការបំពុល ដោយពួកគាត់បានប្រើប្រាស់ទិន្នន័យស្តីពីការប្រមូលផ្តុំឧស្ម័នស្ពាន់ធ័រឌីអុកស៊ីត ។ ការសិក្សារបស់ពួកគាត់បានរកឃើញថា សេរីភាវូបនីយកម្មពាណិជ្ជកម្ម នាំឱ្យមានការកាត់បន្ថយការបំពុល ពោលគឺ ប្រសិនបើសេរីភាវូបនីយកម្មពាណិជ្ជកម្មបង្កើន ផសស ក្នុងមនុស្សម្នាក់បាន ១% ការប្រមូលផ្តុំការបំពុលនឹងធ្លាក់ចុះប្រហែល ១% ។ ពួកគាត់បានគួបផ្សំការប៉ាន់ស្មាននូវឥទ្ធិពលទាំងបីខាងលើ ហើយបានសន្និដ្ឋានថា ពាណិជ្ជកម្មសេរីមានផលល្អចំពោះបរិស្ថាន ។

## សេរីភាវូបនីយកម្មពាណិជ្ជកម្ម ហុចផលអវិជ្ជមានលើបរិស្ថាន

សេរីភាវូបនីយកម្មពាណិជ្ជកម្ម អាចហុចផលអវិជ្ជមានលើបរិស្ថាន ប្រសិនបើនៅតាមប្រទេសមានឧត្តមភាពប្រៀបធៀបក្នុងឧស្សាហកម្មកខ្វក់ ឥទ្ធិពលខាងទំហំ និងសមាសភាព វាធំជាងឥទ្ធិពលខាងបច្ចេកទេស និងប្រសិនបើនៅតាមប្រទេសមានឧត្តមភាពប្រៀបធៀបក្នុងឧស្សាហកម្មស្អាតល្អ ឥទ្ធិពលខាងទំហំ វាធំជាងឥទ្ធិពលខាងបច្ចេកទេស និងសមាសភាព ។ ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសមានបទបញ្ញត្តិបរិស្ថានធូររលុង ប៉ុន្តែមានសមត្ថភាពធំដើម្បីស្រូបយកការបំពុលនោះ ទំនងជាមានឯកទេសក្នុងការផលិត និងនាំចេញផលិតផលដែលមានកំរិតបំពុលលើសលប់ ។ ក្នុងករណីបែបនេះ សេរីភាវូបនីយកម្មពាណិជ្ជកម្មអាចនាំឱ្យមានការខូចខាតបរិស្ថាន ។

Copeland និង Taylor (1994) បានធ្វើការសិក្សាមួយដ៏ល្បីល្បាញដែលគាំទ្រដល់ការវែកញែកខាងលើ ។ ការសិក្សានេះ វិភាគពីទំហំដែលសេរីភាវូបនីយកម្មពាណិជ្ជកម្ម វាជះឥទ្ធិពលលើកំរិតនៃការបំពុល ដោយបំបែកឥទ្ធិពលខាងបរិស្ថាន ចេញជាឥទ្ធិពលខាង ទំហំ សមាសភាព និងបច្ចេកទេស ។ ដើម្បីធ្វើដូច្នេះ ការសិក្សាបានប្រើប្រាស់គំរូតុល្យភាពទូទៅមួយនៃប្រទេសពីរ ដែលមានគោលនយោបាយបរិស្ថានខុសគ្នា ដោយសារមាន

ក៏រិតចំណូលខុសគ្នា ហើយរឿងនេះក៏បានជំរុញដល់ពាណិជ្ជកម្ម ។ លទ្ធផលនៃការវិភាគបង្ហាញថា ពាណិជ្ជកម្មសេរីវាបញ្ចុះកំរិតបំពុលនៅក្នុងប្រទេសសំបូរធនធានមនុស្ស (ប៉ែកខាងជើង) ហើយបង្កើនកំរិតបំពុលនៅក្នុងប្រទេសដែលខ្សត់ធនធានមនុស្ស (ប៉ែកខាងត្បូង) ដូច្នេះហើយ ក៏បង្កើនការបំពុលលើពិភពលោក ប្រសិនបើពុំមានការតំរឹមកំរិតថ្លៃរវាងប្រទេសនានាទេ ។

ការសិក្សាគួរឱ្យចាប់អារម្មណ៍មួយទៀត ដែលបានចាត់ទុកថា សេរីភាវូបនីយកម្មពាណិជ្ជកម្មនាំឱ្យខូចខាតបរិស្ថាននោះ លោកស្រី Chilchilnisky បានធ្វើវាឡើងនៅឆ្នាំ១៩៩៤ ដោយបានពិនិត្យថា តើភាពខុសគ្នានៃសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិមានឥទ្ធិពលដូចម្តេច ចំពោះការប្រើប្រាស់ធនធានធម្មជាតិ ។ គាត់បានប្រើគំរូតុល្យភាពទូទៅសំរាប់ទំនិញ២មុខ ធាតុចូល២មុខ និងប្រទេសចំនួន២ ។ វិធីសាស្ត្រនេះ ស្រដៀងគ្នានឹងគំរូស្តង់ដាររបស់ Heckscher-Ohlin ដែរ ដែលផ្អែកលើការសន្មតជាគ្រឹះថា ប្រទេសមួយ (នៅប៉ែកខាងត្បូង) ដែលមានរបបកំណត់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិមិនច្បាស់លាស់ បានធ្វើជំនួញជាមួយប្រទេសមួយទៀត (នៅប៉ែកខាងជើង) ដែលមានរបបកំណត់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិច្បាស់លាស់ ហើយប្រទេសទាំង២ មានបច្ចេកវិទ្យា ធនធានធម្មជាតិ និងចំណូលចិត្តដូចគ្នា ។ ការសិក្សាបានបង្ហាញថា ប្រទេសមានរបបសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិមិនច្បាស់លាស់ នឹងបង្កើនការប្រើប្រាស់ធនធានលើសកំរិត ដែលនាំឱ្យមានផលិតកម្មលើសកំរិតនៅប៉ែកខាងត្បូង និងការប្រើប្រាស់លើសកំរិតនៅប៉ែកខាងជើង ។ ការសន្និដ្ឋានចំបងរបស់ Chilchilnisky គឺ "ទីផ្សារអន្តរជាតិបញ្ជូន និងពង្រីកនូវផលប៉ះពាល់ពីខាងក្រៅនៃធនធានរួមរបស់ពិភពលោក ។ គោលនយោបាយដែលមើលរំលងទំនាក់ទំនងនេះ មិនអាចអនុវត្តបានជោគជ័យឡើយ" (ទំព័រ ១០៨) ។

Cole et al. (1998) បានពិនិត្យមើលថា តើកិច្ចចរចាជំនួញពហុភាគីអ៊ុយរ៉ាហ្កាយ (Uruguay Round) មានផលប៉ះពាល់ដូចម្តេច ទៅលើការបញ្ចេញសារធាតុបំពុលខ្យល់ ៥យ៉ាង (នីត្រូសែនឌីអុកស៊ីត ស៊ុលផួឌីអុកស៊ីត កាបូនម៉ូណូស៊ីត ធូលីក្នុងខ្យល់ និងកាបូនឌីអុកស៊ីត) ហើយបានប៉ាន់ស្មានថា ប្រទេសសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ និងសេដ្ឋកិច្ចអន្តរកាលស្ទើរតែទាំងអស់ នឹងមានកំណើនការបញ្ចេញសារធាតុបំពុលខ្យល់ទាំង ៥យ៉ាង ស្របពេលដែលនៅប្រទេសអភិវឌ្ឍន៍ នឹងមានការបញ្ចេញសារធាតុបំពុលខ្យល់ ៣ប្រភេទ ថយចុះ និង ២ប្រភេទទៀតកើនឡើង ។ Lee និង Roland-Holst (1997) និង Lopez (1997) មានធ្វើការសិក្សាតាមការពិនិត្យឃើញជាក់ស្តែងនៅក្នុងប្រទេសជាក់លាក់មួយចំនួន ។ Lee និង Roland-Holst បានពិនិត្យមើលថា តើពាណិជ្ជកម្មមានឥទ្ធិពលដូចម្តេច ចំពោះបរិស្ថាននៅក្នុងប្រទេសឥណ្ឌូនេស៊ី ដោយប្រើការវិភាគតុល្យភាពទូទៅសំរាប់អនុវត្ត ហើយបានរកឃើញថា សេរីភាវូបនីយកម្មពាណិជ្ជកម្មឯកតោភាគីរបស់ឥណ្ឌូនេស៊ី បង្កើនកំរិតនៃការបញ្ចេញសារធាតុពុលស្ទើរតែគ្រប់ប្រភេទដូចរៀបរាប់ខាងលើ ។ Lopez (1997) បានធ្វើការសិក្សាពីឥទ្ធិពលនៃពាណិជ្ជកម្មសេរីនៅក្នុងប្រទេសហ្កាណា ប៉ែកខាងលិច ទៅលើផលិកម្មកសិកម្ម ចំណូល និងបរិស្ថាន ហើយបានលើកថា សេរីភាវូបនីយកម្មពាណិជ្ជកម្មមានផលប៉ះពាល់អវិជ្ជមាន ទាំងទៅលើចំណូល និងទៅលើបរិស្ថាន ។ Lopez លើកឡើងថា ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមទៀត ទំនងជាធ្វើឱ្យចំណូលជាតិធ្លាក់ចុះ នឹងនាំឱ្យខូចរបៀបរស់នៅម៉ាស់ធ្ងន់ធ្ងរ ។

ផ្អែកលើការសិក្សាតាមការពិនិត្យឃើញជាក់ស្តែងដែលមានស្រាប់ ស្តីពីផលប៉ះពាល់នៃសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើបរិស្ថាន គេមិនអាចធ្វើការសន្និដ្ឋានជារួមបានទេថា ពាណិជ្ជកម្មសេរីធ្វើឱ្យគុណភាពបរិស្ថានខូចខាត ឬប្រសើរឡើង ។ អន្តរកម្មរវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថាន វាផ្អែកលើកត្តាជាក់លាក់ផ្សេងៗនៅក្នុងប្រទេស ដូចជា គោលនយោបាយ រចនាសម្ព័ន្ធស្ថាប័ន ហើយនិងកិច្ចព្រមព្រៀងសេរីភាវូបនីយកម្មពាណិជ្ជកម្មនេះដែរ ។ ដោយសារលទ្ធផលផ្អែកលើការពិនិត្យឃើញជាក់ស្តែង មានភាពមិនប្រាកដប្រជា និងមិនអាចបង្ហាញថា សេរីភាវូបនីយកម្មពាណិជ្ជកម្មមិនធ្វើឱ្យខូចខាតដល់បរិស្ថានទេ ដូច្នេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មគួរតែបញ្ចូលកិច្ចសហការខាងបរិស្ថាន ក៏ដូចជាសុខដុមនីយកម្មនៃគោលនយោបាយបរិស្ថាន ទៅក្នុងកញ្ចប់កិច្ចសហការ ដើម្បីឱ្យបរិស្ថានក្នុងតំបន់ និងពិភពលោក មានគុណភាពកាន់តែប្រសើរឡើង ។

## ២.៤. សន្ទេបសេចក្តី

ផ្នែកនេះ ពិនិត្យត្រួសៗលើការជជែកវែកញែកពីពាណិជ្ជកម្ម និងបរិស្ថាន ដោយផ្តោតជាពិសេសលើទិដ្ឋភាព ២: ផលប៉ះពាល់នៃបទបញ្ញត្តិបរិស្ថានទៅលើលំនាំការធ្វើពាណិជ្ជកម្ម និងការប្រកួតប្រជែង ហើយនិងឥទ្ធិពលនៃកំណើនសេដ្ឋកិច្ច និងសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើបរិស្ថាន ។ ទ្រឹស្តីជាច្រើនដែលគេបានចងក្រងឡើង និងមានការទទួលស្គាល់យ៉ាងទូលំទូលាយ បានជួយបង្ហាញផ្លូវដល់ការជជែកវែកញែកពីបញ្ហាខាងលើ ប៉ុន្តែការសិក្សាផ្អែកលើការពិនិត្យឃើញជាក់ស្តែងនានា មិនអាចបង្កើតអំណះអំណាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការប៉ាន់ស្មានជាលក្ខណៈទ្រឹស្តីនោះទេ ។ ដូចនេះ ទាក់ទងនឹងសំណួរ "តើពាណិជ្ជកម្មមានផលប៉ះពាល់យ៉ាងដូចម្តេច ចំពោះបរិស្ថាន" គេពុំមានការសន្និដ្ឋានជាសាកលណាមួយទេ ។

បំរែបំរួលនៅក្នុងស្តង់ដារបរិស្ថានមិនអាចជៀសផុតទេ ជាពិសេសក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ហើយបំរែបំរួលនេះប៉ះពាល់ប៉ុណ្ណាទៅលើបន្ទុកចំណាយផលិតកម្ម និងការប្រកួតប្រជែង កំពុងស្ថិតក្នុងការជជែកវែកញែកនៅឡើយ ។ ជំពូកនេះធ្វើការវែកញែកថា បន្ទុកចំណាយខាងបរិស្ថាននៅបណ្តាប្រទេសមានបទបញ្ញត្តិបរិស្ថានតឹងរ៉ឹង មានសមាមាត្រតូចណាស់ និងមានឥទ្ធិពលតិចតួចលើភាពប្រកួតប្រជែង (ទោះជាផលប៉ះពាល់ពិតប្រាកដ វាផ្អែកលើចំណែកនៃការចំណាយត្រួតពិនិត្យការបំពុលនៅក្នុងបន្ទុកចំណាយសរុប ដែលអាចមានកំរិតខ្ពស់សំរាប់វិស័យខ្លះ) ។ ភាពប្រកួតប្រជែងអាចមានកត្តាកំណត់ជាច្រើន ដូចជា ពលកម្ម បច្ចេកវិទ្យាអាចប្រើបាន រចនាសម្ព័ន្ធទីផ្សារ បរិយាកាស អាជីវកម្ម គោលនយោបាយ និងស្ថាប័ន ។ ជំពូកនេះ ក៏បានវែកញែកដែរថា ភាពទន់ខ្សោយនៃបទបញ្ញត្តិបរិស្ថាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មិនមែនជាកត្តាសំខាន់ នាំឱ្យមានការផ្លាស់ប្តូរទីតាំងនៃឧស្សាហកម្មមានការបំពុលខ្លាំងនោះទេ ។ កត្តាផ្សេងទៀត ដូចជា ស្ថិរភាពនយោបាយ វត្តមានធនធានធម្មជាតិ ទំហំទីផ្សារ ច្រកចូលទីផ្សារ បរិយាកាសវិនិយោគ ។ល។ មានសារៈសំខាន់បំផុតសំរាប់ការវិនិយោគ ។

កំណើនសេដ្ឋកិច្ច និងកំណើនប្រាក់ចំណូល អាចជាសូចនាករងាយៗបំផុតបង្ហាញពីការវិវត្តរបស់មនុស្ស ប៉ុន្តែកំណើនសេដ្ឋកិច្ចគ្មានកំហិតកំណត់អ្វីសោះ អាចធ្វើឱ្យខូចខាតដល់បរិស្ថាន ។ ការអភិវឌ្ឍមានចីរភាព ដែលរក្សា

តុល្យភាពបានល្អរវាងកំណើនសេដ្ឋកិច្ច និងចីរភាពបរិស្ថាន ត្រូវពឹងផ្អែកលើការអនុវត្តតាមគោលនយោបាយគាំទ្រ និងស្ថាប័នផ្សេងៗ ដែលអាចជួយធានាឱ្យមានការរក្សាការពារបរិស្ថានឱ្យបានគ្រប់គ្រាន់តាមការតំរូវនៃច្បាប់ ។

សេរីភាវូបនីយកម្មពាណិជ្ជកម្មអាចហុចផលវិជ្ជមាន ឬអវិជ្ជមាន ចំពោះបរិស្ថាន យោងតាមឧត្តមភាពប្រៀបធៀបគោលនយោបាយមានស្រាប់ និងការគ្រប់គ្រងធនធានរបស់ប្រទេសនីមួយៗ ។ បច្ចុប្បន្នការសំរបសំរួលគោលនយោបាយបរិស្ថានរវាងប្រទេសជាដៃគូពាណិជ្ជកម្មមានតិចតួចណាស់ ហើយការចរចាពាណិជ្ជកម្មផ្សេងៗតែងតែមើលរំលងបញ្ហានានាខាងបរិស្ថាន ។ ការតភ្ជាប់ការងារគ្រប់គ្រងបរិស្ថាន ជាមួយនឹងសេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺសំខាន់បំផុតដើម្បីរក្សាការពារបរិស្ថានធម្មជាតិ និងធានានូវភាពរីកលូតលាស់ប្រកបដោយចីរភាព ។

ជំពូក ៣

# វិធីសាស្ត្រវាយតំលៃផលប៉ះពាល់នៃពាណិជ្ជកម្មនៅលើបរិស្ថាន

ជំពូកនេះ បង្ហាញត្រួសៗពីវិធីសាស្ត្របានប្រើប្រាស់ក្នុងការសិក្សានេះ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃពាណិជ្ជកម្មអន្តរជាតិទៅលើបរិស្ថាន និងជាពិសេសគឺ ក៏រិតបំពុលនៅទូទាំងមហាអនុតំបន់មេគង្គ និងនៅកម្ពុជា ។

## ៣.១. ការវាស់វែង និងព្យាករណ៍ពីផលវិបាកខាងបរិស្ថាននៃពាណិជ្ជកម្ម

ដើម្បីវាយតំលៃថា កំណើនពាណិជ្ជកម្មអាចនាំឱ្យមានការខូចខាតគុណភាពបរិស្ថានមែន ឬក៏អត់ គេត្រូវ ក) វាស់វែងពីផលវិបាកខាងបរិស្ថាននៃសកម្មភាពផលិតកម្ម រួមទាំងបណ្តាសកម្មភាពបង្កដោយពាណិជ្ជកម្ម និង ខ) ពិនិត្យពីអន្តរកម្មដ៏មានសន្ទុះរវាងពាណិជ្ជកម្ម ចំណូល និងគុណភាពបរិស្ថាន ។

ការខូចខាតបរិស្ថាន និងការរេចរឹលធនធាន គឺជាផលបន្ទាប់បន្សំនៃសកម្មភាពផលិតកម្ម ។ កត្តាធាតុចូល ដូចជា ប្រេង និងប្រភពថាមពលដទៃទៀត អាចនាំឱ្យមានការរេចរឹលបរិស្ថានដោយផ្ទាល់ នៅក្នុងដំណើរការផលិតថាមពលទាំងនោះ ។ កត្តាធាតុចូល ក៏អាចរួមចំណែកជាប្រយោលផងដែរដល់ការខូចខាតបរិស្ថាន ប្រសិនបើផលិតកម្មរបស់ពួកវាមានប្រើសំភារៈដែលរួមចំណែកដល់ការបំផ្លាញបរិស្ថាន ។ ដើម្បីក្តាប់បានពីទំហំនៃការបំផ្លាញបរិស្ថានបង្កដោយសកម្មភាពផលិតកម្ម គេត្រូវសំគាល់ឱ្យដាច់ពីគ្នារវាងឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោល ។

ដើម្បីវាយតំលៃពីការបំផ្លាញបរិស្ថានដែលទាក់ទងនឹងសកម្មភាពផលិតកម្ម គេត្រូវបញ្ជាក់ឱ្យច្បាស់ពីរបៀបដែលកត្តាធាតុចូលផ្សេងៗចូលរួមក្នុងសកម្មភាពផលិតកម្មនេះ ។ ទំនាក់ទំនងរវាងធាតុចូល និងធាតុចេញផ្សេងៗ និងបែបបទដែលវាជាប់ទាក់ទងគ្នា តាមធម្មតាគេអាចដឹងបានតាមមុខងារផលិតកម្ម ។ មុខងារផលិតកម្មអាចវាស់វែងនូវបម្លាស់ប្តូរនៅក្នុងតំរូវការទំនិញ និងសេវាកម្ម រួមទាំងបម្លាស់ប្តូរបង្កឡើងដោយពាណិជ្ជកម្ម ។ លើសពីនេះ តាមរយៈការកំណត់ជាក់លាក់នូវទំនាក់ទំនងរវាងសកម្មភាពផលិតកម្ម និងកំរិតនៃការបំផ្លាញបរិស្ថានដែលជាប់ទាក់ទងនឹងសកម្មភាពនីមួយៗ គេក៏អាចវាស់វែងពីផលវិបាកខាងបរិស្ថាននៃបម្លាស់ប្តូរតំរូវការ (នូវទំនិញ និងសេវាកម្ម ដែលបង្កឡើងដោយពាណិជ្ជកម្ម) ផងដែរ ។ ការព្យាករណ៍ពីការរេចរឹលបរិស្ថានទៅថ្ងៃអនាគត ដែលជាប់ទាក់ទងនឹងបម្លាស់ប្តូរតំរូវការទំនិញ និងសេវាកម្មនៅថ្ងៃខាងមុខ អាចធ្វើឡើងបានតាមមធ្យោបាយស្រដៀងគ្នាដែរ ។ នេះគឺជាគោលការណ៍ព្យាករណ៍ដែលបានប្រើក្នុងការសិក្សានេះ ។

ភាពត្រឹមត្រូវនៃការវាស់វែង និងព្យាករណ៍ពីបម្លាស់ប្តូរក្នុងតំរូវការទំនិញ និងសេវាកម្ម និងកំរិតពាក់ព័ន្ធនឹងការបំផ្លាញបរិស្ថាន វាប្រែប្រួលទៅតាមកំរិតភាពជឿនលឿន និងស្មុគស្មាញនៃវិធីសាស្ត្រដាក់អនុវត្ត និងឧបករណ៍ប្រើប្រាស់ក្នុងព្យាករណ៍ ។ ដើម្បីមានការវិភាគកាន់តែជឿនលឿន និងលំអិតស្មុគស្មាញ ពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាន និងការរេចរឹលធនធាន អ្នកនិពន្ធក្នុងការសិក្សានេះ បានណែនាំឱ្យប្រើម៉ាទ្រីសធាតុចូល-

ធាតុចេញ ឬម៉ាទ្រីសគណនេយ្យសង្គម (social accounting matrix: SAM) ដែលបើកឱ្យធ្វើវិភាគពីអន្តរកម្មរវាងវិស័យនានា និងស្ថាប័នផ្សេងៗនៅក្នុងសេដ្ឋកិច្ច ។ SAM គឺជាក្របខ័ណ្ឌវិភាគទិន្នន័យមួយ ដែលផ្តល់រូបភាពនៃស្ថានភាពនៅពេលណាមួយនូវទស្សនៈសង្ខេបចំពេលវេលាទាន់ស្ថានការណ៍ ដោយផ្តល់ជាព័ត៌មាននៅឆ្នាំគោលដែលមានលក្ខណៈស៊ីគ្នានឹងអថេរនានា ។ នៅក្នុងក្របខ័ណ្ឌនេះ កត្តាធាតុចូលទាំងអស់រួមមាន ធនធានមនុស្ស មូលធនរូបវ័ន្ត ធនធានធម្មជាតិ និងធាតុចូលអន្តរការី សុទ្ធតែត្រូវបញ្ចូលទៅក្នុងកត្តាគណនេយ្យសំរេច ។

ការសិក្សានេះ មិនបានប្រើ SAM ធ្វើជាឧបករណ៍សំរាប់ប៉ាន់ស្មានពីផលប៉ះពាល់ដោយថាហេតុនៃពាណិជ្ជកម្មចំពោះការបំផ្លាញបរិស្ថាន និងការរេចរឹលធនធានឡើយ ព្រោះបរិមាណ និងគុណភាពទិន្នន័យ ដែលអាចប្រើប្រាស់បាននៅមានកំរិតនៅឡើយ ។ ផ្ទុយទៅវិញ ការសិក្សានេះបានប្រើវិធីវិភាគមានការកែតំរូវមួយ ដែលផ្អែកលើប្រព័ន្ធគន់គូរពីការបំពុលដោយឧស្សាហកម្មមួយបង្កើតឡើងដោយ Hettige et al. (1995) សំរាប់ធនាគារពិភពលោក ។

## ៣.២. វិធីសាស្ត្រកែតំរូវសំរាប់វាយតំលៃផលវិបាកខាងបរិស្ថាន ចំពោះពាណិជ្ជកម្ម

ដើម្បីស្វែងរកទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថាន ការសិក្សានេះបានប្រើវិធីមានការកែតំរូវមួយ សំរាប់ប៉ាន់ស្មានពីឥទ្ធិពលពាណិជ្ជកម្មទៅលើកំរិតនៃការបំពុល ។ វិធីនេះរួមមាន ការកសាងម៉ាទ្រីសពាណិជ្ជកម្មដែលបង្ហាញពីនិន្នាការក្នុងពាណិជ្ជកម្មរវាងចិន និងប្រទេស GMS5 ក្នុងរយៈពេល៦ឆ្នាំ, ការគណនាពីម៉ាទ្រីស RCA, បំណែងចែកវិស័យពាណិជ្ជកម្មជាបីប្រភេទ ដោយផ្អែកលើបរិមាណនៃការបំពុល ដែលបញ្ចេញដោយផលិតកម្មរបស់ពួកវា និងចុងក្រោយបង្អស់គឺ ការកសាងម៉ាទ្រីសពាណិជ្ជកម្ម-បរិស្ថាន ដោយមានការប៉ាន់ស្មានពីកំរិតនៃការបំពុលរបស់វិស័យពាណិជ្ជកម្មដែលបានជ្រើសរើសមួយចំនួន ។ ផ្នែកខាងក្រោមពណ៌នាពីវិធីមានការកែតំរូវនេះ ដែលសាមញ្ញជាង (និងអស់ចំណាយតិចជាង) SAM ប៉ុន្តែអាចចង្អុលបង្ហាញបាន ពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើទិដ្ឋភាពមួយការបំផ្លាញបរិស្ថាន ពោលគឺ ការបំពុល ។

### ៣.២.១. ម៉ាទ្រីសពាណិជ្ជកម្ម ប្រើជាឧបករណ៍សំរាប់វិភាគពីនិន្នាការពាណិជ្ជកម្ម

ជាដំបូង ម៉ាទ្រីសពាណិជ្ជកម្មនាំចូល និងនាំចេញ ត្រូវបានបង្កើតឡើងដើម្បីបង្ហាញពីគន្លងពាណិជ្ជកម្មរវាងចិន និងប្រទេស GMS5 ក្នុងរយៈពេល៦ឆ្នាំ: ២០០១ (មុនពេលប្រទេស GMS5 ចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយចិន), ២០០៤ (ឆ្នាំចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម) និង ២០០៧ (៣ឆ្នាំ ក្រោយពីការចុះកិច្ចព្រមព្រៀង) ។ តារាង ៧ ផ្តល់នូវឧទាហរណ៍មួយស្តីពីម៉ាទ្រីសនេះ ។ បណ្តុំម៉ាទ្រីសពាណិជ្ជកម្ម ២ ត្រូវបានបង្កើតឡើង: បណ្តុំមួយសំរាប់បង្ហាញពីការនាំទំនិញចេញពីប្រទេស GMS5 ទៅកាន់ប្រទេសចិន និងការនាំទំនិញចូលពីចិន ទៅប្រទេស GMS5 ហើយមួយទៀត បង្ហាញពីការនាំទំនិញចេញពីកម្ពុជា ទៅចិន និងការនាំទំនិញចូលពីចិន មកកម្ពុជាវិញ ។ ម៉ាទ្រីសពាណិជ្ជកម្ម ត្រូវបានរៀបចំទៅតាមលំដាប់វិស័យពាណិជ្ជកម្មដែលសំគាល់ឡើងដោយប្រព័ន្ធសុខដុមនីយកម្ម (HS) មានលេខកូដ ២ខ្ទង់ ។ ខ្ទង់បញ្ឈរបង្ហាញពី ទំហំពាណិជ្ជកម្ម (តាមវិស័យ) និងចំណែកនៃវិស័យជាក់លាក់នោះនៅក្នុងពាណិជ្ជកម្មសរុប ។

បន្ថែមពីលើម៉ាទ្រីសពាណិជ្ជកម្ម សន្ទស្សន៍ RCA ត្រូវបានគេគណនាចេញពីទិន្នន័យពាណិជ្ជកម្មដែលមានស្រាប់ ដើម្បីវិភាគពីឯកទេសនីយកម្មខាងពាណិជ្ជកម្មនៃប្រទេសនីមួយៗ ។ ដូចមានកត់សំគាល់ពីខាងលើ RCA វាស់វែងពីលទ្ធផលប្រកួតប្រជែងប្រៀបធៀបនៃការនាំចេញផលិតផលជាក់លាក់មួយ ឬទំនិញមួយប្រភេទរបស់ប្រទេសមួយ ។ សន្ទស្សន៍ RCA ជួយព្យាករណ៍ពីការនាំចេញទៅថ្ងៃអនាគត នៅពេលសេរីភាវូបនីយកម្មពាណិជ្ជកម្មបានធ្វើពេញលេញហើយ ។ ឯកទេសនីយកម្ម នឹងកំណត់នូវលំនាំពាណិជ្ជកម្ម និងផលវិបាកខាងបរិស្ថានដែលអាចកើតមាន ។

### ៣.២.២. ការធ្វើចំណាត់ថ្នាក់វិស័យនានា ទៅតាមកំរិតបំពុល

ការសិក្សានេះ ព្យាយាមវាយតំលៃពីផលប៉ះពាល់ខាងបរិស្ថាននៃពាណិជ្ជកម្ម តាមរយៈមធ្យោបាយ២យ៉ាងៈ ការវាយតំលៃបែបបរិមាណ ដោយពិនិត្យលើកំរិតនៃការបំពុល ដែលចាត់ទុកជាឧទាហរណ៍មួយនៃការបំផ្លាញបរិស្ថាននៅទូទាំងតំបន់ GMS និងការវាយតំលៃបែបគុណភាព ដោយពិនិត្យពីផលប៉ះពាល់ផ្សេងៗទៀតលើបរិស្ថាននៃពាណិជ្ជកម្មនៅកម្ពុជា ។ អ្នកនិពន្ធដឹងច្បាស់ពីចំណុចខ្សោយនៃការប្រើប្រាស់ត្រឹមតែទិន្នន័យនៃការបំពុលធ្វើជាសូចនាករនៃផលប៉ះពាល់ទៅលើបរិស្ថាន ប៉ុន្តែពួកគេសង្ឃឹមថា ទិន្នន័យនេះអាចក្លាយជាចំណុចចាប់ផ្តើមសំរាប់ការស្រាវជ្រាវបន្ថែមទៀត ស្តីពីបែបបទដែលពាណិជ្ជកម្មមានផលប៉ះពាល់ទៅលើទិដ្ឋភាពផ្សេងៗនៃគុណភាពបរិស្ថាន និងចីរភាពធនធានធម្មជាតិនៅក្នុងតំបន់ GMS ។

ដើម្បីធ្វើចំណាត់ថ្នាក់វិស័យពាណិជ្ជកម្មផ្សេងៗទៅតាមកំរិតបំពុល (ការបញ្ចេញធាតុពុល គិតក្នុងធាតុចេញមួយឯកតា) ការសិក្សានេះ បានប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ឧស្សាហកម្មតាមស្តង់ដារអន្តរជាតិ លេខបីខ្ទង់ (ISIC) ដែល Hettige *et al.* (1995) បានបង្កើតឡើងនៅក្នុងការសិក្សាពីប្រព័ន្ធគន់គូរពីការបំពុលនៃឧស្សាហកម្មសំរាប់ធនាគារពិភពលោក ។ ការសិក្សានេះបានប៉ាន់ស្មានពីការបញ្ចេញសារធាតុពុលពីឧស្សាហកម្មទៅក្នុងខ្យល់ ទឹក និងដី ក៏ដូចជា ផលបូកនៃការបញ្ចេញជាតិពុលទៅក្នុងគ្រប់មធ្យោបាយ ដោយមានប្រើអថេរសេដ្ឋកិច្ចបីគឺៈ តំលៃធាតុចេញ តំលៃបន្ថែម និងចំនួនការងារ ។ ក្នុងគោលបំណងធ្វើវិភាគពីផលប៉ះពាល់ពាណិជ្ជកម្មទៅលើការបំពុល យើងបានសំរេចប្រើប្រាស់នូវកំរិតការបំពុលសំរាប់គ្រប់មធ្យោបាយ ដែលបញ្ចេញដោយបរិមាណដ៏ជាក់លាក់នៃធាតុចេញ (សំរាប់បរិមាណប៉ាន់ស្មាននៃការបំពុលបញ្ចេញដោយផ្នែកពាណិជ្ជកម្មនីមួយៗ គិតជាផោនក្នុងមួយលានដុល្លារអាមេរិក នៃធាតុចេញ សូមមើលតារាង A.1. ក្នុងឧបសម្ព័ន្ធ) ។ ការបំពុលសរុប (សរសេរកាត់ ToxTot នៅក្នុងតារាង) ជាផលបូកនៃការបំពុលក្នុងខ្យល់ (ToxAir) ទឹក (ToxWat) និងដី (ToxLand) ។

តាមរយៈព័ត៌មានក្នុងតារាង A.1 យើងបានធ្វើចំណាត់ថ្នាក់វិស័យពាណិជ្ជកម្មជា ៣ប្រភេទ យោងតាមបរិមាណជាតិពុលដែលបញ្ចេញដោយផលិតកម្មរបស់ពួកវា ។ ប្រភេទទី១ ហៅថា វិស័យមានការបំពុលបំផុត ហើយសំដៅដល់វិស័យនានាដែលមានការបំពុលលើសពី ១.៥០០ផោន (១ផោន=0,៤៥៤គ.ក) ក្នុងមួយលានដុល្លារអាមេរិក នៃផលិតកម្ម ។ វិស័យដែលចាត់ចូលទៅក្នុងប្រភេទនេះ រួមមាន ផលិតកម្មសារធាតុគីមីបែបឧស្សាហកម្ម លោហៈមិនមែនដែក ដែកនិងដែកថែប ផលិតផលស្បែក ក្រដាសនិងម្សៅក្រដាស ការស្លូតទ្រនៈ

សារធាតុគីមីដទៃទៀត ផលិតផលប្លាស្ទិក ផលិតផលធ្វើពីលោហៈនិងសង្ហារឹមមិនធ្វើពីលោហៈ ។ ពាណិជ្ជកម្មក្នុងប្រភេទនេះ មានលក្ខណៈវិនិច្ឆ័យស្រដៀងគ្នានឹងចំណាត់ថ្នាក់វិស័យមានកំរិតបំពុលខ្លាំង ឬឧស្សាហកម្មកខ្វក់ ដែលធ្វើឡើងដោយ Mani និង Wheeler (1997) ។ ដូច្នេះ វិស័យមានការបំពុលបំផុត អាចមានន័យដូចគ្នានឹងវិស័យមានការបំពុលខ្លាំង ។

***តារាង ១: សង្ខេបពីការធ្វើចំណាត់ថ្នាក់កំរិតបំពុល គិតតាមវិស័យ***

| | *ប្រភេទ ១*<br>**វិស័យបំពុលខ្លាំងបំផុត** | *ប្រភេទ ២*<br>**វិស័យបំពុលមធ្យម** | *ប្រភេទ ៣*<br>**វិស័យបំពុលតិចបំផុត** |
|---|---|---|---|
| *និយមន័យ* | ToxTot ≥ ១៥០០ផោន / លានដុល្លារអាមេរិក | ៥០០ផោន/លានដុល្លារអាមេរិក < ToxTot < ១៥០០ផោន/ លានដុល្លារអាមេរិក | ToxTot ≤ ៥០០ផោន/ លានដុល្លារអាមេរិក |
| *ផ្នែក (ISIC)* | គីមីឧស្សាហកម្ម (៣៥១)<br>លោហធាតុគ្មានជាតិដែក (៣៧២)<br>ដែក និងដែកថែប (៣៧១)<br>ផលិតផលធ្វើពីស្បែកសត្វ (៣២៣)<br>ម្សៅក្រដាស និងក្រដាស (៣៤១)<br>រោងចក្រចំរាញ់ប្រេងកាត (៣៥៣)<br>សារធាតុគីមីផ្សេងៗ (៣៥២)<br>ផលិតផលប្លាស្ទិក (៣៥៦)<br>ផលិតផលលោហធាតុកែច្នៃ (៣៨១)<br>គ្រឿងសង្ហារឹមក្រៅពីលោហធាតុ (៣៣២) | គ្រឿងក្អមឆ្នាំងធ្វើពីដីឥដ្ឋ គ្រឿងធ្វើពីដីឥដ្ឋនិងព័រសឺឡែន (៣៦១)<br>គ្រឿងម៉ាស៊ីនប្រើអគ្គិសនី (៣៨៣)<br>ផលិតផលធ្វើពីជ័រ (៣៥៥)<br>ផលិតផលរ៉ែ មិនមែនលោហធាតុ(៣៦៩)<br>វាយនភណ្ឌ (៣២១)<br>សំភារៈដឹកជញ្ជូន (៣៨៤)<br>ផលិតផលកម្មន្តសាលផ្សេងៗ (៣៩០)<br>ផលិតផលធ្យូងនិងប្រេងកាតចំរុះ (៣៥៤)<br>គ្រឿងម៉ាស៊ីនមិនប្រើអគ្គិសនី (៣៨២) | បរិក្ខារវិជ្ជាជីវៈនិងវិទ្យាសាស្ត្រ (៣៨៥)<br>គ្រឿងសំរាប់ពាក់នៅជើង មិនមែនធ្វើពីជ័រ ឬប្លាស្ទិក (៣២៤)<br>ផលិតផលបោះពុម្ព (៣៤២)<br>ផលិតផលធ្វើពីឈើ លើកលែងគ្រឿងសង្ហារឹម (៣៣១)<br>កែវ និងផលិតផលធ្វើពីកែវ (៣៦២)<br>ថ្នាំជក់ (៣១៤)<br>ផលិតផលអាហារ (៣១១)<br>ភេសជ្ជៈ (៣១៣)<br>គ្រឿងស្លៀកពាក់ (៣២២) |
| *ផ្នែក (HS)* | លោហធាតុ (HS 71-83)<br>សារធាតុគីមី (HS 28-38)<br>ប្លាស្ទិក (HS 39)<br>ម្សៅក្រដាសនិងក្រដាស (HS 47-49)<br>ស្បែកសត្វ (HS 41-43) | គ្រឿងម៉ាស៊ីន និងឧបករណ៍អគ្គិសនី (HS 84-85)<br>ផលិតផលរ៉ែ (HS 25-27)<br>វាយនភណ្ឌនិងគ្រឿងស្លៀកពាក់ (HS 50-63)<br>ផលិតផលធ្វើពីជ័រ (HS 40)<br>យានយន្ត (HS 86-89)<br>វត្ថុកែច្នៃចំរុះ (HS 93-96) | ផលិតផលបន្លែ (HS 6-14)<br>ឈើ និងគ្រឿងឈើ (44-46)<br>គ្រឿងអុបទិច ឧបករណ៍សំរាប់វាស់វែង និងឧបករណ៍តន្ត្រី (HS 90-92)<br>ថ្ម/ស៊ីម៉ង់ត៍/សេរ៉ាមិច (HS 68-70)<br>គ្រឿងឧបភោគបរិភោគ (HS 15-24)<br>គ្រឿងសំរាប់ពាក់នៅជើង (HS 64-67) |

ប្រភេទទី ២ គឺ វិស័យមានការបំពុលមធ្យម ដែលសំដៅលើវិស័យទាំងឡាយមានបញ្ចេញជាតិពុលក្នុងកំរិតពី ៥០០-១៥០០ផោន/លានដុល្លារអាមេរិក នៃផលិតកម្ម ។ វិស័យដែលចាត់ចូលក្នុងប្រភេទនេះមានគ្រឿងក្អមឆ្នាំងធ្វើពីដីឥដ្ឋ គ្រឿងធ្វើពីដីឥដ្ឋនិងព័រសឺឡែន គ្រឿងម៉ាស៊ីនប្រើអគ្គិសនីនិងមិនប្រើអគ្គិសនី គ្រឿងអគ្គិសនី ផលិផលជ័រ ផលិតផលរ៉ែមិនមែនលោហធាតុ វាយនភណ្ឌ សំភារៈដឹកជញ្ជូន ផលិតផលកម្មន្តសាលផ្សេងៗ និងផលិតផលធ្យូងនិងប្រេងកាតចំរុះ ។

ប្រភេទទី ៣ គឺ វិស័យមានការបំពុលទាបបំផុត ដែលសំដៅលើវិស័យមានបញ្ចេញជាតិពុលតិចជាង ៥០០ផោន/មួយលានដុល្លារអាមេរិក នៃផលិតកម្ម និងរួមមាន បរិក្ខារវិជ្ជាជីវៈនិងវិទ្យាសាស្ត្រ គ្រឿងសំរាប់ពាក់នៅជើងដែលមិនមែនធ្វើពីជ័រ ឬប្លាស្ទិក ផលិតផលបោះពុម្ព ផលិតផលឈើក្រៅពីសង្ហារឹម កែវនិងផលិតផលធ្វើពី

កែវ ថ្នាំជក់ ផលិតផលអាហារ ភេសជ្ជៈ និងសំលៀកបំពាក់ ។ ខាងវិស័យកសិកម្ម មានដូចជា ផលិតកម្មសត្វចិញ្ចឹម និងការនេសាទជាដើម ដែលមិនបានដាក់បញ្ចូលនៅក្នុងការសិក្សាពីប្រព័ន្ធគន់គូរពីការបំពុលនៃឧស្សាហកម្ម ត្រូវបានចាត់ចូលទៅក្នុងប្រភេទមានការបំពុលទាបបំផុត (សំរាប់គោលបំណងនៃការសិក្សានេះ) ពីព្រោះផលិតកម្មកសិកម្មមានការបំពុលក៏រិតទាប (គេទទួលស្គាល់ថា ការពង្រីកកសិកម្មអាចមានផលប៉ះពាល់ផ្សេងទៀតលើបរិស្ថាន ក្រៅពីការបំពុល ហើយគេនឹងពិភាក្សាពីបញ្ហានេះនៅផ្នែកខាងក្រោម) ។

ដោយសារតែទិន្នន័យពាណិជ្ជកម្ម ដែលដកស្រង់ចេញពីមូលដ្ឋានទិន្នន័យ Global Trade Atlas ប្រើប្រព័ន្ធសុខដុមនីយកម្មក្នុងការធ្វើចំណាត់ថ្នាក់ផលិតផលនោះ ដូច្នេះជាការសំខាន់ណាស់ ដែលត្រូវធ្វើឱ្យស៊ីគ្នានូវការរាយមុខផលិតផលដែលប្រើនៅក្នុងចំណាត់ថ្នាក់ ISIC ហើយនិង ប្រព័ន្ធ HS ដូចមានបង្ហាញក្នុងតារាង ១ ។

## ៣.២.៣ ការវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការបំពុល

ដើម្បីប៉ាន់ប្រមាណពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការបំពុល ក្រុមសិក្សាបានបង្កើតម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្ម ដោយប្រើទិន្នន័យបានពីម៉ាទ្រីសពាណិជ្ជកម្មនៃការនាំចេញ-នាំចូល ។ ការសន្មត់ចំបងនៃម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្ម គឺ កំណើនពាណិជ្ជកម្ម (ជាពិសេសការនាំចេញ) នឹងជំរុញឱ្យមានកំណើនផលិតកម្ម ហើយក៏រិតបំពុលក៏ផ្លាស់ប្តូរទៅតាមនោះ ។ ជួរផ្តេកក្នុងម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្ម បានចាត់ថ្នាក់វិស័យផ្សេងៗទៅតាមក៏រិតខ្លាំងនៃការបំពុលរបស់ពួកវា ហើយខ្ទង់បញ្ឈរពណ៌នាពីចំណុចពេលក្នុងទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិនៈ មុនកិច្ចព្រមព្រៀង (២០០១) នៅពេលការចុះហត្ថលេខាលើកិច្ចព្រមព្រៀង (២០០៤) និងក្រោយកិច្ចព្រមព្រៀង (២០០៧) ។ សំរាប់ចំណុចពេលនីមួយៗ ខ្ទង់បញ្ឈរទីមួយ កត់ត្រាពីតម្លៃពាណិជ្ជកម្មនៃប្រភេទផលិតផលនីមួយៗ ខ្ទង់ទីពីរ កត់ត្រាពីចំណែកផលិតផលក្នុងពាណិជ្ជកម្មសរុប ហើយខ្ទង់ទីបី កត់ត្រាពីប្រពលភាពប៉ាន់ស្មាននៃការបំពុល (Estimated Pollution Intensity-EPI) ដែលបានដកស្រង់ចេញពីការសិក្សារបស់ធនាគារពិភពលោក (1995 World Bank Study by Hettige et al.) ។

EPI អាចឱ្យយើងវាស់វែងក៏រិតការបំពុលបណ្តាលមកពីផលិតកម្មទំនិញតម្លៃមួយលានដុល្លារអាមេរិក ។ ត្រូវកត់សម្គាល់ជាសំខាន់ថា ការវិភាគនេះពិចារណាតែលើផលវិបាកខាងបរិស្ថាននៃផលិតផលសម្រេចប៉ុណ្ណោះ ។ យើងដឹងថា នៅមានចំណងតភ្ជាប់ជាច្រើនទៅខាងប្រភពដើម ដែលធ្វើឱ្យផលិតផលសម្រេចមួយចំនួនហាក់ដូចជាមានឥទ្ធិពលអវិជ្ជមានតិចតួចទៅលើបរិស្ថាន ប៉ុន្តែផលិតកម្មធាតុចូលនីមួយៗនៃផលិតផលសម្រេចទាំងនោះ អាចមានផលប៉ះពាល់អវិជ្ជមានជាច្រើនចំពោះបរិស្ថាន ។ ទោះយ៉ាងនេះក្តី ការសិក្សានេះវិភាគតែទៅលើផលិតផលសម្រេចប៉ុណ្ណោះ ។

## ជំពូក ៤

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងផលប៉ះពាល់នៅលើពាណិជ្ជកម្ម និងបរិស្ថាននៅមហាអនុតំបន់មេគង្គ

ជំពូកនេះ ពិនិត្យទៅលើលក្ខណៈវិនិច្ឆ័យនៃ ACFTA និងផលប៉ះពាល់ដែលអាចកើតមានទៅលើពាណិជ្ជកម្ម និងបរិស្ថាននៅក្នុងបណ្តាប្រទេស GMS5 និងប្រទេសចិន ។ ជំពូកនេះ ចែកជាពីរផ្នែក ។ ផ្នែកទីមួយ បង្ហាញត្រួសៗពី ACFTA ជាអាទិ ប្រវត្តិ សនិទាន និងលក្ខណៈដែលលេចធ្លោ ។ ផ្នែកទីពីរ ពិភាក្សាពីពាណិជ្ជកម្មរវាង GMS5 និងចិន ព្រមទាំងផលប៉ះពាល់ទៅលើបរិស្ថានតាមការផ្លាស់ប្តូរករិតបំពុល ។

## ៤.១ ការបង្ហាញត្រួសៗពី ACFTA

### ៤.១.១ ប្រវត្តិ ACFTA

ទំនាក់ទំនងរវាងអាស៊ាន និងចិន បានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅក្នុង ១៥ឆ្នាំចុងក្រោយនេះ ។ ប្រទេសចិនកន្លងមក គេធ្លាប់ចាត់ទុកជាការគំរាមកំហែងមួយចំពោះអាស៊ាន ប៉ុន្តែសព្វថ្ងៃបានវិវត្តទៅជាដៃគូអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏រឹងមាំមួយ ។ ប្រទេសចិន មានទំនាក់ទំនងជាផ្លូវការជាមួយអាស៊ាននៅឆ្នាំ១៩៩១ ហើយបានក្លាយជាដៃគូចរចាគ្នានៅឆ្នាំ១៩៩៦ ។ ទំនាក់ទំនងរវាងអាស៊ាន និងចិន បានវិវត្តយ៉ាងលឿន តាមការបង្កើតគណៈកម្មាធិការសហប្រតិបត្តិការរួមគ្នាអាស៊ាន-ចិន (១៩៩៧) មូលនិធិសហប្រតិបត្តិការអាស៊ាន-ចិន (១៩៩៧) និងកិច្ចប្រជុំកំពូលរវាងអាស៊ាន-ចិន ជាបន្តបន្ទាប់ ។ តាំងពីពេលនោះមក សហប្រតិបត្តិការរវាងអាស៊ាន និងចិន (ជាពិសេសលើពាណិជ្ជកម្ម និងវិនិយោគ) បានវិវត្តយ៉ាងឆាប់រហ័ស ។ ជាក់ស្តែង ពាណិជ្ជកម្មទ្វេភាគីបានកើនដល់ ៣៩,៥ពាន់លានដុល្លារ នៅឆ្នាំ២០០០ ធៀបនឹង ១១,០៦ពាន់លានដុល្លារ នៅឆ្នាំ១៩៩៤ ។ នៅឆ្នាំ១៩៩១ វិនិយោគរបស់អាស៊ាននៅចិន មានត្រឹម ៩០លានដុល្លារ ប៉ុន្តែបានកើនដល់ ៤,៨ពាន់លានដុល្លារ នៅឆ្នាំ១៩៩៨ និង ២៦,២ពាន់លានដុល្លារ នៅឆ្នាំ២០០១ ចំណែកចិនបានវិនិយោគនៅអាស៊ានប្រមាណ ១,១ពាន់លានដុល្លារ នៅឆ្នាំ២០០១ (ទិន្នន័យរបស់លេខាធិការដ្ឋានអាស៊ាន) ។

ក្រោយពេលប្រទេសចិន បានចូលជាសមាជិក WTO ក្នុងឆ្នាំ២០០១ មក ពាណិជ្ជកម្មសរុបកើនឡើងយ៉ាងលឿន ប្រមាណ ២០% ក្នុងមួយឆ្នាំ នៅអំឡុងឆ្នាំ២០០១-២០០៦ ។ បរិមាណពាណិជ្ជកម្ម កើនដល់ ១៤៥,២ពាន់លានដុល្លារ នៅឆ្នាំ២០០៦ ហើយរំពឹងថានឹងឡើងដល់ ២០០ពាន់លានដុល្លារ នៅឆ្នាំ២០១០ (Lim & Lai 2007) ។ ដោយសារការលូតលាស់យ៉ាងលឿននេះ ក៏មានសំណើឱ្យបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន និងចិន នៅក្នុងកិច្ចប្រជុំថ្នាក់កំពូលអាស៊ាន+៣ កាលពីខែវិច្ឆិកា ២០០០ (រួមមាន ប្រទេសអាស៊ាន ចិន ជប៉ុន និងកូរ៉េ) ។ បន្ទាប់ពីនោះ មានការបង្កើតក្រុមជំនាញការអាស៊ាន-ចិន ដែលមានភារកិច្ចធ្វើការសិក្សាពីភាពអាចធ្វើបាន

នៃ ACFTA ។ របាយការណ៍របស់ក្រុមជំនាញការដែលបានស្នើឱ្យអាស៊ាន និងចិន បង្កើតតំបន់ពាណិជ្ជកម្មសេរីមួយក្នុងរយៈពេល ១០ឆ្នាំ បានទទួលការអបអរសសាទរពីថ្នាក់ដឹកនាំនានា នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ចិន នៅឆ្នាំ២០០១ ។

ក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី៨ នៅក្រុងភ្នំពេញ កាលពីថ្ងៃទី៤ វិច្ឆិកា ២០០២ បណ្តាប្រទេសសមាជិកអាស៊ាន និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចរួម ដែលមានទិសដៅ: (១) ពង្រឹង និងលើកកម្ពស់សហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ (២) បន្តធ្វើសេរីភាវូបនីយកម្ម និងជំរុញពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម ព្រមទាំងបង្កើតរបបវិនិយោគមួយមានតម្លាភាព លក្ខណៈសេរី និងភាពងាយស្រួល (៣) ស្វែងរកតំបន់ថ្មីៗ និងកំណត់វិធានការសមស្រប ដើម្បីឱ្យមានសហប្រតិបត្តិការកាន់តែជិតស្និទ្ធ និង (៤) ជួយសំរួលឱ្យមានសមាហរណកម្មសេដ្ឋកិច្ចកាន់តែសក្តិសិទ្ធិ នៃបណ្តាប្រទេសជាសមាជិកថ្មីរបស់អាស៊ាន និងភ្ជិតគំលាតអភិវឌ្ឍន៍រវាងប្រទេសជាដៃគូ ។ កិច្ចព្រមព្រៀងនេះ គ្របដណ្តប់លើពាណិជ្ជកម្មនៃទំនិញ/សេវា និងវិនិយោគ និងមានបទបញ្ញត្តិ សំរាប់កម្មវិធីប្រមូលផលដើមដៃ (Early Harvest Programme-EHP) ដើម្បីជំរុញការកាត់បន្ថយពន្ធគយ ក៏ដូចជាលុបបំបាត់ពន្ធគយលើផលិតផលកសិកម្មមួយចំនួន ។ EHP គ្របដណ្តប់លើផលិតផលកសិកម្មចំនួន ៨ក្រុម រួមមាន សត្វរស់ សាច់និងគ្រឿងក្នុងអាចបរិភោគបាន ត្រី ផលិតផលទឹកដោះគោ ផលិតផលសត្វដទៃទៀត ដើមឈើរស់ បន្លែនិងផ្លែឈើ និងគ្រាប់ធញ្ញជាតិ ហើយកំណត់រយៈពេលអនុវត្តចំនួន ៣ឆ្នាំ គិតចាប់ពីខែមករា ២០០៤ ។ ជាផ្នែកមួយនៃ ACFTA ដែរ អាស៊ាន និងចិន ក៏បានចរចាគ្នាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មលើទំនិញ និងសេវា ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ បានចុះហត្ថលេខានៅខែវិច្ឆិកា ២០០៤ ហើយចូលជាធរមាននៅខែកក្កដា ២០០៥ ចំណែកឯកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងសេវាកម្ម បានចុះហត្ថលេខាក្នុងខែមករា ២០០៧ និងចូលជាធរមាននៅក្នុងខែកក្កដា ២០០៧ ។

### ៤.១.២ សនិទាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន

សេដ្ឋកិច្ច និងនយោបាយ ជាកត្តាលើកទឹកចិត្តដល់អាស៊ានក្នុងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ។ ទីមួយ ប្រទេសចិន មានសេដ្ឋកិច្ចធំសំបើម និងមានសន្ទុះខ្លាំង ហើយកំណើនតំរូវការរបស់ចិន នូវទំនិញ និងសេវាពីអាស៊ាន អាចជាក្បាលម៉ាស៊ីនថ្មីមួយជួយជំរុញកំណើនផងដែរ (Chai 2004) ។ អាស៊ាន ចាត់ទុកចិនជាទីផ្សារចំបងនៅពេលអនាគត សំរាប់ការនាំចេញថាមពល វត្ថុធាតុដើម និងគ្រឿងបន្លាស់ខាងអេឡិចត្រូនិក និងម៉ាស៊ីន ។ ទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធរវាងអាស៊ាន និងចិន អាចជួយឱ្យអាស៊ានលែងសូវពឹងផ្អែកលើ ស.រ.អា សហគមន៍អឺរ៉ុប និងជប៉ុន (Bernardino 2004) ។ ទីពីរ ប្រទេសចិនក៏ផ្តល់ភាពងាយស្រួលដល់ប្រទេសជាសមាជិកថ្មីរបស់អាស៊ាន ដូចជា កម្ពុជា ឡាវ ភូមា និងវៀតណាម ដោយផ្តល់នូវការអនុគ្រោះជាពិសេស និងជំនួយអភិវឌ្ឍន៍ និងចែករំលែកអត្ថប្រយោជន៍ពីលក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (MFN) របស់ WTO ទៅឱ្យប្រទេសដែលមិនមែនជាសមាជិក WTO ។ វិធានការទាំងនេះ ជួយឱ្យប្រទេសជាសមាជិកថ្មីរបស់អាស៊ាន អាចទទួលបានប្រយោជន៍ពីសេរីភាវូបនីយកម្មពាណិជ្ជកម្មជាមួយចិន និងផ្តល់ភាពងាយស្រួលដល់ការភ្ជិតគំលាតអភិវឌ្ឍន៍ក្នុងតំបន់ ។ ទីបី អាស៊ាន និងចិន អាចទៅបានឆ្ងាយជាងកិច្ចព្រមព្រៀង និងការប្តេជ្ញាចិត្ត របស់សមាជិក WTO

ទាំងអស់ទៅទៀត ក្នុងការធ្វើសេរីភាវូបនីយកម្មលើពាណិជ្ជកម្មផលិតផលកសិកម្ម ពីព្រោះកសិកម្មតំបន់ត្រូពិចរបស់អាស៊ាន និងកសិកម្មតំបន់ត្រជាក់របស់ចិន ជួយបំពេញឱ្យគ្នាទៅវិញទៅមក ។ ទីបួន អាស៊ានមើលឃើញកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ថាជាមធ្យោបាយដ៏មានសក្តានុពលសំរាប់ជួយឱ្យអាស៊ានងើបពីវិបត្តិ ។ បើតាមសំដីរបស់លោក Bernardino បំណងរបស់អាស៊ាន គឺ "ប្រើប្រាស់យានជំនិះសេដ្ឋកិច្ចដ៏លឿនរបស់ចិន ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI) សាជាថ្មី និងបង្វិល FDI ខ្លះៗ ពីបរិមាណដ៏ច្រើនដែលកំពុងហូរចូលប្រទេសចិន ឱ្យហូរចូលមកតំបន់អាស៊ីអាគ្នេយ៍វិញ" (២០០៤: ៥) ។

ចំពោះចិនវិញ សេដ្ឋកិច្ច និងនយោបាយ ក៏ជាកត្តាលើកទឹកចិត្តឱ្យបង្កើត ACFTA នេះដែរ ។ ចំពោះវិស័យនយោបាយ ចិនចង់រក្សាទំនាក់ទំនងមិត្តភាពល្អជាមួយប្រទេសជិតខាងនៅប៉ែកខាងត្បូង (Chai 2004) ។ ACFTA គឺជាចំណែកមួយនៃដំណើរការកសាងទំនុកចិត្ត ដើម្បីជួយសម្រាលក្តីបារម្ភរបស់អាស៊ានពីការគំរាមកំហែងនៃសេដ្ឋកិច្ចចិន ដោយធ្វើសហប្រតិបត្តិការកាន់តែជិតស្និទ្ធក្នុងតំបន់ដែលមានដូចជា ពាណិជ្ជកម្ម និងវិនិយោគវិស័យកសិកម្ម ព័ត៌មាន និងបច្ចេកវិទ្យាផ្នែកទំនាក់ទំនង ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍអាងទន្លេមេគង្គ ទេសចរណ៍ និងសន្តិសុខ ។ គោលបំណងចំបងមួយទៀតមានលក្ខណៈជាភូគព្ភនយោបាយ (geopolitical) ពោលគឺដើម្បីទប់ទល់នឹងនយោបាយរាំងខ្ទប់របស់ ស.រ.អា ប្រឆាំងនឹងប្រទេសចិន និងដើម្បីការពារច្រកពាណិជ្ជកម្មរបស់ចិននៅអាស៊ីអាគ្នេយ៍ ។ ទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធជាមួយអាស៊ាន ជួយឱ្យប្រទេសចិនអាចកសាងកំលាំងភូគព្ភនយោបាយ និងទប់ទល់នឹងឥទ្ធិពលរបស់ ស.រ.អា និងជប៉ុន (Bernardino 2004) ។ ខាងផ្នែកសេដ្ឋកិច្ច ចិនចង់ដាក់អាស៊ានជា "សួនក្រោយផ្ទះ" របស់ខ្លួន និងជាប្រភពវត្ថុធាតុដើម ពីព្រោះចិនបានក្លាយជាប្រទេសមានសេដ្ឋកិច្ចឧស្សាហកម្ម និងជាអ្នកនាំចូលសុទ្ធ នូវផលិតផលកសិកម្ម (Bernardino 2004) ។ លោក Bernardino ក៏អះអាងដែរថា ការចូលជាសមាជិក WTO របស់ចិន កាលពីខែវិច្ឆិកា ២០០១ ហើយនិងការបន្តដាក់សម្ពាធរបស់ ស.រ.អា គឺជាកត្តាជំរុញឱ្យចិនចងសម្ព័ន្ធភាពជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសនៅអាស៊ីខាងកើត ដូចជា អាស៊ាន ជប៉ុន និងកូរ៉េ តាមរយៈគំនិតផ្តួចផ្តើមបង្កើតអាស៊ាន+៣ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងចិន ។

## ៤.១.៣ កម្មវិធីប្រមូលផលដើមដៃ

កម្មវិធីប្រមូលផលដើមដៃ (EHP) គឺជាផ្នែកមួយនៅក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀង និងមានទិសដៅពន្លឿនការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ ។ EHP គ្របដណ្តប់លើផលិតផលដាក់បញ្ចូលក្នុងជំពូក ១-៨ នៃប្រព័ន្ធសុខដុមនីយកម្មក្នុងកំរិតលេខ ៨/៩ខ្ទង់ និងរួមមាន សត្វរស់ សាច់និងគ្រឿងក្នុងសត្វអាចហូបបាន ត្រី ផលិតផលទឹកដោះគោ ផលិតផលសត្វផ្សេងៗ ដើមឈើរស់ បន្លែហូបបាន និង ផ្លែឈើនិងគ្រាប់ធញ្ញជាតិហូបបាន ។ EHP ក៏អនុញ្ញាតឱ្យប្រទេសជាសមាជិកដកយកផលិតផលងាយប៉ះពាល់ខ្លះ ចេញពីការធ្វើសេរីភាវូបនីយកម្មផងដែរ ។ ភាគីណាដែលបានដកប្រទេសជាសមាជិកអាស៊ានណាមួយ ឬប្រទេសចិន ចេញពីសម្បទានពន្ធគយតាមរយៈបញ្ជីដកចេញ ភាគីនោះមិនទទួលបានសម្បទានពន្ធគយពីប្រទេសសមាជិកអាស៊ានឯទៀត ឬប្រទេសចិន លើផលិតផលដូចគ្នានោះដែរ ។ EHP បានចាប់អនុវត្តនៅឆ្នាំ២០០៤ ក្នុងក្របខ័ណ្ឌពេលនៃការកាត់បន្ថយពន្ធគយរយៈពេល ៣ឆ្នាំ

សំរាប់អាស៊ាន៦[៥] និងចិន និងក្របខ័ណ្ឌពេលវែងជាង សំរាប់បណ្តាប្រទេសសមាជិកថ្មីរបស់អាស៊ាន (កម្ពុជា ឡាវ ភូមា និងវៀតណាម) ។

ការកាត់បន្ថយពន្ធគយក្រោម EHP បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងកំណើនយ៉ាងលឿននៃពាណិជ្ជកម្មរវាងអាស៊ាន និងចិន ។ ក្នុងឆ្នាំ២០០៦ តម្លៃផលិតផល EHP ដែលធ្វើពាណិជ្ជកម្មរវាងអាស៊ាន និងចិន ឡើងដល់ ២,៦២ពាន់លានដុល្លារ ឬកើន ១០០% ធៀបនឹងឆ្នាំ២០០៣ ហើយតម្លៃនាំចេញពីអាស៊ានទៅចិន ឡើងដល់ ១,២១ពាន់លានដុល្លារ ឬកើន ១២០% ។ ផ្អែកលើស្ថិតិថ្មីៗនេះ ពាណិជ្ជកម្មលើផលិតផល EHP កើនដល់ ៣,០៨ពាន់លានដុល្លារ នៅឆ្នាំ២០០៧ ក្នុងនេះមាន ៤៧% ជាការនាំចេញពីអាស៊ាន ទៅចិន ។

### ៤.១.៤ កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ

កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញរវាងអាស៊ាន និងចិន បានចុះកិច្ចសន្យានៅខែវិច្ឆិកា ២០០៤ បន្ទាប់ពីមានការប្រជុំជាច្រើនលើក ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០៣ ។ កិច្ចព្រមព្រៀងនេះ បានកំណត់នូវបែបបទថ្មីៗ សំរាប់ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ វិធានកំណត់ប្រភពដើម និងវិធានការផ្សេងៗទាក់ទងនឹងពាណិជ្ជកម្ម ដូចជា កំហិតជាបរិមាណ របាំងមិនមែនពន្ធគយ និងវិធានការការពារ ក៏ដូចជារបៀបរបបស្ថាប័នក្នុងការត្រួតពិនិត្យ សម្របសម្រួល និងពិនិត្យឡើងវិញលើការអនុវត្តកិច្ចព្រមព្រៀង ។

**តារាងពេលកាត់បន្ថយពន្ធគយ**

កិច្ចព្រមព្រៀងខាងលើ តំរូវឱ្យភាគីនៃកិច្ចព្រមព្រៀងកាត់បន្ថយ និងលុបបំបាត់ជាបណ្តើរៗនូវអត្រាពន្ធគយតាម MFN នៅលើមុខផលិតផលដែលមិនគ្របដណ្តប់ដោយ EHP ស្របតាមក្របខ័ណ្ឌពេលមួយដែលបានព្រមព្រៀងគ្នា ។ កម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌបានបែងចែកមុខទំនិញធ្វើពាណិជ្ជកម្មដែលត្រូវកាត់បន្ថយពន្ធគយជា ពីរក្រុម គឺក្រុមទំនិញធម្មតា និងក្រុមទំនិញងាយប៉ះពាល់ ។

ផលិតផលស្ថិតក្នុងក្រុមទំនិញធម្មតានឹងត្រូវកាត់បន្ថយ ឬលុបចោលជាបណ្តើរៗ នូវកំរិតពន្ធគយតាម MFN របស់ពួកវា ហើយការងារនេះត្រូវអនុវត្តពីថ្ងៃទី១ មករា ២០០៥ រហូតដល់ ២០១០ សំរាប់អាស៊ាន ៦ និងចិន និងពីថ្ងៃទី១ មករា ២០០៥ ដល់ ២០១៥ សំរាប់បណ្តាប្រទេសសមាជិកថ្មីរបស់អាស៊ាន ។ ការកាត់បន្ថយ ឬលុបបំបាត់ពន្ធគយនេះ ត្រូវធ្វើតាមតារាងពេលជាក់លាក់ដូចមានចុះក្នុងតារាង ២, តារាង ៣ និងតារាង ៤ ។

***តារាង ២: អាស៊ាន ៦ និងចិន***

| X = អត្រាពន្ធគយតាម MFN | អត្រាពន្ធគយអនុគ្រោះនៃ ACFTA (មិនហួសថ្ងៃទី ១ មករា) | | | |
|---|---|---|---|---|
| | 2005* | 2007 | 2009 | 2010 |
| X > 20% | 20 | 12 | 5 | 0 |
| 15% < X < 20% | 15 | 8 | 5 | 0 |
| 10% < X < 15% | 10 | 8 | 5 | 0 |
| 5% < X < 10% | 5 | 5 | 0 | 0 |
| X < 5% | នៅដដែល | | 0 | 0 |

[៥] អាស៊ាន ៦ រួមមាន សមាជិកស្ថាបនិកនៃអាស៊ាន (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) និងប្រទេសប្រ៊ុយណេ ។

### តារាង ៣: វៀតណាម

| X = អត្រាពន្ធគយ តាម MFN | អត្រាពន្ធគយអនុគ្រោះនៃ ACFTA ( មិនហួសថ្ងៃទី ១ មករា) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 2005* | 2006 | 2007 | 2008 | 2009 | 2011 | 2013 | 2015 |
| X > 60% | 60 | 50 | 40 | 30 | 25 | 15 | 10 | 0 |
| 45% < X < 60% | 40 | 35 | 35 | 30 | 25 | 15 | 10 | 0 |
| 35% < X < 45% | 35 | 30 | 30 | 25 | 20 | 15 | 5 | 0 |
| 30% < X < 35% | 30 | 25 | 25 | 20 | 17 | 10 | 5 | 0 |
| 25% < X < 30% | 25 | 20 | 20 | 15 | 15 | 10 | 5 | 0 |
| 20% < X < 25% | 20 | 20 | 15 | 15 | 15 | 10 | 0-5 | 0 |
| 15% < X < 20% | 15 | 15 | 10 | 10 | 10 | 5 | 0-5 | 0 |
| 10% < X < 15% | 10 | 10 | 10 | 10 | 8 | 5 | 0-5 | 0 |
| 7% < X < 10% | 7 | 7 | 7 | 7 | 5 | 5 | 0-5 | 0 |
| 5% < X < 7% | 5 | 5 | 5 | 5 | 5 | 5 | 0-5 | 0 |
| X < 5% | នៅដដែល | | | | | | | 0 |

### តារាង ៤: កម្ពុជា ឡាវ និង ភូមា

| X = អត្រាពន្ធគយ តាម MFN | អត្រាពន្ធគយអនុគ្រោះនៃ ACFTA ( មិនហួសថ្ងៃទី ១ មករា) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 2005* | 2006 | 2007 | 2008 | 2009 | 2011 | 2013 | 2015 |
| X > 60% | 60 | 50 | 40 | 30 | 25 | 15 | 10 | 0 |
| 45% < X < 60% | 40 | 35 | 35 | 30 | 25 | 15 | 10 | 0 |
| 35% < X < 45% | 35 | 35 | 30 | 30 | 20 | 15 | 5 | 0 |
| 30% < X < 35% | 30 | 25 | 25 | 20 | 20 | 10 | 5 | 0 |
| 25% < X < 30% | 25 | 25 | 25 | 20 | 20 | 10 | 5 | 0 |
| 20% < X < 25% | 20 | 20 | 15 | 15 | 15 | 10 | 0-5 | 0 |
| 15% < X < 20% | 15 | 15 | 15 | 15 | 15 | 5 | 0-5 | 0 |
| 10% < X < 15% | 10 | 10 | 10 | 10 | 8 | 5 | 0-5 | 0 |
| 7% < X < 10% | 7** | 7** | 7** | 7** | 7** | 5 | 0-5 | 0 |
| 5% < X < 7% | 5 | 5 | 5 | 5 | 5 | 5 | 0-5 | 0 |
| X < 5% | នៅដដែល | | | | | | | 0 |

* កាលបរិច្ឆេទអនុវត្តដំបូងគឺថ្ងៃទី ១ កក្កដា ២០០៥ ។

** ប្រទេសមីយ៉ាន់ម៉ា ត្រូវបានអនុញ្ញាតឱ្យរក្សាអត្រាពន្ធគយតាម ACFTA មិនឱ្យលើសពី ៧,៥% រហូតដល់ឆ្នាំ២០១០ ។

កម្មវិធីកាត់បន្ថយពន្ធគយសំរាប់ផលិតផលក្នុងក្រុមទំនិញធម្មតា តំរូវឱ្យភាគីនីមួយៗបន្តកាត់បន្ថយជាបន្តបន្ទាប់នូវពន្ធគយត្រឹម ០-៥% លើផលិតផលបន្ថែម ។ ឧទាហរណ៍ ប្រទេសអាស៊ាន ៦ និងចិន ត្រូវកាត់បន្ថយពន្ធគយមកត្រឹម ០-៥% ឱ្យបានយ៉ាងហោចណាស់ ៤០% នៃបន្ទាត់ពន្ធគយក្នុងក្រុមទំនិញធម្មតា មិនហួសថ្ងៃទី១ កក្កដា ២០០៥ និងលើសពី ៦០% មិនហួសថ្ងៃទី១ មករា ២០០៧ ។ ការត្រូវលុបបំបាត់អត្រាពន្ធគយទាំងស្រុងត្រូវអនុវត្តមិនហួសថ្ងៃទី១ មករា ២០១០ ប៉ុន្តែអាចបត់បែនបានខ្លះ ដោយអាចរក្សាទុកបន្ទាត់ពន្ធគយមិនឱ្យលើសពី ១៥០បន្ទាត់ ដែលត្រូវលុបបំបាត់មិនឱ្យហួសថ្ងៃទី១ មករា ២០១២ ។ អត្រាពន្ធគយសំរាប់បណ្តាប្រទេសសមាជិកថ្មីរបស់អាស៊ាន ត្រូវកាត់បន្ថយមកត្រឹម ០-៥% សំរាប់យ៉ាងហោចណាស់ ៥០% នៃបន្ទាត់ពន្ធគយក្នុងក្រុមទំនិញធម្មតា មិនឱ្យហួសថ្ងៃទី១ មករា ២០០៩ សំរាប់វៀតណាម ថ្ងៃទី១ មករា ២០១០ សំរាប់ឡាវ និងភូមា និងថ្ងៃទី១ មករា ២០១២ សំរាប់កម្ពុជា ។ ពន្ធគយសំរាប់ផលិតផលក្នុងក្រុមទំនិញធម្មតា ត្រូវលុបបំបាត់ទាំងស្រុង មិនហួសថ្ងៃទី១ មករា ២០១៥ ប៉ុន្តែអាចបត់បែនរក្សាទុកបន្ទាត់ពន្ធគយមួយចំនួន មិនឱ្យលើសពី ២៥០បន្ទាត់ ដែលត្រូវលុបបំបាត់មិនហួសថ្ងៃទី១ មករា ២០១៨ ។

ចំពោះអត្រាពន្ធគយនៃក្រុមទំនិញងាយប៉ះពាល់ ដែលអនុវត្តតាម MFN គេត្រូវកាត់បន្ថយឱ្យដល់អត្រាគោលដៅទៅតាមកាលបរិច្ឆេទ ដែលនឹងត្រូវសំរេចដោយភាគីទាំងសងខាង ។ ផលិតផលក្នុងក្រុមនេះ មិនត្រូវមានច្រើនជាង ៤០០បន្ទាត់ ក្នុងប្រព័ន្ធសុខដុមនីយកម្ម មានលេខ ៦ខ្ទង់ និង ១០% នៃតម្លៃនាមចូលសរុប (ផ្អែកលើស្ថិតិពាណិជ្ជកម្មឆ្នាំ២០០១) សំរាប់ប្រទេសអាស៊ាន ៦ និងចិន និងមិនលើស ៥០០បន្ទាត់ បណ្តាប្រទេសសមាជិកថ្មីរបស់អាស៊ាន ។ បន្ទាត់ពន្ធគយក្នុងក្រុមងាយប៉ះពាល់ត្រូវបែងចែកចេញជា ២បញ្ជី ទៀត គឺ បញ្ជីងាយប៉ះពាល់ និងបញ្ជីងាយប៉ះពាល់ខ្លាំង ។ អត្រាពន្ធគយអនុវត្តតាម MFN សំរាប់បញ្ជីងាយប៉ះពាល់ ត្រូវកាត់បន្ថយមកត្រឹម ២០% មិនឱ្យហួសថ្ងៃទី ១ មករា ២០១២ សំរាប់ប្រទេសអាស៊ាន ៦ និងចិន និងមិនហួស ថ្ងៃទី ១ មករា ២០១៥ សំរាប់ប្រទេសសមាជិកថ្មីរបស់អាស៊ាន[១០] ។ អត្រាពន្ធគយត្រូវកាត់បន្ថយជាបន្តមកត្រឹម 0-៥% មិនហួសថ្ងៃទី ១ មករា ២០១៨ សំរាប់អាស៊ាន ៦ និងចិន និងថ្ងៃទី ១ មករា ២០២០ សំរាប់ប្រទេសសមាជិកថ្មីរបស់អាស៊ាន ។ សំរាប់ប្រទេសអាស៊ាន ៦ និងចិន ផលិតផលក្នុងបញ្ជីងាយប៉ះពាល់ខ្លាំង មិនត្រូវមានលើសពី ១០០បន្ទាត់ ក្នុងប្រព័ន្ធសុខដុមនីយកម្មមានលេខ ៦ខ្ទង់ និងត្រូវកាត់បន្ថយមកនៅទាបជាង ឬត្រឹម ៥០% មិនហួសថ្ងៃទី១ មករា ២០១៥ ហើយសំរាប់បណ្តាប្រទេសសមាជិកថ្មីរបស់អាស៊ានវិញ មិនត្រូវមានលើស ១៥០បន្ទាត់ និងត្រូវកាត់បន្ថយមកនៅទាបជាង ឬត្រឹម ៥០% នៅមុនថ្ងៃទី១ មករា ២០១៨ ។ ព័ត៌មានសង្ខេបពីតារាងពេលកាត់បន្ថយពន្ធគយមានចុះក្នុងតារាង ៥ និង តារាង ៦ ។

***តារាង ៥: តារាងពេលនៃការកាត់បន្ថយពន្ធគយសំរាប់ផលិតផលក្នុងក្រុមងាយប៉ះពាល់: អាស៊ាន ៦ និងចិន***

| | មិនហួស ថ្ងៃទី ១ មករា ២០១២ | មិនហួស ថ្ងៃទី ១ មករា ២០១៨ |
|---|---|---|
| បញ្ជីងាយប៉ះពាល់ | 20% | 0-5% |
| បញ្ជីងាយប៉ះពាល់ខ្លាំង | -- | < 50% |

***តារាង ៦: តារាងពេលនៃការកាត់បន្ថយពន្ធគយសំរាប់ផលិតផលក្នុងបញ្ជីងាយប៉ះពាល់: សមាជិកថ្មីរបស់អាស៊ាន***

| | មិនហួសថ្ងៃ ១ មករា ២០១៥ | មិនហួសថ្ងៃ ១ មករា ២០១៨ | មិនហួសថ្ងៃ ១ មករា ២០២០ |
|---|---|---|---|
| បញ្ជីងាយប៉ះពាល់ | 20% | -- | 0-5% |
| បញ្ជីងាយប៉ះពាល់ខ្លាំង | -- | <50% | -- |

## វិធានកំណត់ប្រភពដើម

វិធានកំណត់ប្រភពដើម ដែលមានចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ បានកំណត់ពីលក្ខណៈវិនិច្ឆ័យ និងវិធានកំណត់ផលិតផល ដែលត្រូវទទួលបានសម្បទានពន្ធគយអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ។ ផ្អែកតាមលក្ខណៈវិនិច្ឆ័យនៃប្រភពដើមចុះក្នុងឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀងផលិតផល

[១០] វៀតណាមមិនទាន់បានកំណត់ទេ នូវអត្រាពន្ធគយជាក់លាក់ក្នុងបញ្ជីងាយប៉ះពាល់ ដែលត្រូវកាត់បន្ថយត្រឹមថ្ងៃទី១ មករា ២០១៥ ។

នាំចូលដោយប្រទេសជាសមាជិកណាមួយត្រូវកំណត់ថា មានប្រភពដើមនៅក្នុងប្រទេសជាសមាជិកមួយទៀត និងមានសិទ្ធិទទួលបានអត្រាពន្ធគយអនុគ្រោះ ប្រសិនបើផលិតផលទាំងនោះត្រូវបានទទួល ឬផលិតទាំងស្រុងនៅក្នុងប្រទេសជាសមាជិកមួយទៀតនោះ ។ ប្រសិនបើផលិតផលទាំងនោះ មិនត្រូវបានផលិតទាំងស្រុងនៅក្នុងប្រទេសនាំចេញនោះទេ ផលិតផលទាំងនោះត្រូវមានគ្រឿងផ្សំក្នុងស្រុកយ៉ាងហោចណាស់ ៤០% ។ ផលិតផលដែលបំពេញតាមវិធានកំណត់ប្រភពដើម ត្រូវទទួលបានវិញ្ញាបនប័ត្រប្រភពដើមដែលចេញដោយអាជ្ញាធររដ្ឋាភិបាលមានការចាត់តាំងពីប្រទេសនាំចេញ និងមានការជូនដំណឹងដល់ប្រទេសដទៃទៀត ។

### សមាសភាគផ្សេងទៀត

ចំពោះវិធានការសំខាន់ៗផ្សេងទៀតទាក់ទងនឹងពាណិជ្ជកម្ម ដូចជា វិធានការមិនមែនពន្ធគយ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ស្តង់ដារអនាម័យ និងភូតគាមអនាម័យ ឧបត្ថម្ភធន និងវិធានការតបត វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងកម្មសិទ្ធិបញ្ញា ជាដើម កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញនេះ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិ WTO ។ ឧទាហរណ៍ កិច្ចព្រមព្រៀងបានកំណត់ថា ការដាក់កំហិតលើបរិមាណមិនត្រូវរក្សាទុកទេ លើកលែងតែមានការអនុញ្ញាតក្រោមគោលការណ៍របស់ WTO ហើយរបាំងមិនមែនពន្ធគយផ្សេងទៀត ត្រូវរកឱ្យឃើញ និងលុបបំបាត់ភ្លាមៗតាមអាចធ្វើបាន បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន ។

ចំពោះវិធានការការពារ[១១] កិច្ចព្រមព្រៀងបានបញ្ជាក់ថា ប្រទេសហត្ថលេខីនីមួយៗដែលជាសមាជិក WTO អាចរក្សាសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទៅតាមមាត្រា ១៩ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) និងតាមកិច្ចព្រមព្រៀង ស្តីពីវិធានការការពាររបស់ WTO រីឯប្រទេសមិនមែនជាសមាជិក WTO ទទួលបានវិធានការការពារនៃ ACFTA ។ ប្រទេសនីមួយៗ មានសេរីភាពក្នុងការទទួលយកវិធានការការពារនៃ ACFTA ប្រសិនបើសម្បទានពន្ធគយរបស់ប្រទេសនោះ ដែលស្ថិតក្រោម EHP ឬតារាងពេលនៃការកាត់បន្ថយពន្ធគយក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ វាបង្ក ឬគំរាមកំហែង បង្កឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតនូវផលិតផលប្រហាក់ប្រហែល ឬផលិតផលត្រូវប្រកួតប្រជែងផ្ទាល់នឹងទំនិញនាំចូលនោះ ។ ប្រទេសដែលទទួលយកវិធានការការពារនេះ អាចតម្លើងអត្រាពន្ធគយលើផលិតផលជាប់ទាក់ទិនរហូតដល់អត្រាពន្ធគយក្នុងលក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្មរបស់ WTO ដែលដាក់អនុវត្តលើផលិតផលនោះនៅពេលកំពុងប្រើវិធានការ ហើយក៏អាចរក្សាទុកដូច្នេះក្នុងមួយរយៈពេលដំបូងចំនួន ៣ឆ្នាំ និងអាចពន្យាពេលបានមួយលើកទៀតមិនឱ្យលើសពីមួយឆ្នាំ ។

នៅពេលបង្កើតស្ថាប័នអចិន្ត្រៃយ៍មួយមិនទាន់បាន អង្គភាពមួយដែលចូលរួមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចរបស់អាស៊ាន និងក្រសួងពាណិជ្ជកម្មរបស់ចិន ត្រូវបានតែងតាំងឱ្យធ្វើការត្រួតពិនិត្យ គ្រប់គ្រង សម្របសម្រួល

[១១] នៅក្រោមវិធាន WTO វិធានការការពារ (ដូចជា ការដាក់កំហិតបរិមាណលើការនាំចូល ឬការបង្កើនពនគយឱ្យខ្ពស់ជាងអត្រាកំណត់រួច) អាចយកមកអនុវត្ត ដើម្បីដាក់កំហិតជាបណ្តោះអាសន្នលើការនាំចូលផលិតផលជាក់លាក់មួយ ដែលបង្ក ឬគំរាមកំហែងបង្កការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុករបស់ប្រទេសសមាជិកដែលនាំចូល ។

និងពិនិត្យឡើងវិញ លើការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញ ។ អង្គភាពនេះទទួលការគាំទ្រ និងជំនួយពីជំនួបប្រជុំមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់អាស៊ាន ។ អង្គភាពនេះត្រូវជួបប្រជុំគ្នាក្នុងរយៈមួយឆ្នាំ ក្រោយពេលអនុវត្តកិច្ចព្រមព្រៀង ហើយបន្ទាប់មកត្រូវជួបប្រជុំរៀងរាល់ពីរឆ្នាំម្តង ឬនៅពេលណាមួយដ៏សមស្រប ដើម្បីពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង ក្នុងគោលបំណងស្វែងរកវិធានការបន្ថែម សំដៅធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មខាងទំនិញ កសាងវិន័យ និងចរចាពីកិច្ចព្រមព្រៀងលើបទបញ្ញត្តិទាក់ទងនឹងពាណិជ្ជកម្មក្នុងគោលការណ៍របស់ WTO ។

ខុសប្លែកពីកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយចំនួន ជាពិសេសកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលធ្វើឡើងដោយ ស.រ.អា និងកាណាដា កិច្ចព្រមព្រៀងពាណិជ្ជកម្មខាងទំនិញនេះ មិនមានបទបញ្ញត្តិស្តីពីទិដ្ឋភាពបរិស្ថាននៃពាណិជ្ជកម្មឡើយ ។ ផ្ទុយទៅវិញ សហប្រតិបត្តិការលើផ្នែកបរិស្ថានរវាងអាស៊ាន និងចិន ត្រូវបានកំណត់តាមរយៈគំនិតផ្តួចផ្តើមផ្សេងទៀត ។ ទីមួយ ក្រោមកិច្ចប្រជុំកំពូលអាស៊ាន+៣ រដ្ឋមន្ត្រីផ្នែកបរិស្ថានជួបប្រជុំគ្នាមួយឆ្នាំម្តង ដើម្បីពិភាក្សាពីបញ្ហាគោលនយោបាយ និងវិស័យត្រូវធ្វើសហប្រតិបត្តិការ ដែលរួមមាន ការអភិរក្សធនធានធម្មជាតិ ការអភិរក្សធនធានទឹក ការការពារបរិស្ថានសមុទ្រ ការបណ្តុះបណ្តាលពីបច្ចេកវិទ្យាខាងបរិស្ថាន និងការចូលរួមជាសាធារណៈ ការការពារតំបន់ដីសើម ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ផលិតកម្មស្អាត ព្រមទាំងការទប់ស្កាត់ និងត្រួតពិនិត្យការបំពុលឆ្លងប្រទេស ។ សហប្រតិបត្តិការដទៃទៀតលើបញ្ហាបរិស្ថាន ក៏អាចធ្វើឡើងក្នុងក្របខ័ណ្ឌ GMS ដែរ ។ បញ្ហានៃការរេចរឹលបរិស្ថានក្នុង GMS ត្រូវបានទទួលស្គាល់ និងលើកឡើងជាបន្តបន្ទាប់នៅក្នុងកិច្ចប្រជុំកំពូលរបស់ GMS ដែលវេទិកាដ៏សំខាន់សំរាប់ឱ្យថ្នាក់ដឹកនាំធ្វើការពិភាក្សា និងព្រមព្រៀងគ្នាលើសកម្មភាពជាអាទិភាព សំរាប់កម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច GMS ។

កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ច GMS មានចក្ខុវិស័យជំរុញការគ្រប់គ្រងធនធានក្នុងអនុតំបន់ប្រកបដោយចីរភាព ដើម្បីកែជួសជុលភាពរេចរឹលពីមុនមកវិញ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍថ្មីៗទៅលើបរិស្ថាន ។ ការងារជាអាទិភាពមួយ គឺ កម្មវិធីបរិស្ថានស្នូល ដែលមានសមាសភាគចំនួន ៥ គឺ: ១-ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើវិស័យជាអាទិភាព និងរបៀងសេដ្ឋកិច្ចរបស់ GMS ២-គំនិតផ្តួចផ្តើមពីរបៀងនៃការអភិរក្សជីវៈចម្រុះ ៣-ការវាយតម្លៃពីការអនុវត្តខាងបរិស្ថាន ៤-ការកសាងសមត្ថភាពលើការគ្រប់គ្រងបរិស្ថាន និង ៥-ការអភិវឌ្ឍកម្មវិធី ការអនុវត្ត និងការផ្តល់ហិរញ្ញប្បទានមានចីរភាព ។ កម្មវិធីបរិស្ថានស្នូល មានគោលបំណងផ្តល់សិទ្ធិអំណាចដល់ប្រទេស GSM ក្នុងការគ្រប់គ្រងបរិស្ថាន និងអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន តាមរយៈការអភិរក្សជីវៈចម្រុះ ការពង្រឹងសមត្ថភាពធ្វើផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងបរិស្ថាន និងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយឈរលើការរួបរួម និងសហការគ្នា ។ ក្រុមការងារខាងបរិស្ថាន ដើរតួជាវេទិកា និងជាទីប្រឹក្សា ក្នុងការដោះស្រាយបញ្ហាបរិស្ថាននៅក្នុងតំរោងអនុតំបន់ និងជួយសម្រួលកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរព័ត៌មាន ការបណ្តុះបណ្តាល ការសម្របសម្រួលគោលនយោបាយ និងការផ្តល់ហិរញ្ញប្បទានដល់គម្រោង និងការអនុវត្ត ។ កន្លងមក កម្មវិធីបរិស្ថានស្នូលបានទទួលជោគជ័យគួរឱ្យកត់សម្គាល់ជាច្រើន ដូចជាការចាប់អនុវត្តគម្រោងសាកល្បងមួយចំនួន ដើម្បីលើកកម្ពស់ការអភិរក្សជីវៈចម្រុះ ការពង្រឹងក្រុមការងារខាង

បរិស្ថានតាមរយៈការកសាងសមត្ថភាព និងការបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាន ដើម្បីសម្របសម្រួលលើបញ្ហាបរិស្ថានឆ្លងប្រទេស និងចែករំលែកធនធាន និងព័ត៌មាន ដោយមានចីរភាព និងមានរយៈពេលវែង ។

សរុបមក ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាងប្រទេសអាស៊ាន និងចិន បានរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយការបង្កើត ACFTA គឺជាជំហានមួយធំឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកាន់តែជិតស្និទ្ធស៊ីជម្រៅ និងមានផលប្រយោជន៍ទៅវិញទៅមក ។ ទោះយ៉ាងនេះក្តី របៀបវារៈខាងបរិស្ថានមិនទាន់បានពិភាក្សាសព្វគ្រប់នៅឡើយទេនៅក្នុងកិច្ចចរចាស្តីពីពាណិជ្ជកម្ម ពីព្រោះក្នុងកិច្ចព្រមព្រៀងនៅមិនទាន់មានបញ្ញត្តិសំរាប់ដោះស្រាយបញ្ហាបរិស្ថានដែលកើតឡើងពីពាណិជ្ជកម្មនោះទេ ។ ថ្វីបើសហប្រតិបត្តិការខាងបរិស្ថានរវាងអាស៊ាន និងចិន ក៏ឃើញមាននៅក្នុងគំនិតផ្តួចផ្តើមជាច្រើនទៀតដែរ ប៉ុន្តែមិនទាន់មានគំនិតផ្តួចផ្តើមណាមួយដែលផ្សារភ្ជាប់យ៉ាងជាក់លាក់ទៅនឹងពាណិជ្ជកម្មឡើយ ។

## ៤.២ ពាណិជ្ជកម្មនៅក្នុងមហាអនុតំបន់មេគង្គ និងផលប៉ះពាល់នៅលើបរិស្ថាន

### ៤.២.១ ការពិនិត្យត្រួសៗពីពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិន

ដូចមានបង្ហាញក្នុងក្រាហ្វិក២ ក្នុង ៨ឆ្នាំ កន្លងមកនេះ ពាណិជ្ជកម្មក្នុង GMS បានរីកលូតលាស់យ៉ាងលឿន ។ ពាណិជ្ជកម្មសរុបរវាងចិន និងប្រទេស GMS5 កើនឡើងក្នុងអត្រាជាមធ្យម ២៧% ក្នុងមួយឆ្នាំ ពីត្រឹម ៩,៩៨ពាន់លានដុល្លារ ក្នុងឆ្នាំ២000 ដល់ ៥៣,០១ពាន់លានដុល្លារ ក្នុងឆ្នាំ២00៧ ។ ពីឆ្នាំ២000-២00៧ ការនាំចេញពីប្រទេស GMS5 ទៅប្រទេសចិន តំណាងឱ្យប្រហែល ៥0% នៃពាណិជ្ជកម្មសរុប ដោយកើនឡើងក្នុងអត្រាជាមធ្យម ២៦% ក្នុងមួយឆ្នាំ រីឯការនាំចូលពីប្រទេសចិនវិញ កើនឡើងក្នុងអត្រា ២៩% ក្នុងមួយឆ្នាំ ។

***ក្រាហ្វិក ២: ពាណិជ្ជកម្មរវាងប្រទេសចិន និងប្រទេស GMS5***



## ការនាំចេញផលិតផលពីប្រទេស GMS5 ទៅ ចិន

ការនាំចេញពីប្រទេស GMS5 ទៅចិន ប្រមូលផ្តុំលើផលិតផលមួយក្រុមតូច ដែលរួមចំណែក ៨៧% នៃការនាំចេញសរុបក្នុងឆ្នាំ២០០៧ ។ ផលិតផលនាំចេញធំៗបំផុត រួមមាន ម៉ាស៊ីន គ្រឿងមេកានិកនិងគ្រឿងម៉ាស៊ីនអគ្គិសនី ដែលមានប្រហែល ៥០% នៃការនាំចេញសរុប បន្ទាប់មកគឺ ឥន្ធនៈរ៉ែ កៅស៊ូ ប្លាស្ទិក សារធាតុគីមី និងឈើ ។ ផលិតផលកសិកម្មជាក់លាក់ ដូចជា បន្លែ ផ្លែឈើ ជាដើម ក៏ជាផលិតផលនាំចេញសំខាន់ៗពីប្រទេស GMS5 ទៅកាន់ប្រទេសចិនផងដែរ ទោះបីវាមានចំណែកតិចតួចក្តី (ប្រហែល ៤%) ។ តារាង ៧ បង្ហាញថាក្នុង ៧ឆ្នាំចុងក្រោយនេះ ផលិតផលនាំចេញឈានមុនគេ ១០មុខ បានកើនឡើងខ្លាំងណាស់ ទាំងបរិមាណ (ពីត្រឹម ៤.៧៥ពាន់លានដុល្លារ ក្នុងឆ្នាំ២០០១ ដល់ ១២.១ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៤ និង ២៣.១ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៧) និងទាំងជាចំណែកភាគរយ (ពី ៨១% ក្នុងឆ្នាំ២០០១ ដល់ ៨៨% ក្នុងឆ្នាំ២០០៧) ។

***តារាង ៧: ផលិតផលនាំចេញពីប្រទេស GMS5 ទៅប្រទេសចិន***

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2004/01 | 2007/04 | 2007/01 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | តម្លៃ (លានដុល្លារអាមេរិក) | | | បំរែបំរួលតាមពេល (%) | | | ចំណែក (%) | | |
| 84 | គ្រឿងមេកានិក និងម៉ាស៊ីន | 975.1 | 2846.9 | 7251.6 | 192 | 155 | 644 | 16.5 | 19.9 | 27.5 |
| 85 | គ្រឿងម៉ាស៊ីនប្រើអគ្គិសនី | 918.3 | 2984.6 | 5818.3 | 225 | 95 | 534 | 15.6 | 20.9 | 22.1 |
| 27 | ប្រេង និងឥន្ធនៈរ៉ែ | 1071.9 | 2426.7 | 2506.0 | 126 | 3 | 134 | 18.2 | 17.0 | 9.5 |
| 40 | កៅស៊ូ | 465.8 | 1155.0 | 2297.1 | 148 | 99 | 393 | 7.9 | 8.1 | 8.7 |
| 39 | ប្លាស្ទិក | 666.4 | 1223.7 | 1641.3 | 84 | 34 | 146 | 11.3 | 8.6 | 6.2 |
| 29 | សារធាតុគីមីសរីរាង្គ | 104.8 | 344.1 | 1357.4 | 228 | 294 | 1195 | 1.8 | 2.4 | 5.1 |
| 44 | ឈើ និងផលិតផលធ្វើពីឈើ | 244.3 | 456.5 | 762.2 | 87 | 67 | 212 | 4.1 | 3.2 | 2.9 |
| 07 | បន្លែអាចហូបបាន | 139.7 | 326.8 | 649.6 | 134 | 99 | 365 | 2.4 | 2.3 | 2.5 |
| 26 | រ៉ែលោហៈ កាកសំណល់រ៉ែ និងផេះ | 33.5 | 130.3 | 436.0 | 289 | 234 | 1200 | 0.6 | 0.9 | 1.7 |
| 08 | ផ្លែឈើអាចហូបបាន | 130.1 | 214.6 | 369.7 | 65 | 72 | 184 | 2.2 | 1.5 | 1.4 |
| **ផលិតផលនាំចេញនាំមុខគេចំនួន ១០** | | 4750.4 | 12,109 | 23,089 | 154.9 | 90.7 | 386.1 | 80.5 | 84.8 | 87.5 |
| **ផ្សេងៗ** | | 1150 | 2162 | 3283 | 87.9 | 51.9 | 185.4 | 19.5 | 15.2 | 12.5 |
| **ផលិតផលទាំងអស់** | | 5901 | 14,272 | 26,373 | 141.9 | 84.8 | 346.9 | 100 | 100 | 100 |

ប្រភព: Global Trade Atlas 2007

នៅក្នុង GMS5 ថៃ ជាប្រទេសនាំចេញធំបំផុតទៅកាន់ប្រទេសចិន ។ នៅឆ្នាំ២០០៧ តម្លៃនាំចេញរបស់ថៃកើនជាខ្លាំងដល់ប្រហែល ២២.៦៥ពាន់លានដុល្លារ (ធៀបនឹង ១១.៥៤ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៤) ឬស្មើ ៨៦% នៃការនាំចេញសរុបរបស់ GMS5 ក្នុងឆ្នាំនោះ ។ ក្រុមផលិតផលនាំចេញសំខាន់ៗ រួមមាន គ្រឿងម៉ាស៊ីន

និងបរិក្ខារអគ្គិសនី កៅស៊ូ សារធាតុគីមីសរីរាង្គ ឥន្ធនៈរ៉ែ បន្លែ ឈើ ផ្លែឈើនិងគ្រាប់ផ្លែឈើ ។ វៀតណាម ជាប្រទេសនាំចេញធំទីពីរ ដោយមានតម្លៃនាំចេញប្រមាណ ៣,២១៣ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៧ ហើយការនាំចេញនេះ មានលំនាំប្រហែលគ្នានឹងថៃដែរ គឺផ្តោតលើផលិតផលធនធានធម្មជាតិ (ដូចជា ឥន្ធនៈរ៉ែ រ៉ែ ឈើ កៅស៊ូ) ផលិតផលកសិកម្ម (ដូចជា បន្លែ ផ្លែឈើ គ្រាប់ផ្លែឈើ ម្សៅ) និងទំនិញកម្មន្តសាល (ដូចជា គ្រឿងម៉ាស៊ីន បរិក្ខារអគ្គិសនី គ្រឿងសំរាប់ពាក់នៅជើង) ។ ផលិតផលនាំចេញឈានមុខគេទាំង ១០នេះ បានចូលរួមចំណែកយ៉ាងសំខាន់ (៨៧%) ក្នុងការនាំចេញសរុប ។ មីយ៉ាន់ម៉ា ជាប្រទេសនាំចេញធំទីបី បន្ទាប់មកគឺប្រទេស ឡាវ និងកម្ពុជា ។ ការនាំចេញរបស់ប្រទេសទាំងនេះ មិនសូវខុសគ្នាពីប្រទេសវៀតណាមទេ ដោយផ្តោតជាសំខាន់លើធនធានធម្មជាតិ និងផលិតផលកសិកម្ម (សេចក្តីលំអិតមានបង្ហាញក្នុងតារាង A.2-A.5 នៅក្នុងឧបសម្ព័ន្ធ) រីឯរចនាការនាំចេញរបស់កម្ពុជា ទៅចិន មានពិភាក្សាលំអិតនៅក្នុងជំពូកបន្ទាប់ ។

ក្រាហ្វិក ៣ បង្ហាញពីនិន្នាការនៃផលិតផល ២ក្រុម ចំបងៗ ដែលចិននាំចូលពីប្រទេស GMS5 ។ ក្រុមទី១ សំដៅដល់ផលិតផលដែលមានអត្រាពន្ធគយត្រូវកាត់បន្ថយ ក្រោមការប្តេជ្ញាចិត្តរបស់ ACFTA សំរាប់ការនាំចូលមានប្រភពមកពីប្រទេស GMS5 ។ ផលិតផលទាំងនេះ រួមមាន គ្រឿងម៉ាស៊ីននិងគ្រឿងមេកានិក (HS 84) គ្រឿងម៉ាស៊ីនប្រើអគ្គិសនី (HS 85) ឥន្ធនៈរ៉ែ (HS 27) កៅស៊ូ (HS 40) ប្លាស្ទិក (HS 39) បន្លែ (HS 07) និងផ្លែឈើ (HS 08) ។ ក្រុមទី២ សំដៅដល់ផលិតផលដែលមានអត្រាពន្ធគយមិនប្រែប្រួល និងរួមមាន សរសៃឆ្មារសំយោគ ឬសិប្បនិម្មិត (HS 54) ក្រដាស (HS 48) សរសៃអំបោះសិប្បកម្ម (HS 55) កប្បាស (HS 52) យានយន្ត (HS 87) និងកាហ្វេ និងតែ (HS 09) ។

***ក្រាហ្វិក ៣: និន្នាការនៃការនាំចូលរបស់ប្រទេសចិន នូវផលិតផលមកពីប្រទេស*** *GMS5*



ក្រាហ្វិក ៣ បង្ហាញទៀតថា និន្នាការនៃការនាំចូលផលិតផលទាំងពីរក្រុម មានលក្ខណៈស្រដៀងគ្នា នៅមុនពេលអនុវត្តការកាត់បន្ថយពន្ធគយក្រោមកិច្ចព្រមព្រៀង ACFTA (ឆ្នាំ២០០០-០៤) ប៉ុន្តែបានប្រែប្រួលខុសគ្នាក្រោយពេលដាក់អនុវត្ត (ឆ្នាំ២០០៥-០៧) ។ ការនាំចូលក្រុមផលិតផលដែលមានការបញ្ចុះអត្រាពន្ធគយកើនឡើងជាខ្លាំងចាប់ពីឆ្នាំ២០០៥ រីឯការនាំចូលក្រុមផលិតផលដែលមានអត្រាពន្ធគយថេរ មានកំណើនយឺត ។ ការវិភាគនិន្នាការជាដំបូងៗនេះ បង្ហាញពីសារៈសំខាន់នៃការកាត់បន្ថយពន្ធគយសំរាប់ពាណិជ្ជកម្ម ។ គេចាត់ទុកកិច្ចព្រមព្រៀង ACFTA ដែលតម្រូវឱ្យសមាជិកទាំងអស់អនុវត្តការកាត់បន្ថយពន្ធគយជាបណ្តើរៗនេះ ជាកត្តាជំរុញឱ្យចិនបង្កើនការនាំចូលផលិតផលពីប្រទេស GMS5 ។

ការទស្សទាយជាលក្ខណៈទ្រឹស្តីដែលថា ប្រទេសមួយមាននិន្នាការនាំចេញផលិតផលដែលខ្លួនមានឧត្តមភាពប្រៀបធៀប ទំនងជាត្រឹមត្រូវហើយសំរាប់ប្រទេស GMS5 ។ ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (Revealed Comparative Advantage-RCA) នៃប្រទេស GMS5 នៅក្នុងទីផ្សារប្រទេសចិនបញ្ជាក់ថា ប្រទេសទាំងនេះមានជំនាញឯកទេសខ្ពស់ក្នុងផលិតកម្មទំនិញកសិកម្ម ផលិតផលផ្អែកលើធនធានធម្មជាតិ និងឧស្សាហកម្មធុនស្រាល ។ ផលិតផលនាំចេញឈានមុខទាំងអស់ លើកលែងតែ គ្រឿងអគ្គិសនីនិងគ្រឿងមេកានិក និងរបស់ធ្វើពីដែក ដែកថែបនិងរ៉ែចេញ បានបង្ហាញពីឧត្តមភាពប្រៀបធៀបខ្ពស់ ហើយភាគច្រើនបានបង្កើនសន្ទស្សន៍ឧត្តមភាពប្រៀបធៀបពិនិត្យឃើញរបស់ខ្លួននៅរយៈពេល ៧ឆ្នាំចុងក្រោយនេះថែមទៀត ។ ផលិតផលនាំចេញខ្លះរបស់ប្រទេស GMS5 ដូចជា សត្វរស់ គ្រឿងសំរាប់ពាក់នៅជើង គ្រឿងម៉ាស៊ីន គ្រឿងមេកានិក និងសារធាតុគីមីសរីរាង្គ មិនសូវប្រកួតប្រជែងឡើយកាលពីអតីតកាល ប៉ុន្តែនៅពេលនេះវាហាក់បីដូចជាមានឧត្តមភាពប្រៀបធៀបខ្ពស់នៅក្នុងទីផ្សារប្រទេសចិន ។

ប្រទេសថៃ មានឧត្តមភាពប្រៀបធៀបខ្ពស់លើផលិតផលកសិកម្ម កែច្នៃនិងមិនទាន់កែច្នៃ ដូចជា បន្លែធញ្ញជាតិ ដើមឈើរស់ ផ្លែឈើនិងគ្រាប់ផ្លែឈើ ផលិតផលម្សៅ (malt ម្សៅដំឡូង និងម្សៅមី) គ្រឿងម្ហូបអាហារនិងស្ករ ។ ប្រទេសថៃ ក៏មានឯកទេសក្នុងការផលិត កៅស៊ូនិងប្លាស្ទិក គ្រឿងម៉ាស៊ីននិងគ្រឿងមេកានិក និងផលិតផលធ្វើពីឈើដែរ ។ ប្រទេសវៀតណាម ដូចគ្នានឹងប្រទេសថៃ គឺមានឯកទេសលើផលិតផលកសិកម្មកែច្នៃនិងមិនទាន់កែច្នៃ កៅស៊ូនិងផលិតផលធ្វើពីឈើ ។ វៀតណាម ក៏មានឯកទេសក្នុងការផលិតឥន្ទនៈរ៉ែ សំលៀកបំពាក់ និងគ្រឿងសំរាប់ពាក់នៅជើង ដែលមានឧត្តមភាពប្រៀបធៀបខ្ពស់នៅក្នុងទីផ្សារប្រទេសចិន ។ ឯកទេសកម្មរបស់ភូមា ប្រមូលផ្តុំលើផលិតផលកសិកម្ម និងផលិតផលផ្អែកលើធនធានធម្មជាតិ ចំណែកឯឡាវ មានឧត្តមភាពប្រៀបធៀបលើផលិតផលមួយចំនួនតូច ដូចជា កៅស៊ូ ផលិតផលធ្វើពីឈើ កាហ្វេនិងតែ និងសំលៀកបំពាក់ (តារាង A.6-A.10 នៅក្នុងឧបសម្ព័ន្ធ) ។ ចំណែកឯឯកទេសកម្មរបស់កម្ពុជា នៅក្នុងទីផ្សារប្រទេសចិន មានពិភាក្សានៅក្នុងជំពូកបន្ទាប់ ។

## ការនាំចូលផលិតផលពីចិនមកក្នុងប្រទេស GMS5

ដូចមានបង្ហាញក្នុងតារាង ៨ ការនាំចូលរបស់ប្រទេស GMS5 ផ្ដោតជាសំខាន់លើផលិតផលឧស្សាហកម្ម និងផលិតផលកម្មន្តសាល ។ ផលិតផលនាំចូលសំខាន់ៗដែលមានប្រមាណ ៦៧,៥% នៃផលិតផលនាំចូលសរុប ក្នុងឆ្នាំ២០០៧ រួមមាន គ្រឿងមេកានិកនិងគ្រឿងម៉ាស៊ីន គ្រឿងម៉ាស៊ីនប្រើអគ្គិសនី ដែកនិងដែកថែប យានយន្ត ឥន្ធនៈរ៉ែនិងប្រេង កប្បាសនិងក្រណាត់ និង សារធាតុគីមីនិងជី ។ គ្រឿងម៉ាស៊ីន គ្រឿងមេកានិក និងបរិក្ខារអគ្គិសនី រួមចំណែកជាងមួយភាគបី នៃការនាំចូលសរុបក្នុងឆ្នាំ២០០៧ ។ រឿងនេះមានន័យថា ប្រទេស GMS5 និងចិន មានទំនាក់ទំនងពាណិជ្ជកម្មខាងឧស្សាហកម្មក្នុងកំរិតខ្ពស់ ។

***តារាង ៨: ការនាំចូលនៃប្រទេស GMS5 ពីប្រទេសចិន***

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2004/01 | 2007/04 | 2007/01 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | *តម្លៃ (ជាលានដុល្លារអាមេរិក)* | | | *បំរែបំរួលតាមពេល (ជា%)* | | | *ចំណែក (ជា%)* | | |
| 84 | គ្រឿងមេកានិក និងគ្រឿងម៉ាស៊ីន | 998/5 | 1973/5 | 4803/5 | 98 | 143 | 381 | 20/4 | 17/1 | 18/0 |
| 85 | គ្រឿងម៉ាស៊ីនប្រើអគ្គិសនី | 730/3 | 1718/4 | 4091/8 | 135 | 138 | 460 | 14/9 | 14/9 | 15/4 |
| 72 | ដែកនិងដែកថែប | 205/5 | 1231/7 | 3611/5 | 499 | 193 | 1657 | 4/2 | 10/7 | 13/6 |
| 87 | យានយន្ត | 528/1 | 330/3 | 1054/7 | -37 | 219 | 100 | 10/8 | 2/9 | 4/0 |
| 27 | ឥន្ធនៈរ៉ែ និងប្រេង | 303/0 | 797/2 | 9973 | 163 | 25 | 229 | 6/2 | 6/9 | 3/7 |
| 73 | ផលិតផលធ្វើពីដែក ឬដែកថែប | 95/2 | 232/1 | 771/2 | 144 | 232 | 710 | 1/9 | 2/0 | 2/9 |
| 52 | កប្បាស | 149/5 | 406/7 | 739/2 | 172 | 82 | 394 | 3/1 | 3/5 | 2/8 |
| 60 | ក្រណាត់ | 56/2 | 219/4 | 677/9 | 290 | 209 | 1105 | 1/1 | 1/9 | 2/5 |
| 29 | សារធាតុគីមីសរីរាង្គ | 130/3 | 229/7 | 646/8 | 76 | 182 | 396 | 2/7 | 2/0 | 2/4 |
| 31 | ជី | 86/9 | 486/9 | 588/7 | 460 | 21 | 577 | 1/8 | 4/2 | 2/2 |
| **ផលិតផលនាំចេញនាំមុខគេចំនួន ១០** | | 3283/9 | 7625/9 | 17>982 | 132/2 | 135/8 | 447/6 | 67/1 | 66/0 | 67/5 |
| **ផ្សេងៗ** | | 1608/3 | 3925/9 | 8651/8 | 144/1 | 120/4 | 437/9 | 32/9 | 34/0 | 32/5 |
| **ផលិតផលទាំងអស់** | | 4892/3 | 11>552 | 26>634 | 136/1 | 130/6 | 444/4 | 100/0 | 100/0 | 100/0 |

ប្រភព: Global Trade Atlas 2007

ក្នុងចំណោមប្រទេស GMS5 ថៃជាប្រទេសនាំផលិតផលចូលធំបំផុតពីចិន ។ ក្នុងឆ្នាំ២០០៧ ការនាំចូលផលិតផលពីចិនរបស់ថៃ មានតម្លៃ ១១,៩៨ពាន់លានដុល្លារ ឬប្រហែល ៤៥% នៃការនាំចូលសរុបរបស់ប្រទេស GMS5 ។ ក្រុមផលិតផលនាំចូលចំបងៗ រួមមាន គ្រឿងមេកានិកនិងបរិក្ខារអគ្គិសនី ដែកនិងដែកថែប លោហធាតុសំខាន់ៗ សារធាតុគីមី ប្លាស្ទិកនិងយានយន្ត ។ វៀតណាម ជាប្រទេសនាំចូលធំទីពីរដែលនាំចូលផលិតផល មានតម្លៃ ១១,៩១ពាន់លានដុល្លារ ឬស្មើនឹង ៤៤% នៃការនាំចូលសរុបរបស់ប្រទេស GMS5 ។ គ្រឿងម៉ាស៊ីន និងបរិក្ខារអគ្គិសនី គឺជាផលិតផលនាំចូលសំខាន់ជាងគេ បន្ទាប់មកគឺ ដែកនិងដែកថែប ឥន្ធនៈរ៉ែ យានយន្ត និងជី ។ វៀតណាមក៏នាំចូលកប្បាស និងក្រណាត់យ៉ាងច្រើនពីចិនដែរ សំរាប់ធ្វើជាធាតុចូលនៃផលិតកម្មវាយនភ័ណ្ឌសំរាប់នាំចេញ ។ មីយ៉ាន់ម៉ា គឺជាប្រទេសទីបី បន្ទាប់មកគឺកម្ពុជា និងឡាវ ។ មុខទំនិញនាំចូលរបស់ប្រទេសទាំងនេះ ប្រហាក់

ប្រហែលគ្នានឹងប្រទេសវៀតណាមដែរ (តារាង A.2-A.5 នៅក្នុងឧបសម្ព័ន្ធ) ។ ការនាំចូលរបស់កម្ពុជាពីប្រទេសចិន មានពិភាក្សាជាលម្អិតក្នុងជំពូកបន្ទាប់ ។

ក្រាហ្វិក ៤ បង្ហាញពីនិន្នាការនៃការនាំចូលផលិតផល ពីរក្រុម ពីប្រទេសចិនទៅក្នុងប្រទេស GMS5 ។ ក្រុមទី ១ (បន្ទាត់ជិតជាប់គ្នាក្នុងក្រាហ្វិក) រួមមាន គ្រឿងមេកានិក និងគ្រឿងម៉ាស៊ីន (HS 84) គ្រឿងម៉ាស៊ីនប្រើអគ្គិសនី (HS 85) ដែកនិងដែកថែប (HS 72) យានយន្ត (HS 87) កប្បាស (HS 52) ក្រណាត់ (HS 60) និងសារធាតុគីមីសរីរាង្គ (HS 29) ។ ប្រទេស GMS5 បានកាត់បន្ថយអត្រាពន្ធគយលើផលិតផលខាងលើមួយភាគធំដែលនាំចូលពីប្រទេសចិន ។ ក្រុមទី ២ (បន្ទាត់ដាច់ៗក្នុងក្រាហ្វិក) បង្ហាញពីផលិតផលដែលមានអត្រាពន្ធគយថេរ ដូចជា ក្រដាស (HS 48) កែវនិងផលិតផលធ្វើពីកែវ (HS 70) គ្រឿងសំរាប់ពាក់នៅជើង (HS 64) ធញ្ញជាតិ (HS 10) សាច់កែច្នៃរួច (HS 16) និង ស្ករនិងដំណាប់ (HS 17) ។

ក្រាហ្វិក ៤ បង្ហាញទៀតថា ផលិតផលទាំងពីរក្រុមមាននិន្នាការកំណើនស្រដៀងគ្នា (មានកំណើនថេរ) នៅមុនពេលមាន FTA (ឆ្នាំ២០០០-០៤) ប៉ុន្តែវាចាប់ផ្តើមមានកំណើនខុសគ្នា ក្រោយពេលអនុវត្តការកាត់បន្ថយពន្ធគយនៅឆ្នាំ២០០៥ ។ ការនាំចូលក្រុមផលិតផលដែលបានបញ្ចុះអត្រាពន្ធគយ មានកំណើនខ្លាំងបន្ទាប់ពីការចុះហត្ថលេខាលើ FTA (ឆ្នាំ២០០៥-០៧) រីឯការនាំចូលក្រុមផលិតផលមានអត្រាពន្ធគយថេរ មានកំណើនយឺត ។ ការវិភាគពីនិន្នាការពីដំបូងនេះ ឆ្លុះបញ្ចាំងពីសារសំខាន់នៃពន្ធគយចំពោះលំហូរពាណិជ្ជកម្ម ហើយការកាត់បន្ថយពន្ធគយក្រោមកិច្ចព្រមព្រៀង ACFTA ជាកត្តាជំរុញកំណើនដ៏លឿននៃការនាំចូលពីចិន មកប្រទេស GMS5 ។

***ក្រាហ្វិក ៤: និន្នាការនៃការនាំចូលពីប្រទេសចិន មកប្រទេស GMS5***




ការវិភាគពី ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ (RCA) បង្ហាញថា ប្រទេសចិនមានឧត្តមភាពប្រៀបធៀបលើផលិតផលជាច្រើនប្រភេទនៅក្នុងទីផ្សារប្រទេស GMS5 ។ ផលិតផលដែលចិនមានជំនាញឯកទេស រួមមាន គ្រឿងសំរាប់ពាក់នៅជើង ថ្មនិងសេរ៉ាមិក វាយនភ័ណ្ឌនិងអីវ៉ាន់វាយនភ័ណ្ឌ ស្បែកសត្វ ដែកនិងដែកថែប ។

ខុសប្លែកពីប្រទេស GMS5 ក្នុងចំណោមផលិតផលនាំមុខគេចំនួន ១០មុខ របស់ចិន មានតែពាក់កណ្ដាលប៉ុណ្ណោះ ដែលមានឧត្តមភាពប្រៀបធៀប (កប្បាស ដែកនិងដែកថែប ក្រណាត់ ជី គ្រឿងមេកានិក និងគ្រឿងម៉ាស៊ីន) ។ ពាណិជ្ជកម្មលើផលិតផលទាំងនេះ រួមចំណែកប្រមាណ ៣៩% នៃការនាំចេញសរុបរបស់ចិន ទៅកាន់ប្រទេស GMS5 ។ ថ្វីបើក្នុង ៧ឆ្នាំចុងក្រោយនេះ សន្ទស្សន៍ RCA នៃផលិតផលនាំចេញសំខាន់ៗរបស់ចិន មិនមានការផ្លាស់ប្ដូរជាដុំកំភួនក្ដី ប៉ុន្តែភាគច្រើនវាបានកើនឡើងបន្តិចបន្តួចដែរ ។ ឧទាហរណ៍ RCA នៃកប្បាស កើនដល់ ២,៧៧ ក្នុងឆ្នាំ២០០៧ ធៀបនឹង ២,៥១ ក្នុងឆ្នាំ២០០១ ចំណែកឯ ដែកនិងដែកថែប ក៏កើនដល់ ២,២២ ក្នុងឆ្នាំ២០០៧ ធៀបនឹង ០,៩៥ ក្នុងឆ្នាំ២០០១ ។ ករណីលើកលែងមួយ គឺសន្ទស្សន៍ RCA នៃផលិតកម្មយានយន្តបានធ្លាក់ចុះជាខ្លាំងក្នុង ៧ឆ្នាំចុងក្រោយនេះ (ធ្លាក់ពី ២,៦១ មកដល់ ០,៩០) (តារាង A.12 នៅក្នុងឧបសម្ព័ន្ធ) ។

## ៤.២.២ ឥទ្ធិពលនៃពាណិជ្ជកម្មលើការបំពុល

ដូចបានមកស្រាយនៅផ្នែកវិធីសាស្ត្រស្រាវជ្រាវ ដើម្បីប៉ាន់ស្មានពីឥទ្ធិពលពាណិជ្ជកម្មទៅលើការបំពុល យើងបានបែងចែកផលិតផលពាណិជ្ជកម្មជាបីប្រភេទធំៗ ទៅតាមកម្រិតនៃការបំពុល គឺមាន បំពុលខ្លាំង បំពុលមធ្យម និងបំពុលតិច ។ តម្លៃពាណិជ្ជកម្ម ត្រូវបានកំណត់ជាផលបូកនៃការនាំចេញ និងការនាំចូលរបស់ប្រទេស GMS5 ទៅកាន់ និងមកពី ប្រទេសចិន ហើយតួលេខនេះសំរាប់ប្រើប្រាស់ធ្វើការប៉ាន់ស្មានពីផលប៉ះពាល់ខាងបរិស្ថាននៅទូទាំង GMS នៃការបំពុលដោយផលិតកម្ម ។

តារាង ៩ បង្ហាញថា ពាណិជ្ជកម្មសរុបក្នុង**ផ្នែកបំពុលខ្លាំង** បានកើនឡើងលឿនជាងផ្នែកផ្សេងទៀត និងមានចំណែកខ្ពស់គួរឱ្យកត់សំគាល់នៅក្នុងពាណិជ្ជកម្មសរុប (២៥% ក្នុងឆ្នាំ២០០៧) ។ ដោយសារផលិតកម្មទំនិញក្នុងផ្នែកបំពុលខ្លាំង បង្កការបំពុលច្រើនជាងក្រុមផលិតផលផ្សេងទៀត ដូចនេះកំណើនលឿននៃផលិតកម្មទំនិញទាំងនេះ ដែលជាលទ្ធផលនៃកំណើនពាណិជ្ជកម្មនៅក្នុងអនុតំបន់ ទំនងជាចូលរួមចំណែកក្នុងការបំផ្លាញបរិស្ថាន ។ គេប៉ាន់ស្មានថា ពាណិជ្ជកម្មក្នុងអនុតំបន់ដែលមានតម្លៃសរុប ១៣,៤៤ពាន់លានដុល្លារ វាបង្កការបំពុលរហូតដល់ ១១៨,៩លានតោន សំរាប់អនុតំបន់ទាំងមូល ។ ប្រទេសចិន ជាផលិតករចំបងគេទូវមុខទំនិញក្នុងផ្នែកបំពុលខ្លាំង ដោយរួមចំណែក ៧០% នៃទំនិញក្នុងផ្នែកនេះ ដែលបានធ្វើពាណិជ្ជកម្មក្នុងឆ្នាំ២០០៧ ។ ដោយហេតុថាពាណិជ្ជកម្មក្នុងផ្នែកនេះ វាបង្កការបំពុលប៉ាន់ស្មានភាគច្រើនបំផុត ដែលកើតចេញពីពាណិជ្ជកម្មរវាងចិន និងប្រទេស GMS5 ដូច្នេះការបំពុលភាគច្រើននៅទូទាំង GMS គឺបង្កឡើងដោយពាណិជ្ជកម្មដែលផ្ដើមចេញពីប្រទេសចិន ។ ពាណិជ្ជកម្មលើមុខទំនិញស្ថិតក្នុង**ផ្នែកបំពុលមធ្យម** ដែលរួមមាន បរិក្ខារអគ្គិសនី និងគ្រឿងម៉ាស៊ីន ផលិតផលរ៉ែ វាយនភ័ណ្ឌ និងសំលៀកបំពាក់ ផលិតផលធ្វើពីកៅស៊ូ យានយន្ត និងផលិតផលកម្មន្តសាលផ្សេងៗ បានរួមចំណែក ៦៤% នៃពាណិជ្ជកម្មសរុប ដោយមានតម្លៃ ៣៤,០៣ពាន់លានដុល្លារ និងមានការបំពុលប៉ាន់ស្មាន ២១,១៤លានតោន ។ ទោះជាភាគរយនៃការបំពុលដោយពាណិជ្ជកម្មក្នុងផ្នែកបំពុលមធ្យម កើនឡើងខ្លាំងនៅរវាង ឆ្នាំ២០០១ និង ២០០៧ ក្ដី ប៉ុន្តែកំរិតបំពុលសរុបបង្កឡើងដោយផ្នែកនេះ វាមានមិនដល់ ២០% នៃការបំពុលបង្កដោយផ្នែកបំពុល

ខ្លាំងនោះផង ។ ក្នុងផ្នែកនេះ ចិន និងប្រទេស GMS5 បានធ្វើពាណិជ្ជកម្មជាមួយគ្នាក្នុងកំរិតប្រហាក់ប្រហែលគ្នា ដូច្នេះបានចូលរួមចំណែកសឹងតែស្មើគ្នាក្នុងការបំពុលបរិស្ថាននៅទូទាំង GMS ។

ពាណិជ្ជកម្មលើផលិតផលក្នុង**ផ្នែកបំពុលតិច** មានប្រមាណ ១០% នៃពាណិជ្ជកម្មសរុប និងមានការបំពុលប៉ាន់ស្មាន ១,២១លានដោន ។ តាមរយៈការចាត់ថ្នាក់នេះ ឈើនិងផលិតផលធ្វើពីឈើ ដែលមានរួមចំណែកប្រហែល ១៧% នៃពាណិជ្ជកម្មក្នុងផ្នែកបំពុលតិច (ភាគច្រើនមកពីប្រទេស GMS5) ត្រូវបានចាត់ទុកជាផលិតផលដែលបង្កគ្រោះថ្នាក់តិចតួចបំផុតខាងការបំពុល ។

***តារាង ៩: ម៉ាទ្រីសពាណិជ្ជកម្ម-បរិស្ថានសំរាប់ពាណិជ្ជកម្មសរុបរវាងប្រទេស GMS5 និងចិន***

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2001 | 2004 | 2007 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | *តម្លៃ (ពាន់លានដុល្លារអាមេរិក)* | | | *ចំណែក (%)* | | | *EPI* (ក្នុងមួយលានដោន)* | | |
| 71-83 | លោហធាតុគ្រឹះ | 0.63 | 2.37 | 6.09 | 5.8 | 9.2 | 11.5 | 5.6 | 21.3 | 54.9 |
| 28-38 | សារធាតុគីមី | 0.75 | 1.92 | 4.40 | 7.0 | 7.4 | 8.3 | 9.4 | 24.0 | 54.9 |
| 39-43 | ប្លាស្ទិក | 0.72 | 1.41 | 2.15 | 6.7 | 5.5 | 4.1 | 1.8 | 3.5 | 5.3 |
| 47-49 | ក្រដាស និងម្សៅក្រដាស | 0.19 | 0.20 | 0.47 | 1.7 | 0.8 | 0.9 | 0.7 | 0.7 | 1.7 |
| 41-43 | ស្បែកសត្វ | 0.08 | 0.20 | 0.33 | 0.7 | 0.8 | 0.6 | 0.4 | 1.0 | 1.7 |
| **ផ្នែកបំពុលខ្លាំង** | | **2.37** | **6.10** | **13.44** | **21.93** | **23.62** | **25.36** | **17.89** | **50.53** | **118.5** |
| 84-85 | បរិក្ខារអគ្គិសនី និងគ្រឿងម៉ាស៊ីន | 3.62 | 9.52 | 21.97 | 33.6 | 36.9 | 41.4 | 1.8 | 4.8 | 11.2 |
| 25-27 | ផលិតផលរ៉ែ | 1.45 | 3.40 | 4.01 | 13.4 | 13.2 | 7.6 | 1.1 | 2.6 | 3.1 |
| 50-63 | វាយនភ័ណ្ឌនិងសំលៀកបំពាក់ | 0.74 | 1.87 | 3.82 | 6.8 | 7.2 | 7.2 | 0.5 | 1.3 | 2.7 |
| 40 | ផលិតផលធ្វើពីកៅស៊ូ | 0.50 | 1.23 | 2.51 | 4.6 | 4.8 | 4.7 | 0.6 | 1.4 | 3.0 |
| 86-89 | យានយន្ត | 0.60 | 0.46 | 1.27 | 5.6 | 1.8 | 2.4 | 0.5 | 0.4 | 1.0 |
| 93-96 | គ្រឿងកម្មន្តសាលចម្រុះ | 0.06 | 0.18 | 0.45 | 0.6 | 0.7 | 0.8 | 0.04 | 0.1 | 0.3 |
| **ផ្នែកបំពុលមធ្យម** | | **6.97** | **16.67** | **34.03** | **64.58** | **64.53** | **64.20** | **4.57** | **10.68** | **21.14** |
| 6-14 | ផលិតផលបន្លែ | 0.53 | 1.23 | 2.08 | 4.9 | 4.8 | 3.9 | 0.01 | 0.02 | 0.04 |
| 44-46 | ឈើ និងផលិតផលធ្វើពីឈើ | 0.25 | 0.51 | 0.96 | 2.3 | 2.0 | 1.8 | 0.1 | 0.2 | 0.4 |
| 90-92 | គ្រឿងអុបទិច ឧបករណ៍សំរាប់វាស់វែង និងឧបករណ៍តន្ត្រី | 0.15 | 0.44 | 0.85 | 1.4 | 1.7 | 1.6 | 0.1 | 0.2 | 0.3 |
| 68-70 | ថ្ម / ស៊ីម៉ង់ត៍ / សេរ៉ាមិច | 0.09 | 0.27 | 0.55 | 0.8 | 1.0 | 1.0 | 0.03 | 0.1 | 0.2 |
| 15-24 | ម្ហូបអាហាររៀបចំរួច | 0.30 | 0.33 | 0.53 | 2.7 | 1.3 | 1.0 | 0.1 | 0.1 | 0.1 |
| 64-67 | គ្រឿងសំរាប់ពាក់នៅជើង | 0.05 | 0.12 | 0.28 | 0.4 | 0.5 | 0.5 | 0.023 | 0.1 | 0.1 |
| 1-5 | សត្វរស់ | 0.08 | 0.12 | 0.26 | 0.8 | 0.5 | 0.5 | 0.001 | 0.002 | 0.005 |
| 97-99 | គ្រឿងសិល្បៈ និងវត្ថុបុរាណ | 0.01 | 0.04 | 0.03 | 0.1 | 0.1 | 0.0 | 0.004 | 0.019 | 0.012 |
| **ផ្នែកបំពុលតិច** | | **1.46** | **3.06** | **5.53** | **13.52** | **11.85** | **10.44** | **0.30** | **0.64** | **1.21** |
| សរុប | ផលិតផលទាំងអស់ | 10.79 | 25.82 | 53.01 | 100 | 100 | 100 | 23 | 62 | 141 |

* កំរិតបំពុលប៉ាន់ស្មាន ។ ប្រភព: ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យពាណិជ្ជកម្មបានពី Global Trade Atlas

ទោះបីពាណិជ្ជកម្មលើផលិតផលផ្អែកលើធនធានធម្មជាតិ ទំនងជាបណ្តាលឱ្យមានការបំពុលទាបជាងពាណិជ្ជកម្មលើផលិតផលដទៃទៀតក្តី ប៉ុន្តែវាបង្កការខូចខាតបរិស្ថានតាមបែបផ្សេងៗទៀតជាច្រើន ។ ការបង្កើនពាណិជ្ជកម្មឈើ ឈើនិងផលិតផលធ្វើពីឈើ ដោយគ្មានការបទបញ្ញត្តិ និងការពង្រឹងអនុវត្តដ៏តឹងរ៉ឹង ទំនងជានឹងជំរុញការកាប់បំផ្លាញព្រៃឈើ ហើយបង្កឱ្យមានបញ្ហាបរិស្ថានជាច្រើននៅក្នុងតំបន់ និងពិភពលោក ។ នៅកំរិតមូលដ្ឋានការបាត់បង់គំរបព្រៃឈើ កាត់បន្ថយសមត្ថភាពដីក្នុងការស្រូបទឹកទុក ធ្វើឱ្យដីទំនាបងាយរងគ្រោះដោយទឹកជំនន់ និងការរលុះបាក់ដី បង្កើនអត្រាសឹករេចរឹលដី និងកាត់បន្ថយជីវៈចម្រុះ ។ នៅកំរិតសាកល ការកាប់បំផ្លាញព្រៃឈើចូលរួមជាប្រយោលដល់ការឡើងកម្តៅផែនដី ដោយសមត្ថភាពស្រូបកាបូនទុកបានថយចុះ (WTO 1999) ។

ក្រោយបានព្រមព្រៀងលើការកាត់បន្ថយអត្រាពន្ធគយជាបណ្តើរៗ គេគំពឹងថា ប្រទេស GMS5 និងចិននឹងបន្តមានកំណើនពាណិជ្ជកម្ម ដោយមានការនាំចេញផ្អែកលើឯកទេសកម្ម និងភាពប្រកួតប្រជែងរបស់ពួកគេ ។ ផ្អែកលើកំនើនពាណិជ្ជកម្មនាពេលថ្មីៗក្នុងផ្នែកបំពុលខ្លាំង ដែលមានអត្រាកំនើនថេរ ក្នុង៧ឆ្នាំចុងក្រោយនេះ គេអាចសន្និដ្ឋានថា ពាណិជ្ជកម្មក្នុងផ្នែកនេះនឹងបន្តកើនឡើងទាំងគិតជាភាគរយ និងជាតម្លៃពិត ។ ដោយសារផលិតកម្មក្នុងផ្នែកនេះបង្កការបំពុលច្រើន ដូច្នេះតម្លៃបន្ថែមនៃពាណិជ្ជកម្មទំនងជាធ្វើឱ្យបរិស្ថានខូចខាតកាន់តែធ្ងន់ធ្ងរ ។

ការវិភាគ RCA និងរចនាសម្ព័ន្ធពាណិជ្ជកម្ម បង្ហាញថា ប្រទេសចិននាំចេញផលិតផលមានការបំពុលខ្លាំង ហើយទំនងនៅតែជាអ្នកនាំចេញ និងផលិតករចំបងនូវផលិតផលមានការបំពុលខ្លាំង ដោយសារមានឧត្តមភាពប្រៀបធៀបខ្ពស់លើផលិតកម្មរបស់វា ។ ដូច្នេះការបំពុលច្រើនថែមទៀតនឹងកើតឡើងនៅប្រទេសចិន ដោយសារការបង្កើនផលិតកម្ម ដើម្បីឆ្លើយតបនឹងឱកាសពាណិជ្ជកម្មកំពុងផុសឡើង ។ ចំពោះផលិតផលមានការបំពុលមធ្យម ពាណិជ្ជកម្មផ្ទៃក្នុងឧស្សាហកម្មលើគ្រឿងមេកានិក និងបរិក្ខារអគ្គិសនី កើនឡើងយ៉ាងលឿន ។ គ្រឿងមេកានិក និងបរិក្ខារអគ្គិសនី ទំនងនៅតែជាផលិតផលចំបងដែលប្រទេស GMS5 និងចិន នាំចេញឱ្យគ្នាទៅវិញទៅមក ហើយពាណិជ្ជកម្មលើផលិតផលផ្សេងទៀត ដូចជា កៅស៊ូ វាយនភ័ណ្ឌនិងសំលៀកបំពាក់ យានយន្ត និងផលិតផលរ៉ែ ក៏រំពឹងថានឹងកើនឡើងដែរ ។ ដោយសារផលិតកម្មទំនិញទាំងនេះ កាន់តែផ្អែកខ្លាំងលើបច្ចេកវិទ្យា ដូចនេះ កំណើនពាណិជ្ជកម្មរបស់វា ទំនងមិនបង្កើនការបំពុលច្រើនជាងពាណិជ្ជកម្មលើផលិតផលមានការបំពុលខ្លាំងនោះទេ ។

## ជំពូក ៥

# ពាណិជ្ជកម្មរវាងកម្ពុជា-ចិន និងផលប៉ះពាល់នៅលើបរិស្ថាន

ផ្នែកនេះ ពិនិត្យពីផលប៉ះពាល់នៃពាណិជ្ជកម្មរវាងកម្ពុជា និងចិន ក្រោយពីមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ទៅលើបរិស្ថានធម្មជាតិរបស់កម្ពុជា ។ ផ្នែកនេះចាប់ផ្តើមរៀបរាប់ត្រួសៗ ពីទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ បន្ទាប់មកធ្វើការវិភាគពីរចនាសម្ព័ន្ធពាណិជ្ជកម្ម និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជា ព្រមទាំងវាយតម្លៃពីផលវិបាកខាងបរិស្ថាននៃពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ចំពោះកម្ពុជា ។

## ៥.១. ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងចិន

នៅទសវត្សរ៍ចុងក្រោយនេះ ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងចិន បានវិវត្តយ៉ាងច្រើនអំពីទំនាក់ទំនងដែលមានសកម្មភាពពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ចតិចតួច ទៅជាទំនាក់ទំនងដៃគូសេដ្ឋកិច្ចដ៏មានសន្ទុះរឹងមាំ ដែលជាកត្តាសំខាន់សំរាប់កំណើន និងការអភិវឌ្ឍ ជាពិសេសសំរាប់កម្ពុជា ។ ទំនាក់ទំនងបានលូតលាស់កាន់តែលឿន នៅពេលប្រទេសទាំងពីរ បានចុះកិច្ចព្រមព្រៀងលើការជំរុញ និងការពារវិនិយោគ កាលពីខែកក្កដា ១៩៩៦ ព្រមទាំងកិច្ចព្រមព្រៀងទ្វេភាគីលើការជំរុញពាណិជ្ជកម្មទៅវិញទៅមកក្នុងពេល ១ឆ្នាំក្រោយមកទៀត ។ ភាពជាដៃគូសេដ្ឋកិច្ចកាន់តែរឹងមាំឡើង បន្ទាប់ពីប្រទេសទាំងពីរ បានចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីក្រោមកម្មវិធីប្រមូលផលដើមដៃ (EHP) ក្នុងឆ្នាំ២០០៣ និងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មខាងទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ (មានបរិយាយក្នុងជំពូកមុន) ក្នុងឆ្នាំ២០០៥ ។ ព្រឹត្តិការណ៍ដ៏សំខាន់ទាំងនេះ បានបង្កើតមូលដ្ឋានយ៉ាងរឹងមាំសំរាប់ឱ្យពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ រីកដុះដាលយ៉ាងលឿន ។

***ក្រាហ្វិក ៥: ពាណិជ្ជកម្មរវាងកម្ពុជា និងចិន***




ប្រភព: Global Trade Atlas and UN Comtrade

ប្រទេសចិន គឺជាប្រភពវិនិយោគផ្ទាល់ពីបរទេស (FDI) ដ៏ធំបងមួយសំរាប់កម្ពុជា ដោយបានវិនិយោគប្រហែល ១,៦៤ពាន់លានដុល្លារ ឬ ២៧% នៃ FDI នៅអំឡុងឆ្នាំ១៩៩៦-២០០៦ ហើយបានក្លាយជាដៃគូពាណិជ្ជកម្មធំទីបួន នៅឆ្នាំ២០០៧ ។ នៅឆ្នាំ២០០៧ ពាណិជ្ជកម្មសរុបឈានដល់ ៩៣២,៣៣លានដុល្លារ ក្នុងនេះការនាំចេញពីកម្ពុជាទៅចិន មានតម្លៃ ៥១,០៨លានដុល្លារ និងការនាំចូលពីចិនមកកម្ពុជា មាន ៨៨១,២៥លានដុល្លារ (ក្រាហ្វិក ៥) ។ នៅអំឡុងឆ្នាំ២០០១-២០០៧ ការនាំចូលពីចិន កើនក្នុងអត្រាមធ្យមប្រចាំឆ្នាំ ២៨% ប៉ុន្តែការនាំចេញទៅចិនឡើងចុះមិនទៀងទាត់ ដោយក្នុងឆ្នាំខ្លះមានកំណើនអវិជ្ជមានទៀតផង ។ ដូចមានបង្ហាញក្នុងក្រាហ្វិក ៥ ការនាំចូលពីចិនគ្របដណ្តប់លើពាណិជ្ជកម្មទាំងអស់ ដោយមានចំណែក ៩៥% នៃពាណិជ្ជកម្មសរុប ។

## ការនាំចេញទំនិញពីកម្ពុជាទៅចិន

តារាង ១០ បង្ហាញថា ការនាំចេញទំនិញពីកម្ពុជាទៅចិន ផ្តោតលើផលិតផលតែមួយចំនួនតូច ដូចជាផលិតផលផ្អែកលើធនធានធម្មជាតិ ផលិតផលកសិកម្ម និងសំលៀកបំពាក់ ។ ឈើ និងផលិតផលធ្វើពីឈើ គឺជាផលិតផលនាំចេញទៅប្រទេសចិនធំបំផុត ដោយមាន ៤៧% នៃការនាំចេញសរុប និងមានតម្លៃ ២៤,០៩លានដុល្លារ បន្ទាប់មកគឺកៅស៊ូ (២១,៦%) ដោយមានតម្លៃ ១១លានដុល្លារ ក្នុងឆ្នាំ២០០៧ ។ កៅស៊ូច្រើនណាស់ បាននាំចេញទៅវៀតណាមដើម្បីកែច្នៃ និងនាំចេញសាជាថ្មីទៅចិន ។ ផលិតផលនាំចេញសំខាន់ៗផ្សេងទៀត រួមមាន កប្បាស និងសំលៀកបំពាក់ ប្រេងរុក្ខជាតិ ត្រី-ក្តាម-គ្រំ-បង្គារ និង សត្វរស់ ។

ក្រាហ្វិក ៦ បង្ហាញពីការនាំចូលរបស់ចិននូវផលិតផលពីកម្ពុជា ដែលមានអត្រាពន្ធគយកាត់បន្ថយ (បន្ទាត់ដិតជាប់ក្នុងក្រាហ្វិក) និងផលិតផលដែលមានអត្រាពន្ធមិនសូវផ្លាស់ប្តូរ (បន្ទាត់ដាច់ៗ) ។ ប្រទេសចិន បានកាត់បន្ថយពន្ធគយលើផលិតផលភាគច្រើនដែលនាំចូលពីកម្ពុជាក្រោមលក្ខខណ្ឌនៃ ACFTA ដូចជា កៅស៊ូ (HS 40) ផលិតផលធ្វើពីឈើ (HS 44) សំលៀកបំពាក់ (HS 61) សត្វរស់ (HS 01) ត្រី-ក្តាម-គ្រំ-បង្គា (HS 03) និងប្រេងរុក្ខជាតិ (HS 33) ។ ប៉ុន្តែចំពោះគ្រឿងសំរាប់ពាក់នៅជើង (HS 64) មិនមានការកាត់បន្ថយពន្ធគយទេ ។

ក្រាហ្វិក ៦ ក៏បង្ហាញពីនិន្នាការចម្រុះនៃការនាំចេញផលិតផលមួយចំនួន ដូចជា កៅស៊ូ ផលិតផលធ្វើពីឈើ និងសំលៀកបំពាក់ ដែលកើនឡើងយ៉ាងលឿន តាំងពីចាប់អនុវត្តការកាត់បន្ថយពន្ធគយនៅឆ្នាំ២០០៥ ស្របពេលដែលផលិតផលនាំចេញផ្សេងទៀតមានកំណើនយឺត ។ កៅស៊ូ ឈើ និងសំលៀកបំពាក់ បានឆ្លើយតបយ៉ាងប្រសើរចំពោះការបញ្ចុះអត្រាពន្ធគយ ដែលចិនបានអនុវត្តក្រោមកិច្ចព្រមព្រៀង ACFTA ដោយសារកម្ពុជាមានឧត្តមភាពប្រៀបធៀប និងភាពប្រកួតប្រជែងលើផលិតកម្មទំនិញទាំងនេះ ។ ប៉ុន្តែផលិតផលដទៃទៀត ជាពិសេសទំនិញកសិកម្មមិនទាន់បានទទួលអត្ថប្រយោជន៍ពេញលេញពីអត្រាពន្ធគយអនុគ្រោះនោះទេ ។ ឧទាហរណ៍ ការនាំចេញសត្វរស់ និងត្រី មិនសូវមានការផ្លាស់ប្តូរទេ រវាងអំឡុងពេលមុន និងអំឡុងពេលក្រោយឆ្នាំ២០០៥ ទោះបីអត្រាពន្ធគយមានការផ្លាស់ប្តូរក្តី ។ ជ័រឡូងឈើ ជាផលិតផលនាំចេញមួយទៀត ដែលមិនបានឆក់យកឱកាសល្អចូលទៅទីផ្សារចិន ។ ជំនួសឱ្យការនាំចេញផ្ទាល់ទៅចិន កម្ពុជាបាននាំចេញជ័រឡូងឈើទៅកាន់វៀតណាម និងថៃ ដើម្បីកែច្នៃ និងនាំចេញសាជាថ្មីទៅចិន ។

**តារាង ១០: មុខទំនិញនាំចេញរបស់កម្ពុជាទៅចិន**

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2004/01 | 2007/04 | 2007/01 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | តម្លៃ (លានដុល្លារអាមេរិក) | | | បំរែបំរួលតាមពេល (ជា%) | | | ចំណែក (ជា%) | | |
| 44 | ឈើ និងផលិតផលធ្វើ ពីឈើ | 27.03 | 15.07 | 24.09 | -44 | 60 | -11 | 77.7 | 51.0 | 47.2 |
| 40 | កៅស៊ូ | 5.71 | 2.53 | 11.01 | -56 | 335 | 93 | 16.4 | 8.6 | 21.6 |
| 52 | កប្បាស | 0.44 | 8.85 | 4.78 | 1914 | -46 | 989 | 1.3 | 29.9 | 9.4 |
| 61 | សំលៀកបំពាក់ និងគ្រឿង ដេរប៉ាក់បន្ទាប់បន្សំ | 0.05 | 0.07 | 3.66 | 34 | 4936 | 6628 | 0.2 | 0.2 | 7.2 |
| 33 | ប្រេងរុក្ខជាតិ | 0.00 | 0.06 | 1.86 | - | 2863 | - | 0.0 | 0.2 | 3.6 |
| 63 | គ្រឿងវាយនភ័ណ្ឌកែច្នៃ ផ្សេងៗ | 0.01 | 0.09 | 1.36 | 964 | 1412 | 15988 | 0.0 | 0.3 | 2.7 |
| 03 | ត្រី និងបង្គា | 0.93 | 1.28 | 1.17 | 38 | -9 | 26 | 2.7 | 4.3 | 2.3 |
| 01 | សត្វរស់ | 0.24 | 0.04 | 1.03 | -84 | 2469 | 323 | 0.7 | 0.1 | 2.0 |
| 62 | សំលៀកបំពាក់និងគ្រឿង បន្ទាប់បន្សំ ក្រៅពីដេរប៉ាក់ | 0.08 | 0.68 | 0.81 | 712 | 18 | 859 | 0.2 | 2.3 | 1.6 |
| 60 | សាច់ក្រណាត់បានពី ការដេរប៉ាក់ | 0.02 | 0.01 | 0.39 | -32 | 2804 | 1882 | 0.1 | 0.0 | 0.8 |
| **ផលិតផលនាំមុខគេទាំង ១០** | | 34.5 | 28.7 | 50.2 | -17 | 75 | 45 | 99.2 | 97.1 | 98.2 |
| **ផ្សេងៗ** | | 0.3 | 0.9 | 0.9 | 143 | 85 | 349 | 0.8 | 2.9 | 1.8 |
| **ផលិតផលទាំងអស់** | | 34.8 | 29.6 | 51.1 | 142 | 85 | 347 | 100 | 100 | 100 |

ប្រភព: Global Trade Atlas 2007

ការវិភាគខាងលើបង្ហាញថា ការកាត់បន្ថយអត្រាពន្ធគយរបស់ចិនក្រោមកិច្ចព្រមព្រៀង ACFTA មានសារៈសំខាន់ជួយបង្កើនការនាំចេញរបស់កម្ពុជា ជាពិសេសផលិតផលដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប ។ ប៉ុន្តែ ចំពោះទំនិញកសិកម្មដែលតំរូវឱ្យមានវិញ្ញាបនប័ត្រស្តង់ដារភូតគាមអនាម័យ គឺនៅមិនទាន់មានការកាត់បន្ថយពន្ធគយឱ្យបានគ្រប់គ្រាន់ទេ ។ នៅកម្ពុជា អ្នកនាំចេញមិនងាយទទួលបានវិញ្ញាបនប័ត្រនេះឡើយ ដោយសារកង្វះគ្រឿងបរិក្ខារមន្ទីរពិសោធន៍ និងបុគ្គលិកបច្ចេកទេស ។ សង្ខេបមក កិច្ចព្រមព្រៀង ACFTA ចូលរួមបានតែមួយចំណែកណាប៉ុណ្ណោះ ក្នុងការបង្កើនការនាំចេញផលិតផលពីកម្ពុជាទៅចិន ។

ការវិភាគ RCA បង្ហាញថា កម្ពុជាមានឧត្តមភាពប្រៀបធៀបលើផលិតផលមួយចំនួនតូច ដូចជា សត្វរស់ វាយនភ័ណ្ឌនិងសំលៀកបំពាក់ កៅស៊ូនិងត្រី ដែលនាបច្ចុប្បន្នស្ថិតក្នុងចំណោមផលិតផលនាំចេញឈានមុខគេទាំង ១០ ទៅប្រទេសចិន ។ តារាង A.11 ក្នុងឧបសម្ព័ន្ធបង្ហាញថា នៅក្នុងរយៈពេល ៧ឆ្នាំចុងក្រោយនេះ សន្ទស្សន៍ RCA នៃផលិតផលដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប មាននិន្នាការកើនឡើង និងមានកំណើនយ៉ាងលឿន លើកលែងតែឈើមួយមុខចេញ ។ ម្យ៉ាងទៀត ផលិតផលដូចជា សំលៀកបំពាក់ គ្រឿងសំរាប់ពាក់នៅជើង និងប្រេងរុក្ខជាតិ ដែលកាលពីមុនមិនសូវមានប្រជាប្រិយភាពនៅលើទីផ្សារចិន ឥឡូវនេះបានប្រែក្លាយជាមានការប្រកួតប្រជែងខ្លាំង ។ ដោយសារគីរិតនៃការអភិវឌ្ឍ និងភាពអំណោយផលធនធានរបស់កម្ពុជា ដូចជា ដីយ៉ាងធំសំរាប់ផលិតកម្មកសិកម្ម និងប្រាក់ឈ្នួលពលកម្មទាប កម្ពុជានៅតែមានឯកទេសកម្មលើផលិតផល ដែលផ្អែកលើ

ធនធានធម្មជាតិ កសិកម្ម និងសំលៀកបំពាក់ ហើយកម្ពុជាទំនងជានឹងនាំចេញផលិតផលទាំងនេះកាន់តែច្រើនឡើងទៅប្រទេសចិន ។

***ក្រាហ្វិក ៦: និន្នាការនៃការនាំចូលពីកម្ពុជារបស់ចិន***




ប្រភព: Global Trade Atlas and UN Comtrade

## ការនាំចូលទំនិញពីចិនមកកម្ពុជា

ទំនិញដែលកម្ពុជានាំចូលពីចិន ភាគច្រើនជាផលិតផលឧស្សាហកម្ម និងកម្មន្តសាល ។ ផលិតផលចំបងៗដែលមានចំណែក ៨០% នៃទំនិញនាំចូលសរុបពីចិន រួមមាន កប្បាសនិងក្រណាត់ គ្រឿងមេកានិកនិងគ្រឿងចក្រ ឧបករណ៍អគ្គិសនី ផលិតផលសេរ៉ាមិក និងយានយន្ត ។ ក្នុងចំណោមផលិតផលទាំងនេះ វាយនភ័ណ្ឌនិងសំលៀកបំពាក់ (HS 50-63) មានចំណែកធំជាងគេ ដោយមានតម្លៃ ៥២៥លានដុល្លារ ក្នុងឆ្នាំ២០០៧ ឬ ៦០% នៃការនាំចូលសរុបពីចិន និងមានកំណើនខ្លាំង បើធៀបនឹងក៏រិត ២៩៧.៧លានដុល្លារ ក្នុងឆ្នាំ២០០៤ និង ១១៤.៤លានដុល្លារ ក្នុងឆ្នាំ២០០១ ។

កំណើនយ៉ាងខ្លាំងនៃការនាំចូលក្រុមផលិតផលនេះ ឆ្លុះបញ្ចាំងពីកំណើនតំរូវការវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលជាធាតុចូលនៃផលិតកម្មកាត់ដេរ ហើយក៏ជាឧស្សាហកម្មនាំចេញធំបំផុតរបស់កម្ពុជាដែរ ។ នៅកម្ពុជា វិស័យកាត់ដេរ រួមចំណែកប្រហែល ១៦% ក្នុង ផសស និងផ្តល់ការងារ (ដោយផ្ទាល់ និងដោយប្រយោល) ដល់ប្រហែល ១០% នៃកម្លាំងពលកម្មសរុប និងមានតម្លៃនាំចេញដល់ ៣.៣២ពាន់លានដុល្លារ នៅឆ្នាំ២០០៦ ឬមានកំណើនជាង ៦០% ធៀបនឹង ២.០២ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៤ (CDRI 2008) ។

ក្រុមផលិតផលសំខាន់ទីពីរ ដែលកម្ពុជានាំចូលពីចិន រួមមានឧបករណ៍អគ្គិសនីនិងគ្រឿងម៉ាស៊ីន (HS 84-85) ដែលរួមចំណែក ១៣% នៃការនាំចូលសរុប និងដែលមានកំណើនខ្លាំង បើធៀបនឹងចំណែក ៦% ក្នុងឆ្នាំ២០០១ (តារាង ១១) ។ ការនាំចូលសរុប កើនឡើង ៣៣២% នៅរវាងឆ្នាំ២០០១ និង ២០០៧ ។

**តារាង ១១: រចនាសម្ព័ន្ធនៃការនាំចូលពីចិនរបស់កម្ពុជា**

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2004/01 | 2007/04 | 2007/01 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | តម្លៃ (លានដុល្លារអាមេរិក) | | | បំរែបំរួលតាមពេល (%) | | | ចំណែក (%) | | |
| 60 | សាច់ក្រណាត់បានពីការដេរប៉ាក់ | 30.38 | 85.98 | 250.99 | 183 | 192 | 726 | 14.9 | 19.0 | 28.5 |
| 52 | កប្បាស | 49.85 | 118.27 | 127.52 | 137 | 8 | 156 | 24.5 | 26.1 | 14.5 |
| 85 | ឧបករណ៍ និងគ្រឿងម៉ាស៊ីនប្រើអគ្គិសនី | 11.80 | 15.53 | 74.42 | 32 | 379 | 531 | 5.8 | 3.4 | 8.4 |
| 84 | គ្រឿងម៉ាស៊ីន និងគ្រឿងមេកានិក | 0.59 | 22.02 | 66.04 | 3612 | 200 | 11033 | 0.3 | 4.9 | 7.5 |
| 55 | សរសៃអំបោះសិប្បនិម្មិត | 11.03 | 32.17 | 50.60 | 192 | 57 | 359 | 5.4 | 7.1 | 5.7 |
| 61 | សំលៀកបំពាក់ និងគ្រឿងសំលៀកបំពាក់បន្ទាប់បន្សំ | 6.82 | 8.97 | 30.42 | 31 | 239 | 346 | 3.3 | 2.0 | 3.5 |
| 69 | ផលិតផលសេរ៉ាមិក | 4.87 | 13.88 | 29.11 | 185 | 110 | 497 | 2.4 | 3.1 | 3.3 |
| 89 | ទូក កប៉ាល់ និងគ្រឿងអណ្តែតទឹក | 0.24 | 4.86 | 27.42 | 1947 | 464 | 11445 | 0.1 | 1.1 | 3.1 |
| 54 | សរសៃលោហៈសំយោគ | 6.15 | 20.42 | 26.20 | 232 | 28 | 326 | 3.0 | 4.5 | 3.0 |
| 58 | ក្រណាត់តម្បាញពិសេស | 3.31 | 21.08 | 26.17 | 537 | 24 | 691 | 1.6 | 4.7 | 3.0 |
| **ផលិតផលនាំមុខគេទាំង ១០** | | 125.04 | 343.18 | 708.90 | 174 | 107 | 467 | 61.3 | 75.9 | 80.4 |
| **ផ្សេងៗ** | | 78.83 | 109.15 | 172.35 | 38 | 58 | 119 | 38.7 | 24.1 | 19.6 |
| **ផលិតផលសរុប** | | 203.87 | 452.33 | 881.25 | 122 | 95 | 332 | 100 | 100 | 100 |

ប្រភព: Global Trade Atlas 2007

ក្រាហ្វិក ៧ បង្ហាញពីនិន្នាការនៃការនាំចូលផលិតផលពីរក្រុម ពីចិនមកកម្ពុជា ។ ក្រុមទីមួយ (ខ្សែបន្ទាត់ដិតជាប់) គឺជាផលិតផលដែលកម្ពុជាបានកាត់បន្ថយអត្រាពន្ធគយ ក្រោមឆន្ទៈនៃកិច្ចព្រមព្រៀង ACFTA ។ ផលិតផលទាំងនេះ រួមមាន គ្រឿងម៉ាស៊ីន និងគ្រឿងមេកានិក (HS 84) សំភារៈអេឡិចត្រូនិក (HS 85) កប្បាស (HS 52) ក្រណាត់និងសំលៀកបំពាក់ (HS 54, 55, 58, 60, 61) ដែកនិងដែកថែប (HS 72) និង គ្រឿងធ្វើពីដែកនិងដែកថែប (HS 73) ។ ក្រុមទីពីរ (ខ្សែបន្ទាត់ដាច់ៗ) គឺជាផលិតផលដែលមិនមានការផ្លាស់ប្តូរអត្រាពន្ធគយ និងរួមមាន ផលិតផលឱសថ (HS 30) ក្រដាស (HS 48) ភេសជ្ជៈ (HS 22) ថ្នាំជក់ (HS 24) ឥន្ធនៈរ៉ែ (HS 27) និងសារធាតុគីមីសរីរាង្គ (HS 29) ។

ក្រាហ្វិក ៧ បង្ហាញថា ផលិតផលទាំងពីរក្រុម មាននិន្នាការនាំចូលស្រដៀងគ្នានៅមុនពេលកាត់បន្ថយពន្ធគយ (២០០០-២០០៤) ដោយកើនឡើងក្នុងសន្ទុះថេរ និងប្រហាក់ប្រហែលគ្នា ប៉ុន្តែក្នុងឆ្នាំ២០០៥ បានចាប់ផ្តើមប្រែប្រួលខុសគ្នា និងបន្តបែបនេះរហូត ក្នុងរយៈពេលក្រោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (២០០៥-២០០៧) ។ ផលិតផលមានអត្រាពន្ធគយទាប ឃើញមានកំណើនការនាំចូលខ្លាំង ចាប់ពីឆ្នាំ២០០៥ ចំណែកឯផលិតផលមានអត្រាពន្ធគយមិនសូវផ្លាស់ប្តូរ វាមានកំណើនយឺតជាង (ហើយក្នុងករណីខ្លះបានធ្លាក់ចុះ) ។ ការវិភាគ

បង្ហាញពីនិន្នាការនេះ គួសបញ្ជាក់ពីសារសំខាន់នៃពន្ធគយលើការនាំចេញរបស់ចិនមកកម្ពុជា ។ កិច្ចព្រមព្រៀង ACFTA បានបង្កើនពាណិជ្ជកម្មរវាងប្រទេសទាំងពីរ គួរឱ្យកត់សំគាល់ ជាពិសេសការនាំចេញពីចិនមកកម្ពុជា ។

***ក្រាហ្វិក ៧: និន្នាការនៃការនាំចូលផលិតផលពីចិនមកកម្ពុជា***




ប្រភព: Global Trade Atlas and UN Comtrade

ការវិភាគ RCA បង្ហាញថា ចិនមានឧត្តមភាពប្រៀបធៀបលើផលិតផលជាច្រើនប្រភេទ ដោយមានឯកទេសកម្មលើផលិតផលកម្មន្តសាល និងឧស្សាហកម្ម ។ តារាង A.13 នៅក្នុងឧបសម្ព័ន្ធបញ្ជាញថា ចិនមានឧត្តមភាពប្រៀបធៀបខ្លាំង លើឧបករណ៍អគ្គិសនី និងគ្រឿងម៉ាស៊ីន យានយន្ត វាយនភ័ណ្ឌនិងសំលៀកបំពាក់ លោហធាតុគ្រឹះ គ្រឿងសំរាប់ពាក់នៅជើង និងផលិតផលសេរ៉ាមិក ។ ផលិតផលទាំងនេះភាគច្រើន មានសន្ទស្សន៍ RCA ខ្ពស់ (ឧទាហរណ៍ ៤០៩ ចំពោះក្រណាត់និងផលិតផលពីការដេរប៉ាក់ និង ១១៥ ចំពោះដែកនិងដែកថែប) ដែលឆ្លុះបញ្ចាំងពីភាពគ្របដណ្តប់នៃទំនិញចិនក្នុងទីផ្សារកម្ពុជា និងមានជាអាទិ ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ជាពិសេស កប្បាស ក្រណាត់ និងគ្រឿងសំលៀកបំពាក់បន្ទាប់បន្សំ) ដែលកម្ពុជានាំចូលជាធាតុចូលនៃផលិតកម្មកាត់ដេរ ។ គេរំពឹងថាពាណិជ្ជកម្មរវាងប្រទេសទាំងពីរ នឹងបន្តកើនឡើងមួយផ្នែក ដោយសារគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ ដែលកំពុងដំណើរការ និងមួយផ្នែក ដោយសារឱកាសដ៏ប្រសើរ ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលប្រទេសទាំងពីរបានធ្វើឡើង ។

## ៥.២. ផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាននៅកម្ពុជា

តារាង ១២ បង្ហាញពីម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្មសំរាប់ការនាំចេញពីកម្ពុជាទៅចិន ។ តារាងបង្ហាញថា នៅឆ្នាំ២០០៧ កម្ពុជាបាននាំចេញផលិតផលមានការបំពុលខ្លាំង ក្នុងតំលៃប្រហែល ១,៩លានដុល្លារ ទៅចិន ឬជិតដល់ ៤% នៃការនាំចេញសរុបពីកម្ពុជាទៅចិន ។ តារាង ១៣ បង្ហាញពីផលចំណេញប៉ាន់ស្មានលើការបំពុលបានពីការនាំចូលទំនិញពីចិនមកកម្ពុជា ។ វាបានបញ្ជាក់ថា នៅឆ្នាំ២០០៧ កម្ពុជាបាននាំចូលផលិតផលមានការបំពុលខ្លាំង

ក្នុងតំលៃប្រហែល ៨៤,៥លានដុល្លារ ពីចិន ឬស្មើនឹង ១០% នៃការនាំចូលសរុបពីចិន ។ កម្ពុជាមិនមានឧត្តមភាពប្រៀបធៀបលើផលិតផលដែលបំពុលខ្លាំងឡើយ ដូចនេះការនាំចូលពួកវា ទំនងជួយផ្តល់ផលចំណេញខាងសុខុមាលភាពដល់កម្ពុជា ។ ចំពោះកម្ពុជា ការបំពុលបណ្តាលពីផលិតកម្មទំនិញនាំចេញដែលបំពុលខ្លាំងមានចំនួនតិចតួចណាស់ (២៣,០០០ផោន នៅឆ្នាំ២០០៧) ហើយការបំពុលបង្កពីកំណើននៃការនាំចូលផលិតផលដែលបំពុលខ្លាំង ក៏មានប្រភពនៅកន្លែងផ្សេងដែរ (នៅចិន) ។ នៅឆ្នាំ២០០៧ ការបំពុលប៉ាន់ស្មានបង្កដោយផលិតផលបំពុលខ្លាំងដែលនាំចូលពីចិន មាន ៦៨១.០០០ផោន ហើយនេះជាផលចំណេញមួយយ៉ាងច្រើនចំពោះបរិស្ថានកម្ពុជា ដែលបានមកពីពាណិជ្ជកម្ម ។ សរុបមក មុខទំនិញដែលធ្វើពាណិជ្ជកម្ម វាផ្តល់អត្ថប្រយោជន៍ដល់បរិស្ថានកម្ពុជា តែបែរជាធ្វើឱ្យខូចខាតដល់បរិស្ថាននៅចិនទៅវិញ ។

***តារាង ១២: ម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្មសំរាប់ការនាំចេញពីកម្ពុជាទៅចិន***

| លេខកូដ HS | បរិយាយ | 2001 | 2004 | 2007 | 2001 | 2004 | 2007 | 2001 | 2004 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | *តម្លៃ (ពាន់លានដុល្លារអាមេរិក)* | | | *ចំណែក (%)* | | | *EPI* (ផោន)* | | |
| 28-38 | សារធាតុគីមី | 0 | 0.07 | 1.86 | 0.0 | 0.2 | 3.6 | 0 | 855 | 23255 |
| 39-43 | ប្លាស្ទិក ស្បែកសត្វ | 0.03 | 0.01 | 0.02 | 0.1 | 0 | 0 | 71 | 27 | 52 |
| 47-49 | ក្រដាស | 0 | 0.01 | 0.02 | 0 | 0 | 0 | 2 | 45 | 62 |
| 71-83 | លោហធាតុគ្រឹះ | 0 | 0 | 0 | 0 | 0 | 0 | 0 | 8 | 13 |
| **ផ្នែកបំពុលខ្លាំង** | | **0.03** | **0.09** | **1.90** | **0.1** | **0.3** | **3.7** | **73** | **936** | **23382** |
| 50-63 | វាយនភ័ណ្ឌ និងសំលៀកបំពាក់ | 0.61 | 10 | 11.23 | 1.8 | 33.8 | 22.0 | 429 | 6978 | 7841 |
| 40 | កៅស៊ូ | 5.71 | 2.53 | 11.01 | 16.4 | 8.6 | 21.6 | 6713 | 2978 | 12958 |
| 93-96 | បរិក្ខារកម្មន្តសាលផ្សេងៗ | 0 | 0.04 | 0.14 | 0 | 0.1 | 0.3 | 0 | 26 | 84 |
| 25-27 | ផលិតផលរ៉ែ | 0 | 0 | 0.01 | 0.0 | 0.0 | 0.0 | 0 | 0 | 9 |
| 84-85 | បរិក្ខារអគ្គិសនី និងគ្រឿងម៉ាស៊ីន | 0.08 | 0.05 | 0.01 | 0.2 | 0.2 | 0 | 38 | 26 | 4 |
| 86-89 | យានយន្ត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 |
| **ផ្នែកបំពុលមធ្យម** | | **6.40** | **12.62** | **22.41** | **18.4** | **42.7** | **43.9** | **7181** | **10009** | **20897** |
| 44-46 | ឈើ និងផលិតផលធ្វើពីឈើ | 27.03 | 15.07 | 24.09 | 77.7 | 51.0 | 47.2 | 10595 | 5907 | 9442 |
| 1-5 | សត្វរស់ | 1.17 | 1.32 | 2.20 | 3.4 | 4.5 | 4.3 | 21 | 23 | 38 |
| 64-67 | គ្រឿងសំរាប់ពាក់នៅជើង | 0 | 0.03 | 0.30 | 0 | 0.1 | 0.6 | 0 | 12 | 146 |
| 15-24 | ម្ហូបអាហាររៀបចំស្រាប់ | 0 | 0.06 | 0.12 | 0 | 0.2 | 0.2 | 0 | 14 | 29 |
| 6-14 | ផលិតផលបន្លែ | 0.17 | 0.36 | 0.06 | 0.5 | 1.2 | 0.1 | 3 | 6 | 1 |
| 68-70 | ថ្ម/ស៊ីម៉ង់ត៍ /សេរ៉ាមិក | 0.01 | 0.01 | 0 | 0 | 0 | 0 | 4 | 3 | 1 |
| 90-92 | គ្រឿងអុបទិច ឧបករណ៍សំរាប់វាស់វែង និងឧបករណ៍តន្ត្រី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 97-99 | ស្នាដៃសិល្បៈនិងវត្ថុបុរាណ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **ផ្នែកបំពុលតិច** | | **28.38** | **16.84** | **26.77** | **81.5** | **57.0** | **52.4** | **10623** | **5965** | **9657** |
| សរុប | ផលិតផលទាំងអស់ | 34.80 | 29.56 | 51.08 | 100 | 100 | 100 | 17877 | 16910 | 53936 |

* Estimated Pollution Intensity

ប្រភព: ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើទិន្នន័យបានពី Global Trade Atlas

នៅឆ្នាំ២០០៧ កម្ពុជាបាននាំចេញផលិតផលក្នុងផ្នែកបំពុលមធ្យមទៅចិន ក្នុងតម្លៃ ២២,៤១លានដុល្លារ ឬ ៤៤% នៃបរិមាណសរុប ហើយនាំចូលមកវិញនូវទំនិញក្នុងផ្នែកនេះយ៉ាងច្រើនដល់ ៨៣% នៃការនាំចូលសរុប

ពីចិន ។ ដោយសារផលិតកម្មទំនិញក្នុងផ្នែកនេះបង្កការបំពុលតិចជាខ្លាំង បើធៀបនឹងផលិតផលក្នុងផ្នែកបំពុលខ្លាំង ដូច្នេះការនាំចេញផលិតផលទាំងនេះ មិនសូវមានផលប៉ះពាល់ធំដុំទៅលើកំរិតការបំពុលឡើយ ដូចមានបង្ហាញក្នុងតារាងផ្នែកកំរិតការបំពុលប៉ាន់ស្មាន (EPI) ដែលមានតួលេខនៃការបំពុលស្មើនឹង ២១.000ផោន ។ ទោះយ៉ាងនេះក្តី បរិមាណការបំពុលបង្កពីការនាំចេញទំនិញផ្នែកនេះក្នុងឆ្នាំ២00៧ បានកើនមួយជាពីរ ធៀបនឹងឆ្នាំ២00៤ ហើយកត្តាសំខាន់ គឺកំណើនយ៉ាងខ្ពស់នៃការនាំចេញកៅស៊ូដែលមានការកែច្នៃខ្លះៗ ។ រហូតមកទល់ពេលនេះ ការបំពុលមានកំរិតកំណើនទាបបំផុត ។ ប៉ុន្តែបើសិនកម្ពុជាពង្រីកការនាំចេញទំនិញក្នុងផ្នែកនេះទៅចិន ដោយសារខ្លួនមានឯកទេសកម្មខាងនេះ និងដើម្បីឆ្លើយតបទៅនឹងតំរូវការខ្ពស់ និងឱកាសពាណិជ្ជកម្ម ដែលកើតចេញពីការកាត់បន្ថយពន្ធគយ កំរិតនៃការបំពុលក៏នឹងកើនឡើងដែរ ។

ម៉ាទ្រីសបរិស្ថាន-ពាណិជ្ជកម្ម ក៏បង្ហាញដែរថា ចំពោះផលិតផលដែលកម្ពុជានាំចេញទៅចិន មានពាក់កណ្តាលជាផលិតផលស្ថិតក្នុងផ្នែកមានការបំពុលតិច ដោយមានកំរិតបំពុលប៉ាន់ស្មាន (EPI) តិចជាង ១0.000ផោនបន្តិច ។ ផលិតផលមួយចំនួនក្នុងផ្នែកនេះ ជាផលិតផលដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប ដូច្នេះការនាំចេញក្នុងផ្នែកនេះរំពឹងថានឹងកើនឡើង (ប៉ុន្តែលំនាំនៃការនាំចេញ ទំនងជាមិនសូវផ្លាស់ប្តូរទេ) ។ ទោះជាមានការរំពឹងពីកំណើនក្តី ក៏ផលិតផលក្នុងផ្នែកនេះទំនងជាមានផលប៉ះពាល់តិចតួចបំផុតទៅលើបរិស្ថាន ។

***តារាង ១៣: ផលចំណេញប៉ាន់ស្មានលើការបំពុល ដែលកម្ពុជាទទួលបានពីការនាំចូលទំនិញពីចិន***

| **បរិយាយ** | **2001** | **2004** | **2007** | **2001** | **2004** | **2007** | **2001** | **2004** | **2007** |
|---|---|---|---|---|---|---|---|---|---|
| | ***តម្លៃ (ពាន់លានដុល្លារអាមេរិក)*** | | | ***ចំណែក (%)*** | | | ***EPI* (ផោន)*** | | |
| ផ្នែកបំពុលខ្លាំង | 29.50 | 48.35 | 84.50 | 14 | 11 | 10 | 260 | 389 | 681 |
| ផ្នែកបំពុលមធ្យម | 147.01 | 353.98 | 732.05 | 72 | 78 | 83 | 102 | 241 | 488 |
| ផ្នែកបំពុលតិច | 27.35 | 50.01 | 64.69 | 13 | 11 | 7 | 10 | 15 | 22 |
| **ផលិតផលទាំងអស់** | 203.87 | 452.33 | 881.25 | 100 | 100 | 100 | 372 | 645 | 1190 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើទិន្នន័យបានពី Global Trade Atlas

ការវិភាគខាងលើបង្ហាញថា ផលិតផលក្នុងផ្នែកមានការបំពុលតិច ដូចជា ឈើនិងផលិតផលធ្វើពីឈើ បង្កការបំពុលតិចតួច ដែលអាចនាំឱ្យគេសន្និដ្ឋានថា ការនាំចេញឈើនិងផលិតផលធ្វើពីឈើ មានផលប៉ះពាល់តិចតួចបំផុតដល់បរិស្ថាន ។ ប៉ុន្តែការពិនិត្យលំអិតទៅលើផលប៉ះពាល់ច្រើនបែបយ៉ាងនៃពាណិជ្ជកម្មឈើ បានផ្តល់លទ្ធផលខុសពីនេះ ។ ការសិក្សាជាច្រើនបានបង្ហាញថា ពាណិជ្ជកម្មខ្នាតធំលើឈើនិងផលិតផលធ្វើពីឈើ គឺជាកត្តាចំបងនាំឱ្យមានការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា ។ ព្រៃឈើកម្ពុជាបានបាត់បង់ក្នុងអត្រាមួយយ៉ាងលឿន (ដែលស្ថិតក្នុងចំណោមអត្រាខ្ពស់ៗបំផុតលើសាកលលោក) ដោយនៅប៉ុន្មានឆ្នាំចុងក្រោយនេះ គំរបព្រៃឈើបានថយចុះមកត្រឹម ៥0% ធៀបនឹង ៧៣% ក្នុងឆ្នាំ១៩៦៥ ។

ការកាប់បំផ្លាញព្រៃឈើលឿនបែបនេះ មានឥទ្ធិពលអវិជ្ជមានច្រើន ហើយឥទ្ធិពលច្បាស់លាស់ជាងគេ និងគួរឱ្យបារម្ភបំផុត គឺផលអវិជ្ជមានទៅលើជីវៈចម្រុះ ការស្រូបទឹកទុក និងសំណឹក ។ ការបាត់បង់ព្រៃឈើនាំឱ្យបាត់បង់ទីជម្រកនៃពពួកសត្វ និងរុក្ខជាតិជាច្រើនប្រភេទ ព្រមទាំងអនុផលព្រៃឈើ ។ ម៉្យាងទៀត ដោយសារការកាប់បំផ្លាញព្រៃឈើច្រើនកើតមាននៅតំបន់ខ្ពង់រាប និងបានកាត់បន្ថយសមត្ថភាពស្រូបទឹកទុក ដូច្នេះវាធ្វើឱ្យតំបន់វាលទំនាបងាយរងគ្រោះដោយទឹកជំនន់ ហើយតំបន់ជម្រាលងាយរងគ្រោះដោយការបាក់រលុះដី ។ ទន្ទឹមនឹងការថយចុះយ៉ាងរហ័សនៃព្រៃឈើទូទាំងសាកលលោក ការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា ក៏ទំនងជាចូលរួមចំណែកក្នុងការធ្វើឱ្យផែនដីឡើងកំដៅផងដែរ ។

ដោយសារតម្រូវការដ៏ខ្លាំងក្លានូវផលិតផលកៅស៊ូ ដែលជាធាតុចូលពាក់កណ្តាលសម្រេចនៃផលិតកម្មទំនិញ ដូចជា កង់ឡាន និងខ្សែកាប ជាដើម ចិនទំនងជាបង្កើនការនាំចូលផលិតផលទាំងនេះពីប្រទេសជិតខាង ។ កត្តានេះបង្កើតជាកម្លាំងជំរុញឱ្យអ្នកនាំចេញកៅស៊ូនៅកម្ពុជាបង្កើនផលិតកម្ម ជាពិសេសតាមរយៈការពង្រីកផ្ទៃដីដាំដុះ ។ ទោះបីជាការពង្រីកចំការកៅស៊ូសំដៅនាំចេញអំណោយផលដល់សេដ្ឋកិច្ចជាតិក្តី ប៉ុន្តែវាបង្កើតក្តីបារម្ភជាច្រើនខាងបរិស្ថាន ។ តំបន់សមស្របបំផុតសំរាប់ដំណាំកៅស៊ូស្ថិតនៅប៉ែកឦសាន មានខេត្តកំពង់ចាម ក្រចេះ មណ្ឌលគីរី និងរតនគីរី ប៉ុន្តែខេត្តទាំងនេះ នៅគ្របដណ្តប់ដោយព្រៃឈើយ៉ាងច្រើន ។ ដូចនេះ ការពង្រីកផលិតកម្មកៅស៊ូអាចបង្កការកាប់បំផ្លាញព្រៃឈើថែមទៀត និងផលប៉ះពាល់អវិជ្ជមានជាច្រើនទៅលើបរិស្ថាន ។

ចិន ជាទីផ្សារចំបងសំរាប់ផលនេសាទកម្ពុជា និងមានសក្តានុពលខ្ពស់សំរាប់ការពង្រីកថែម ។ ឱកាសនេះអាចនាំឱ្យកើនសកម្មភាពនេសាទ ។ ប៉ុន្តែជាភ័ព្វអាក្រក់ សព្វថ្ងៃកាន់តែមានកំណើនការប្រើប្រាស់វិធីនេសាទមិនសមស្រប និងក្នុងករណីខ្លះវិធីខុសច្បាប់តែម្តង ទាំងក្នុងទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំ ដែលបណ្តាលឱ្យខូចខាតដល់ស្តុកត្រី និងអាចជះឥទ្ធិពលមិនល្អទៅលើជីវៈចម្រុះ និងជីវភាពរស់នៅក្នុងតំបន់ ជាពិសេសសំរាប់ប្រជាជនអ្នកពឹងផ្អែកដោយផ្ទាល់ទៅលើការនេសាទ (គេប៉ាន់ស្មានថា មានប្រហែល ៤០% នៃប្រជាជនកម្ពុជា) ។

រដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការសកម្មភាពជាតិលើផ្នែកបរិស្ថាន (National Environmental Action Plan) ដើម្បីគ្រប់គ្រងអភិរក្ស និងការពារ បរិស្ថាននិងធនធានធម្មជាតិ តាមបែបបទមួយដែលរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី ។ ដើម្បីដោះស្រាយបញ្ហាចំបង១ខាងបរិស្ថាន ផែនការខាងលើបានផ្តោតជាសំខាន់ទៅលើសកម្មភាពអាទិភាពចំនួន ៦ រួមមាន: (១) គោលនយោបាយព្រៃឈើ (២) នេសាទ និងកសិកម្មនៅវាលទំនាបក្នុងតំបន់ទន្លេសាប (៣) ការគ្រប់គ្រងការនេសាទតាមសមុទ្រ (៤) ជីវៈចម្រុះនិងតំបន់ការពារ (៥) បរិស្ថាន និងការអភិវឌ្ឍថាមពល និង (៦) ការគ្រប់គ្រងកាកសំណល់ទីក្រុង ។ ប៉ុន្តែការអនុវត្តតាមផែនការនេះ ជួបប្រទះនូវកត្តារារាំងជាច្រើន ដូចជា កង្វះខាតបុគ្គលិកជំនាញ ការបែងចែកថវិកាមិនគ្រប់គ្រាន់ មុខងារត្រួតស៊ីគ្នានៃភ្នាក់ងារទទួលបន្ទុក និងបរិក្ខាររូបវន្តមិនគ្រប់គ្រាន់ ។

សរុបមក តំរូវការខ្ពស់លើផលិតផលធនធានធម្មជាតិ អាចនាំឱ្យមានការទាញយកចំណេញហួសហេតុ និងរបៀបរបបអនុវត្តគ្មានចីរភាពនៅកម្ពុជា ។ ទោះបីជារដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពជាតិលើផ្នែក

បរិស្ថានរួចហើយក្តី ប៉ុន្តែវាមានការរាំងពីកង្វះខាតនូវគោលការណ៍ណែនាំច្បាស់លាស់ និងប្រព័ន្ធគ្រប់គ្រងប្រកបដោយតម្លាភាព សំរាប់គ្រប់គ្រងលើការទាញយកធនធានធម្មជាតិសំរាប់ពាណិជ្ជកម្ម ។ ប្រសិនបើមិនមានការដោះស្រាយឧបសគ្គទាំងនេះទេ កំណើនពាណិជ្ជកម្មលើផលិតផលផ្អែកលើធនធានធម្មជាតិដែលបានគ្រោងទុក ទំនងជាធ្វើឱ្យហិនហោចធនធាននៅក្នុងរយៈពេលខ្លី ហើយបង្កអន្តរាយដល់បរិស្ថានធម្មជាតិនៅកម្ពុជាថែមទៀត ។

# ជំពូក ៦

## សន្និដ្ឋាន និងការពិភាក្សាជាគោលនយោបាយ

ការសិក្សានេះ បានពិនិត្យស្រាវជ្រាវពីទំនាក់ទំនងទូទៅរវាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ពាណិជ្ជកម្ម និងបរិស្ថាន តាមរយៈករណីសិក្សាមួយលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ដោយពិនិត្យទៅលើផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ ឈរលើទស្សនៈនៃប្រទេស GMS5 និងកម្ពុជា ។ ការសិក្សាក៏បានពិនិត្យពីការវិវត្តនៃពាណិជ្ជកម្មទំនិញរវាងចិន និងប្រទេស GMS5 ក្រោមកិច្ចព្រមព្រៀង ACFTA និងព្យាយាមវាយតម្លៃពីផលប៉ះពាល់បង្កដោយពាណិជ្ជកម្មនេះទៅលើបរិស្ថាននៅមហាអនុតំបន់មេគង្គ ។ ការពិនិត្យពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថាន បានធ្វើឡើងតាមបែបបរិមាណ ដោយយកការបំពុលជាធ្វើរង្វាស់នៃការរេចរឹលផ្នែកបរិស្ថាន ។ ម្យ៉ាងទៀត ក៏បានធ្វើការវាយតម្លៃបែបគុណភាពមួយដែរ អំពីផលប៉ះពាល់ផ្សេងៗទៅលើបរិស្ថាននៃទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងចិន នេះ ។

នៅប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសនៅមហាអនុតំបន់មេគង្គមានកំណើនពាណិជ្ជកម្មក្នុងតំបន់យ៉ាងឆាប់រហ័ស ហើយកិច្ចព្រមព្រៀង ACFTA ជាកត្តាដ៏ចំបងមួយដែលជំរុញនិន្នាការនេះ ។ ឧទាហរណ៍ ការកាត់បន្ថយពន្ធគយក្រោមកម្មវិធីប្រមូលផលដើមដៃ បានចូលរួមយ៉ាងសំខាន់ក្នុងកំណើនដ៏លឿននៃពាណិជ្ជកម្ម ក្នុងវិស័យកសិកម្មរវាងអាស៊ាន និងចិន ។ នៅឆ្នាំ២០០៦ ប្រទេសទាំងពីរបានធ្វើពាណិជ្ជកម្មលើផលិតផលបានពីកម្មវិធី EHP ក្នុងតម្លៃ ២,៦២ពាន់លានដុល្លារ ឬកើនឡើង ១០០% បើធៀបនឹងឆ្នាំ២០០៣ ។ ការវិភាគអំពីលំហូរទំនិញធ្វើពាណិជ្ជកម្មរវាងប្រទេស GMS5 និងចិន បង្ហាញថា ការកាត់បន្ថយពន្ធគយនៃកិច្ចព្រមព្រៀង ACFTA បានជំរុញឱ្យមានកំណើនយ៉ាងលឿននៃការនាំចូលទំនិញរបស់ GMS5 ទៅក្នុងប្រទេសចិន ក៏ដូចជា ការនាំចូលទំនិញរបស់ចិនទៅក្នុងប្រទេស GMS5 វិញដែរ ក្នុងនេះការចូលទំនិញរបស់ចិន ទៅក្នុងប្រទេសកម្ពុជាមានកំណើនយ៉ាងខ្លាំង ហើយគ្របដណ្តប់លើទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា-ចិន ។ កិច្ចព្រមព្រៀង ACFTA ក៏សំខាន់ណាស់ដែរ ក្នុងការលើកកម្ពស់ការនាំចេញផលិតផលដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប ប៉ុន្តែមិនមែនជាការនាំចេញទំនិញកសិកម្មដែលតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ពីភូតគាមអនាម័យនោះទេ ។

ពាណិជ្ជកម្មទំនិញរវាងប្រទេស GMS5 និងចិន ផ្តោតខ្លាំងទៅលើឧបករណ៍អគ្គិសនី និងគ្រឿងចក្រ លោហធាតុគ្រឹះ ផលិតផលរ៉ែ សារធាតុគីមី វាយនភ័ណ្ឌនិងសំលៀកបំពាក់ កៅស៊ូ និងបន្លែ ។ ប្រហែលពីរភាគបីនៃផលិតផលក្នុងពាណិជ្ជកម្មទំនិញសរុប គឺជាផលិតផលស្ថិតក្នុងផ្នែកមានការបំពុលតិច ហើយមួយភាគបីទៀតស្ថិតក្នុងផ្នែកមានការបំពុលខ្លាំង ។ ការបំពុលបង្កដោយផ្នែកដែលបំពុលខ្លាំងវាមានកំរិតខ្ពស់ ហើយកំណើនក្នុងផ្នែកនេះ ទំនងជាបង្កការបំពុលកាន់តែធ្ងន់ធ្ងរក្នុងរយៈពេលខ្លីខាងមុខ ។ នៅមហាអនុតំបន់មេគង្គ ចិន គឺជាផលិតករចំបងគេនូវទំនិញក្នុងផ្នែកដែលបំពុលខ្លាំង គឺបានន័យថា ការបំពុលភាគច្រើននៅក្នុងមហាអនុតំបន់មេគង្គមានប្រភពមកពីប្រទេសចិន ។

ក្នុងមហាអនុតំបន់មេគង្គ មានការធ្វើពាណិជ្ជកម្មយ៉ាងច្រើនណាស់លើធនធានធម្មជាតិ ដូចជា រ៉ែ ផលិតផលកសិកម្មនិងឈើ និងផលិតផលធ្វើពីធនធានទាំងនេះ ។ ពាណិជ្ជកម្មលើផលិតផលផ្អែកលើធនធានធម្មជាតិ បង្កការព្រួយបារម្ភពីការហិនហោចធនធាន ។ នៅប្រទេសនានាដែលពុំមានប្រព័ន្ធច្បាប់គ្រប់គ្រងសក្តិសិទ្ធិល្អ ពាណិជ្ជកម្មជំរុញដោយការធ្វើអាជីវកម្មលើធនធានធម្មជាតិ អាចនាំឱ្យមានការកាប់ឈើខុសច្បាប់ និងការកាប់ព្រៃមិនសមស្រប ដែលធ្វើឱ្យបាត់បង់ធនធានព្រៃឈើ និងប៉ះពាល់ដល់បរិស្ថានមូលដ្ឋាន និងលើសាកលលោក ។

ការរេចរឹលធនធានធម្មជាតិ ជាក្តីបារម្ភពិសេសមួយសំរាប់កម្ពុជា ដែលជាប្រទេសនាំចេញផលិតផលផ្អែកលើធនធានធម្មជាតិជាច្រើន ដូចជា ឈើ ត្រី និងកៅស៊ូ ជាដើម ហើយកំណើនពាណិជ្ជកម្មទំនិញទាំងនេះ បង្កក្តីបារម្ភខាងបរិស្ថានជាច្រើន ។ ឧទាហរណ៍ ការកាប់បំផ្លាញព្រៃឈើ បានកាត់បន្ថយជីវៈចម្រុះ បង្កើនសំណឹកដី និងផ្លាស់ប្តូរទ្រង់ទ្រាយផ្លូវទឹក ជាពិសេសទន្លេមេគង្គ ទន្លេសាប និងបឹងទន្លេសាប ។ ការនេសាទច្រើនហួសហេតុ ជះឥទ្ធិពលអាក្រក់ទៅលើស្តុកត្រី និងមានផលប៉ះពាល់អវិជ្ជមានទៅលើជីវភាពរស់នៅតាមមូលដ្ឋាន ជាពិសេសសំរាប់ប្រជាជនដែលពឹងផ្អែកដោយផ្ទាល់លើការនេសាទ ។

ទោះបីជារដ្ឋាភិបាលបានបង្កើតផែនការជាតិ ដើម្បីគ្រប់គ្រងអភិរក្ស និងការពារមូលដ្ឋានធនធានធម្មជាតិកម្ពុជាក៏ដោយ ក៏ការអនុវត្តជួបប្រទះឧបសគ្គជាច្រើន ដូចជា កង្វះបុគ្គលិកជំនាញ ការបែងចែកថវិកាមិនគ្រប់គ្រាន់ ភារកិច្ចត្រួតស៊ីគ្នាក្នុងចំណោមភ្នាក់ងារទទួលបន្ទុក និងបរិក្ខាររូបវន្តមិនគ្រប់គ្រាន់ ។

កិច្ចព្រមព្រៀង ACFTA មិនមានបញ្ញត្តិចែងពី កិច្ចសហប្រតិបត្តិការលើបញ្ហាបរិស្ថានដែលអាចកើតមានដោយសារសេរីភាវូបនីយកម្មពាណិជ្ជកម្មនោះទេ ។ នៅខាងក្រៅកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្តីបារម្ភពីបរិស្ថានត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំកំពូលរបស់មហាអនុតំបន់មេគង្គ ប៉ុន្តែមិនមានឧបករណ៍ខាងគោលនយោបាយសំរាប់គ្រប់គ្រងលើកិច្ចការពារបរិស្ថាន និងគំនិតផ្តួចផ្តើមធ្វើការអភិរក្ស ហើយក៏មិនមានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់រវាងប្រទេសក្នុងមហាអនុតំបន់មេគង្គ ដើម្បីដោះស្រាយបញ្ហាទាំងនេះឡើយ ។ រឿងនេះបង្ហាញពីចំណុចខ្វះខាតក្នុងការបង្កើតគោលនយោបាយសេដ្ឋកិច្ចថ្នាក់តំបន់ ។

ជាការពិតណាស់ ការដាក់បញ្ចូលក្តីបារម្ភពីបញ្ហាបរិស្ថានទៅក្នុងរបៀបវារៈពាណិជ្ជកម្មរបស់មហាអនុតំបន់មេគង្គមិនមែនងាយស្រួលទេ ដោយសារសព្វថ្ងៃកំរិតអភិវឌ្ឍន៍ក្នុងតំបន់វានៅទាបនៅឡើយ ដែលតំរូវឱ្យមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់មួយរយៈពេលវែង ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចបានមកពីការរេចរឹលបរិស្ថាន វាមិននាំទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពទេ ។ ការស្វែងរកតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងចីរភាពបរិស្ថាន គឺជាបញ្ហាប្រឈមជាអាទិភាព ដើម្បីទទួលបានការអភិវឌ្ឍប្រកបដោយចីរភាពក្នុងមហាអនុតំបន់មេគង្គ ។ ជាការសំខាន់ ប្រទេសនៅមហាអនុតំបន់មេគង្គត្រូវពង្រឹងកិច្ចប្រតិបត្តិការ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាបរិស្ថាន ។

ការសិក្សាមានគោលដៅចំបង គួសបញ្ជាក់ពីទំនាក់ទំនងរវាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ពាណិជ្ជកម្មនិងបរិស្ថាន នៅក្នុងមហាអនុតំបន់មេគង្គ ដោយផ្តោតលើការបំពុលដែលត្រូវបានប្រើជារង្វាស់នៃផលប៉ះពាល់របស់

ពាណិជ្ជកម្មទៅលើបរិស្ថាន ។ កិច្ចព្រមព្រៀង ACFTA នៅថ្មីថ្មោងណាស់ និងកំពុងដាក់អនុវត្តសន្សឹមៗ ដូច្នេះ ការវាយតម្លៃពីផលប៉ះពាល់ណាមួយ អាចគ្រាន់តែជាការវាយតម្លៃបឋម និងជួយផ្តល់ជាគំនិតខ្លះប៉ុណ្ណោះ ។

ការវិភាគធ្វើឡើងក្នុងការសិក្សានេះ មានដែនកំណត់ជាច្រើន ហេតុនេះគួរមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ។ ទីមួយ ឥទ្ធិពលនៃកិច្ចព្រមព្រៀង ACFTA ទៅលើពាណិជ្ជកម្ម មិនទាន់វិភាគបានពេញលេញទេ ព្រោះទិន្នន័យមានកំណត់ ហើយរយៈពេលក៏ខ្លីពេក គិតចាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះមក ។ ការសិក្សាស្រាវជ្រាវបន្ថែមលើលំហូរពាណិជ្ជកម្មដែលបណ្តាលមកពីកិច្ចព្រមព្រៀង ACFTA អាចបន្ថែមតម្លៃលើការសិក្សានេះ ។ ទីពីរ ការសិក្សានេះមិនទាន់បានពិនិត្យពេញលេញពីផលវិបាក នៃពាណិជ្ជកម្មទំនិញផ្អែកលើធនធានធម្មជាតិទៅលើចីរភាពធនធានឡើយ ហេតុនេះចាំបាច់ត្រូវសិក្សាបន្ថែមលើផលប៉ះពាល់ខាងសង្គម និងបរិស្ថាន ដែលកើតចេញពីការប្រើប្រាស់ធនធាន ។ ទីបី នៅមហាអនុតំបន់មេគង្គ ពាណិជ្ជកម្មផលិតផលព្រៃឈើ និងត្រី បានកើនឡើង ហើយគំរបព្រៃ និងស្តុកត្រីនៅមហាអនុតំបន់មេគង្គ បានថយចុះ ។ ការសិក្សាផ្តោតទៅលើពាណិជ្ជកម្មផលិតផលព្រៃឈើ និងធនធានត្រី ព្រមទាំងផលប៉ះពាល់លើបរិស្ថាននៅមហាអនុតំបន់មេគង្គ អាចនឹងជួយបំពេញបន្ថែមលើការសិក្សានេះ ។

សរុបមកការសិក្សានេះបានរំលេចថា ពាណិជ្ជកម្ម គឺជាប្រភពនៃបញ្ហាបរិស្ថានដ៏សំខាន់ ជាពិសេសក្នុងបណ្តាប្រទេសដែលពុំមានប្រព័ន្ធគ្រប់គ្រង ឬក្របខ័ណ្ឌច្បាប់ដ៏ចាំបាច់ ដើម្បីធានាឱ្យមានការធ្វើអាជីវកម្មលើធនធានធម្មជាតិប្រកបដោយចីរភាព ថ្វីបើជាទូទៅគេចាត់ទុកពាណិជ្ជកម្មជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចក្តី ។ ដូច្នេះ ការសិក្សានេះបានផ្តល់ជាអនុសាសន៍ថា គួរយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាន និងដាក់បញ្ចូលបញ្ហាទាំងនេះក្នុងកិច្ចចរចា និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានានៃពាណិជ្ជកម្មទៅលើបរិស្ថាន ។ ធ្វើដូច្នេះទើបពាណិជ្ជកម្មអាចជួយជំរុញកំណើនសេដ្ឋកិច្ច និងចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព ។

# ឯកសារយោង


Adelman, I. & Robinson, S. (1988), "Macroeconomic adjustment and income distribution: Alternative models applied to two economies." *Journal of Development Economics*, Vol. 29

Agras, J. & Chapman, D. (1999), "A dynamic approach to the Environmental Kuznets Curve hypothesis." *Ecological Economics* 28: 267–27

Albrecht, J. (1998), "Environmental policy and inward investment position of US dirty industries." *Intereconomics*, July/August 1998: 186–194

